# សន្ទានុក្រម ពាក្យច្បាប់ពាណិជ្ជកម្ម

# TRI-LINGUAL COMMERCIAL LEGAL TERMS

ឯកសារ បណ្តុះបណ្តាល

TRAINING MATERIALS

បណ្ណាល័យច្បាប់-Law Library
lawlibrarysite.wordpress.com

# A

| ENGLISH | FRENCH | KHMER |
|---|---|---|
| A fortiori | A fortiori | សេចក្ដីសន្និដ្ឋានដែលផ្អែកលើភាពប្រាកដប្រជា ។ |
| A posteriori | A posteriori | វិធានឬសេចក្ដីសន្និដ្ឋាន ដោយផ្អែកលើការពិសោធន៍ជាក់ស្ដែង ឬ ការសង្កេតជាក់ស្ដែង ។ |
| A priori | A priori | របៀបគិតគូរដោយផ្អែកលើហេតុការណ៍ ដែលមានពីមុន ដើម្បីយល់ដឹងពីហេតុការណ៍ក្រោយៗ ទៀត ដោយមិនផ្អែកលើការពិសោធន៍ទេ ។ |
| Abrogate | Abroger | ទុកជាមោឃៈ ។ |
| Abrogation | Abrogation | ការទុកជាមោឃៈ ។ |
| Absolute | Absolu | មានអំណាចមិនអាចជំទាស់បាន, គ្មានការលើកលែង ។ |
| Absolute Characteristic | Caractére absolu | លក្ខខណ្ឌដាច់ខាត ។ លក្ខខណ្ឌដាច់ខាតរបស់មូលប័ត្រ គឺ លក្ខណៈ មិនអាចប្ដូរពីមូលប័ត្រមួយទៅមូលប័ត្រមួយទៀត ។<br>**ឧទាហរណ៍ :** ប្ដូរពីសញ្ញាប័ណ្ណទៅជាភាគហ៊ុន ។ |
| Absolute majority | Majorité absolue | សំលេងភាគច្រើនដាច់ខាត ។<br>**ឧទាហរណ៍ :** នៅក្នុងការសំដែងមតិ ឬការបោះឆ្នោត គឺសម្លេងលើសពីពាក់កណ្ដាលនៃចំនួន អ្នកសំដែងមតិទាំងអស់ដែលបានចូលរួម ។ |
| Absorption | Fusion-absorption | ការរំលាយក្រុមហ៊ុនចូលគ្នាតាមវិធីក្រុមហ៊ុនមួយរំលាយ ចូលជាមួយក្រុមហ៊ុនមួយទៀត ( សូមអានពាក្យ Merger) |
| Abstention | Abstention | អនុប្បវាទ, ការមិនប្រើសិទ្ធរបស់ខ្លួន ។ |
| Abuse | Abus | ការរំលោភ ។ |
| Accede | Accéder à | យល់ព្រម, ចូលកាន់ការងារ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Accept | Accepter | យល់ព្រមទទួលអ្វីមួយ ឬ ធ្វើតាមលក្ខខណ្ឌអ្វីមួយ ។ |
| Acceptance | Acceptation: | ការព្រមទទួល ។ |
| Accession | Adhésion; accession | ការចូលជាសមាជិក ។ |
| Accomplice | Complice | អ្នកសមគំនិត ។ |
| Accounting records | Documents comptables | បញ្ជីគណនេយ្យ ។ |
| Accuracy | Exactitude | ភាពច្បាស់លាស់, ភាពត្រឹមត្រូវ ។ |
| Accusation | Accusation | ការចោទប្រកាន់ ។ |
| Accused | Accusé | ជនជាប់ចោទ ។ |
| Acknowledgment | Reconnaissance | ការទទួលស្គាល់, ការទទួលដឹងឮ ។ |
| Acquire | Acquérir | បានទទួល, ទិញ, ជាវ ។ |
| Act honestly | Acte légitime | សកម្មភាពស្របច្បាប់ ។ |
| Act of God | Force majeure | បាតុភាពធម្មជាតិ ដែលមិនអាចគ្រោងទុកជាមុនបាន ដូចជា ខ្យល់ព្យុះ រំញ្ជួយផែនដី ទឹកជំនន់ រន្ទះបាញ់ ។ល។ |
| Act of merchant | Acte de commerce | សកម្មភាពពាណិជ្ជកម្ម : ជាសកម្មភាពទិញលក់ទំនិញ ឬសេវា ដែលត្រូវបានអនុវត្តជាប្រចាំក្នុងគោលដៅ ធ្វើការដោះដូរ នឹង ស្វែងរកចំណេញ ។ សកម្មភាពទាំងនោះត្រូវបានចែងក្នុង មាត្រា ២ នៃច្បាប់ស្តីពីវិធាន ពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។ |
| Adjourn of proceeding | Surseoir à statuer | បញ្ឈប់ដំណើរក្តី ឧទាហរណ៍: យោងតាមបណ្តឹងទាមទាររបស់ ភាគីជម្លោះមួយស្នើសុំអោយតុលាការលុបសេចក្តីសំរេចរបស់មជ្ឈត្តករ ។ ប្រសិនបើភាគីប្តឹងនោះ មិនមានសំអាងត្រឹមត្រូវ តាមច្បាប់ទេ តុលាការអាចបញ្ឈប់ដំណើរក្តីនេះហើយបញ្ជាអោយភាគីទាំងពីរអនុវត្ត សេចក្តីសំរេចរបស់មជ្ឈត្តករ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Adjournment | Ajournement | ការលើកពេល, ការផ្អាកសម័យប្រជុំ ។ |
| Adjudicate | Juger | វិនិច្ឆ័យ, ធ្វើសេចក្ដីសំរេច ។ |
| Administer | Gérer; Administrer | គ្រប់គ្រង, ចាត់ចែង ។ |
| Administrative law | Droit administratif | ច្បាប់រដ្ឋបាល ។ |
| Administrator | Administrateur | អភិបាល, អ្នកគ្រប់គ្រង ។ |
| Admissibility | Recevabilité | ភាពដែលអាចទទួលយកបាន ។ |
| Adopt | Adopter | យល់ព្រមយក, អនុម័ត ។ |
| Adultery | Adultère | ការផិតក្បត់ ។ |
| Advantage | Avantage | អត្ថប្រយោជន៏ ។ |
| Advertisement | Annonce; Publicité | ការប្រកាសផ្សាយពាណិជ្ជកម្ម ។ |
| Advocate | Avocat | មេធាវី ។ |
| Affairs | Affaires | ប្រតិបត្តិការអាជីវកម្មគ្រប់ប្រភេទ ។ |
| Affidavit | Affidavit, Attestation par écrit | លិខិតបញ្ជាក់ ដើម្បីធ្វើភស្តុតាងចំពោះមុខអាជ្ញាធរ ។ |
| Affiliate | Groupe de sociétés | សម្ព័ន្ធភាពក្រុមហ៊ុន : ជាក្រុមហ៊ុនដែលមានឯករាជ្យភាពរៀងៗ ខ្លួនតាមច្បាប់ប៉ុន្តែបានបង្កើតជាអង្គភាពសេដ្ឋកិច្ចមួយ ដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធផ្នែកហិរញ្ញវត្ថុ ។ |
| Agency | Agence | ទីភ្នាក់ងារ (ពាណិជ្ជកម្ម) : ជាអង្គភាពសេដ្ឋកិច្ចធ្វើសេវាឱ្យអ្នកដទៃក្នុងគោលបំណងយកកម្រៃសេវា ។ |
| Agenda | Ordre du jour | របៀបវារៈប្រជុំ ។ |
| Aggregate | Global, Totalité | តម្លៃសរុប ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Agreement | Accord | កិច្ចព្រមព្រៀង ។ |
| Aleatory | Aléatoire | មិនទៀង, ព្រឹត្តិការណ៍ដែលអាចកើតឡើងឬមិនអាចកើតឡើង ។ |
| Aleatory Contract | Contrat aleatoire | កិច្ចសន្យាដែលមានលក្ខណៈមិនទៀងទាត់ ។ ជាកិច្ចសន្យា ចំណុះទៅនឹងព្រឹត្តិការណ៍មិនទៀងទាត់ និង ជាព្រឹត្តិការណ៍ដែល បណ្តាលអោយភាគីមួយទទួលផលនឹងភាគីមួយទៀតខាតបង់ ផលប្រយោជន៍ ។ **ឧទាហរណ៍ :** កិច្ចសន្យាធានារ៉ាប់រង កិច្ចសន្យាលេងតុងទីន ការទិញឆ្នោត ។ល ។ |
| Allegation | Allégation | ការពោលអះអាង ។ |
| Allegiance | Allègeance | ស្ថានភាពចំណុះរបស់បុគ្គលម្នាក់ទៅនឹងអ្វីមួយ ។ |
| Allocate | Attribuer | បែងចែកទៅលើ ។ |
| Ambiguity | Ambiguïté | ភាពមានន័យមិនច្បាស់, លទ្ធភាពដែលអាច ធ្វើអោយឯកសារមួយ ត្រូវបានបកស្រាយបានច្រើនយ៉ាង ។ |
| Amend | Amender; Modifier | ធ្វើវិសោធនកម្ម, កែប្រែ ។ |
| Amendment | Amendement | ការធ្វើវិសោធនកម្ម, ការកែសំរួលឬបំពេញបន្ថែមនូវខចែងទាំងឡាយក្នុងច្បាប់ឬក្នុងកិច្ចសន្យាផ្សេងៗ ។ |
| Amicable arrangement | Reglement à l'amiable | ការដោះស្រាយជំលោះដោយការស្រុះស្រួលគ្នារវាងគូភាគី ។ |
| Amicable compositor | Amiable compositeur | អាជ្ញាកណ្តាលដែលកិច្ចព្រមព្រៀងផ្សះផ្សារ ផ្តល់ភារកិច្ចអោយ ដោះស្រាយជម្លោះដោយពុំចាំបាច់អនុវត្តតាមបញ្ញត្តិ និង នីតិវិធីនៃច្បាប់ ។ |
| Amortization | Amortissement | ការរំលោះ, ការរំលោះទុន, ការរំលោះបំណុល ។ |
| Analytical register | Registre analytique | បញ្ជីវិភាគីគឺជាបញ្ជីសំរង់តារាងដែលមានការចុះកាលបរិច្ឆេទ លេខចុះបញ្ជី ឈ្មោះក្រុមហ៊ុន កម្មវត្ថុ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| | | អាជីវកម្ម នឹង ដើមទុនក្រុមហ៊ុន (បញ្ជីនេះរក្សាទុកនៅ ក្រសួងពាណិជ្ជកម្ម) ។ |
| Announcement | Annonce; Publicité | សេចក្តីជូនដំណឹង ។ |
| Annulment | Annulation | មោឃៈភាព, ការធ្វើអោយទៅជាមោឃៈ ឬគ្មានសុពលភាពប្រើប្រាស់ ។ |
| Appeal | Appel | ប្តឹងឧទរណ៍, បណ្តឹងឧទ្ធរណ៍ដែលសុំអោយតុលាការថ្នាក់លើពិនិត្យឡើងវិញនូវសេចក្តីសំរេចរបស់តុលាការថ្នាក់ក្រោម ។ |
| Appealant | Appelant | ភាគីប្តឹងឧទ្ធរណ៍ ។ |
| Appellation of origin | Appellation d'origine | ការហៅឈ្មោះតាមប្រភពទំនិញ ។ ឈ្មោះទំនិញអាចហៅតាមឈ្មោះទីកន្លែងដែលជាប្រទេសមួយ ឬ តំបន់មួយដែលជាកន្លែងផលិតទំនិញនោះ ហើយដែលគុណភាព នឹង លក្ខណៈពិសេស របស់ទំនិញកើតចេញពី កត្តាធម្មជាតិ (ធាតុអាកាស ដី ប្រភពទឹក) នឹងកត្តាមនុស្ស (របៀបផលិតពីបូរាណ) របស់ប្រទេសនោះ ឬ តំបន់នោះ ។ ដើម្បីយកឈ្មោះប្រទេស ឬ តំបន់ទៅដាក់ជាឈ្មោះទំនិញបាន លុះត្រាតែវត្ថុធាតុដើម យកចេញពីប្រទេសឬតំបន់នោះ ទាំងស្រុង ហើយរបៀបផលិត ជារបៀបផលិតពីបូរាណ រៀនបន្តគ្នារបស់មនុស្សក្នុងប្រទេស ឬតំបន់នោះ ។<br>**ឧទាហរណ៍:** ស្រា Bordeaux ជាស្រាក្រហមផលិតនៅខេត្ត Bordeaux របស់បារាំង ផលិតចេញពីផ្លែទំពាំងបាយជូរដាំដុះនៅ Bordeaux និងរបៀបផលិតពិសេសរបស់អ្នកស្រុក Bordeaux ។ |
| Applicant | Requérant | អ្នកប្តឹងសុំ, ឧទាហរណ៍ អ្នកដែលសុំដាក់ប្រតិវេទន៍ នៅក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើអាជីវកម្ម ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Application for annulment | Recours en annulation | សំណើរបស់គូក្តីណាមួយទៅយុត្តាធិការថ្នាក់លើ សុំអោយលុបសេចក្តីសំរេចរបស់យុត្តាធិការថ្នាក់ក្រោម ឬ លុបសេចក្តីសំរេច របស់មជ្ឈត្តករ ។ |
| Appoint | Nommer | ចាត់តាំង ។ |
| Appraisal | Evaluation | ការវាយតំលៃ ។ |
| Arbitral panel | Tribunal arbitrale | វេទិការមជ្ឈត្តកម្ម : វេទិការនេះ បង្កើតឡើងដោយមានអាជ្ញាកណ្តាលមួយនាក់ ឬ មួយក្រុមសំរាប់ធ្វើការផ្សះផ្សាវិវាទ ។ |
| Arbitral proceedings | Procédure arbitrale | នីតិវិធីផ្សះផ្សាវិវាទដោយអាជ្ញាកណ្តាល ។ |
| Arbitrary | Arbitraire | សចក្តីសំរេចចិត្តណាមួយដែលធ្វើឡើងដោយអសុទ្ធចិត្ត ឬ ដោយគ្មានហេតុផលត្រឹមត្រូវ ។ |
| Arbitration | Arbitrage | មជ្ឈត្តការៈ ការផ្សះផ្សារវិវាទដោយអាជ្ញាកណ្តាល ។ |
| Arbitration agreement | Convention d'arbitrage ou compromis d'arbitrage | កិច្ចព្រមព្រៀងផ្សះផ្សារៈ ជាកិច្ចព្រមព្រៀងរវាងភាគីវិវាទ សំរេច ដោះស្រាយវិវាទ ដោយអាជ្ញាកណ្តាល ។ |
| Arbitration clause | Clause compromissoire | ប្រការស្តីពីមជ្ឈត្តការដែលមានចែងនៅក្នុងកិច្ចសន្យារបស់គូភាគី ។ ប្រការស្តីពីមជ្ឈត្តការត្រូវបានអនុញ្ញាតអោយប្រើប្រាស់នៅក្នុងច្បាប់ពាណិជ្ជកម្មដើម្បីសំរបសំរួល វិវាទកម្មដែលកើតមាននៅក្នុងពាណិជ្ជកម្ម ។ |
| Arbitrator | Arbitre | អាជ្ញាកណ្តាល ដែលមានលក្ខណៈជាចៅក្រមឯកជនជ្រើសរើស ដោយគូវិវាទ អោយធ្វើការដោះស្រាយវិវាទ ។ |
| Argument | Argument | សេចក្តីសំអាងដែលអាចធ្វើអោយគេជឿបាន ។ |
| Articles | Clauses, articles | ខ នៅក្នុងច្បាប់ កិច្ចសន្យា ឬក្នុងលក្ខន្តិកៈក្រុមហ៊ុន ។ |
| Articles of association | Statuts | កិច្ចសន្យាក្រុមហ៊ុន ឬ លក្ខន្តិកៈក្រុមហ៊ុន : ជាលិខិតបង្កើតក្រុមហ៊ុនដែលនៅក្នុងនោះមានចែងពីលក្ខខណ្ឌ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| | | សំខាន់ៗ និងចាំបាច់ដូចជាកម្មវត្ថុរបស់ក្រុមហ៊ុន និង លក្ខខ័ណ្ឌនានា ដែលអាចអោយក្រុមហ៊ុន ដំណើរការបាន ។ |
| Articles of incorporation | Acte constitutif d'une société | ឯកសារបង្កើតក្រុមហ៊ុន, លក្ខន្តិកៈក្រុមហ៊ុន ។ |
| Artisan | Artisan | សិប្បករ ឬ ជាម្ចាស់សិប្បកម្ម ដែលមានកម្មករ មិនមែនជា សមាជិកគ្រួសារចំនួនមិនលើសពី ៧ នាក់ (ច្បាប់ការងារកម្ពុជា) ។ |
| Ascent | Ascendance | ញាតិ បុព្វជន ជីដូន ជីតា ។ |
| Assembly | Assemblée | សន្និបាត, អង្គប្រជុំរួមរបស់សមាជិកភាគហ៊ុនរបស់ក្រុមហ៊ុន ។ ជាទូទៅសន្និបាតជាការប្រជុំប្រចាំឆ្នាំរបស់ម្ចាស់ភាគហ៊ុន ។ |
| Assert | Revendiquer, Affirmer | ទាមទារ, ពោលអះអាង ។ |
| Assertion | Revendication | សំដីអះអាង ។ |
| Assets | Actif, biens | ទ្រព្យសម្បត្តិ, ទ្រព្យសកម្មរបស់ក្រុមហ៊ុន ។ |
| Assign | Déléguer | ប្រគល់សិទ្ធិអោយទៅអ្នកណាម្នាក់ ។ |
| Assignee | Cessionnaire | អ្នកទទួលផល ឬ អ្នកទទួលសិទ្ធិ ។ |
| Assignment | Transfert, Cession | ការធ្វើអនុប្បទានសិទ្ធិ, ការផ្ទេរសិទ្ធិ ។ |
| Assignor | Cédant | អ្នកប្រគល់សិទ្ធិទៅអោយជនណាម្នាក់ ។ |
| Association | Association | សមាគម (ឬ សំដៅលើក្រុមហ៊ុនក៏បាន) ។ |
| Assumpsit | Engagement | ការសន្យា, ទទួលអនុវត្ត ។ |
| Attachment | Saisie arrêt | បញ្ជារបស់តុលាការ អោយរឹបអូសទ្រព្យសម្បត្តិរបស់ជនណាម្នាក់ មកដាក់ក្រោមការឃុំគ្រងតាមផ្លូវច្បាប់ ជាទូទៅទុក សំរាប់សងបំណុលដល់ដើមបណ្តឹង ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Attempt | Tentative | ការប៉ុនប៉ងប្រព្រឹត្តបទល្មើស។ |
| Attest | Attester | បញ្ជាក់អ្វីមួយថាពិត។ |
| Auction | Enchère | ការលក់ដេញថ្លៃ ។ |
| Audit | Verifier; apurer | ផ្ទៀងផ្ទាត់, ធ្វើអោយបានត្រឹមត្រូវ (គណនី)។ |
| Auditor | Commissaire aux comptes | សវនករៈ ជារូបវ័នបុគ្គល ឬ នីតិបុគ្គលដែលច្បាប់ទទួលស្គាល់ អោយធ្វើការត្រួតពិនិត្យគណនេយ្យរបស់ក្រុមហ៊ុនសំរាប់ផ្ដល់ពតិមានដល់ម្ចាស់ហ៊ុន និងអ្នកដឹកនាំក្រុមហ៊ុនពីស្ថានភាពហិរញ្ញ វត្ថុរបស់ក្រុមហ៊ុន ។ |
| Authentic | Authentique | ពិតប្រាកដ, ត្រឹមត្រូវតាមច្បាប់។ |
| Authentic act | Acte authentique | លិខិតយថាភូតៈ លិខិតយថាភូត ជាលិខិតធ្វើឡើងដោយ សារការី ឬមន្ត្រីសាធារណៈ មានលក្ខណៈច្បាប់គ្រប់គ្រាន់ ដោយមានចុះហត្ថលេខាទាំងមន្ត្រីសាធារណៈ និងគូភាគី ជាប់កិច្ចសន្យា (សូមអានពាក្យ Private deed) ។ |
| Authentication | Légalisation | ការបញ្ជាក់ជាផ្លូវការលើឯកសារសាធារណៈ ដើម្បីអាចអោយយកទៅប្រើប្រាស់បានតាមផ្លូវច្បាប់ ។ |
| Avoidance | Resiliation, Annulation | មោឃៈភាព។ |
| Award | Sentence | សេចក្ដីសំរេចរបស់អាជ្ញាកណ្ដាល ឬ របស់តុលាការ ។ |
| Ayant cause | Ayant cause | ជនដែលគេប្រគល់សិទ្ធិអោយកាន់កាប់ ឬទទួលផលតាមរយៈ មតិកសាសន៍-កិច្ចសន្យាលក់ដូរ-ផ្ដល់ជាអំណោយ ។ល។ |

# B

| ENGLISH | FRENCH | KHMER |
|---|---|---|
| Bad debt | Créance irrecouvrable | បំណុលដែលមិនអាចទារយកមកវិញបាន។ |
| Bad faith | Mauvaise foi | អសុទ្ធចិត្ត។ |
| Badge of fraude | Signe de fraude | សញ្ញានៃការបោកបន្លំ : បាតុភាពនៅជុំវិញកិច្ចការជំនួយ ដែលបញ្ជាក់ថាអាចមានការបោកបន្លំ ដូចជាការធ្វើជំនួញ ខុសពីធម្មតា  ការផ្ទេរទ្រព្យសម្បត្តិធ្វើឡើងជាសំងាត់ មុនការអនុវត្តសាលក្រម ឬការសងបំណុលមុនកាលកំណត់។ ល។ |
| Balance of payments | Balance des paiements | ជញ្ជីងទូទាត់ជាផលសងរវាងចំណូលចំណាយរបស់ប្រជាជាតិមួយជាមួយពិភពលោក។ |
| Bankrupt | Failli | អ្នកក្ស័យធន។ |
| Bankruptcy | Faillite | ធនក្ស័យៈ ស្ថានភាពដែលពាណិជ្ជករ ឬ ក្រុមហ៊ុនលែងមានលទ្ធភាពសងបំណុល ហើយបិទទ្វារតាមសេចក្តីសម្រេចរបស់តុលាការ។ |
| Bar association | Ordre des avocats | គណៈមេធាវី។ |
| Bargain sale | Vente au rabais; Soldé | លក់ចុះថ្លៃ។ |
| Basic capital | Capital initial | ដើមទុនដំបូងរបស់ក្រុមហ៊ុន ឬ របស់អាជីវករនៅពេលចាប់ផ្តើមធ្វើអាជីវកម្ម ។ |
| Bear | Porter | កាន់កាប់ (មូលប័ត្រ ឬផលប័ត្រ)។ |
| Bearer | Porteur | គាហកៈ, អ្នកកាន់។<br>**ឧទាហរណ៍:** នៅលើមូលប្បទានប័ត្រម្ចាស់គណនីបានចារ ថា"ចំណាយអោយដល់" អ្នកកាន់មូលប្បទានប័ត្រនេះ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Bigamy | Bigamie | ប្រព័ន្ធច្បាប់ដែលអនុញ្ញាតអោយមានប្តី ឬ ប្រពន្ធពីរក្នុងពេលតែមួយ ។ |
| Bilateral agreement | Accord bilatéral | កិច្ចព្រមព្រៀងទ្វេភាគី ។ |
| Bilateral contract | Contrat synallagmatique | កិច្ចសន្យាបង្កើតឡើងដោយ ២ភាគី ដែលក្នុងនោះគូភាគីបានធ្វើការសន្យាទៅវិញទៅមក ។ (កិច្ចសន្យាទ្វេភាគី) ។ |
| Bill of exchage | Lettre de change ou Traite | លិខិតបញ្ជាអោយកូនបំណុលសងប្រាក់តាមកាលកំណត់ទៅអោយជនណាម្នាក់ ឬ អ្នកកាន់លិខិត (រូបិយាណត្តិ) ។ |
| Bill of lading | Connaissement | ឯកសារដែលជាភស្តុតាងនៃការទទួលទំនិញដោយមេបញ្ជាការនាវា ហើយដែលត្រូវដឹកជញ្ជូនតាមកិច្ចសន្យា ។ |
| Blank endorsement | Endossement en blanc | បដិលេខទុកចន្លោះ, ចំណារទុកចន្លោះ ។ និយាយដល់ម្ចាស់ផលប័ត្រឬមូលប្បទានប័ត្រ ចុះហត្ថលេខាលើខ្នងផលប័ត្រ ប៉ុន្តែមិនបញ្ជាក់ឈ្មោះអ្នកដែលត្រូវទទួលផលប័ត្រនោះទេ ។ |
| Blood relation | Lien de parenté | ចំណងញាតិសារលោហិត ។ |
| Bona fide possessor | Possesseur de bonne foi | ជនដែលមិនដឹងពីអត្ថិភាពនៃសិទ្ធិរបស់តតីយជនលើទ្រព្យសម្បត្តិដែលខ្លួនកំពង់កាន់កាប់ ។ |
| Bona fide purchaser | Acheteur de bonne foi | អ្នកទិញដោយសុទ្ធចិត្ត, តាមច្បាប់ពាណិជ្ជកម្ម គឺអ្នកដែលទិញ ទំនិញអ្វីមួយដោយសុទ្ធចិត្ត ហើយបង់តម្លៃត្រឹមត្រូវដោយមិនដឹងថាទំនិញដែលទិញនោះមានគេទាមទារឡើយ ។ |
| Bond | Obligation | សញ្ញាប័ណ្ណៈ ជាបណ្ណ័បំណុលដែលបោះផ្សាយដោយក្រុមហ៊ុន មហាជនទទួលខុសត្រូវមានកំរិតក្នុងគោលបំណងលក់ដើម្បី បង្កើនដើមទុនរបស់ក្រុមហ៊ុន ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Branch office | Succursale | សាខា: ផ្នែកមួយនៃអាជីវកម្មដែលស្ថិត នៅទីកន្លែងផ្សេងពីទីស្នាក់ការដើម ។ |
| Breach of the law | Violation de la loi | ការរំលោភច្បាប់ ។ |
| Broker | Courtier | គួកជេរ, ជើងសារ, ជនដែលនាំអោយភាគីផ្សេងៗ ធ្វើកិច្ចសន្យា ជាមួយគ្នា ឬ ទិញ លក់ជាមួយគ្នាដើម្បីបានកំរៃ ។ សូមអានពាក្យ Commission) ។ |
| Burden of proof | Charge de la preuve | បន្ទុកនៃភស្តុតាង: នៅក្នុងការប្តឹង អ្នកប្តឹងត្រូវបង្ហាញភស្តុ តាងដែលមានលក្ខណៈគ្រប់គ្រាន់ នឹងសមស្របដើម្បីគាំទ្របណ្តឹងនោះ ។ |
| Business assets | Fonds de commerce | មូលនិធិពាណិជ្ជកម្ម: ទ្រព្យសម្បត្តិជាចលនទ្រព្យរបស់ក្រុមហ៊ុនដែលជាទ្រព្យរូបីយ និងអរូបីយ ហើយដែលពាណិជ្ជករ ឬក្រុមហ៊ុនយកមកប្រើប្រាស់សំរាប់ការធ្វើអាជីវកម្មរបស់ខ្លួន។ មូលនិធិពាណិជ្ជកម្មមានជាអាទិ៍:<br>- ទ្រព្យអរូបីយ: នាមករណ៍-និមិត្តសញ្ញា-អតិថិតា-កម្មសិទ្ធិបញ្ញា-----<br>- ទ្រព្យរូបីយ: សំភារៈ- ទព្វសំភារៈ- ទំនិញ----- |
| Business management | Gestion de l'entreprise | ការគ្រប់គ្រងសហគ្រាស។ |
| By Laws | Règlement intérieur | បទបញ្ជាផ្ទៃក្នុងមានគោលដៅកំណត់បែបបទរធ្វើការរបស់ក្រុមហ៊ុនឬស្ថាប័នមួយ ។ |
| By mutual consent | d'un commun accord | ការព្រមព្រៀងរួម ។ |

# C

| ENGLISH | FRENCH | KHMER |
| --- | --- | --- |
| C&F (Cost and Freight) | Coût and Frêt | លក្ខខណ្ឌ C&F ដូច CIF ដែរ ប៉ុន្តែអ្នកលក់មិនមានកាតព្វកិច្ចបង់ថ្លៃធានារ៉ាប់រងទំនិញទេ ។ សូមអានពាក្យ CIF ） ។ |
| Cancellation | Annullation: | ការលុបចោល ។ |
| Cancellation clause | Clause de résiliation | ខ បញ្ញត្តិនៅក្នុងកិច្ចសន្យាមួយដែលបើកផ្លូវអោយភាគីផ្សេងៗរំលត់កាតព្វកិច្ចរបស់ខ្លួនដែលមានក្នុងកិច្ចសន្យានោះ ។ |
| Capital | Capitaux de la société | ដើមទុន ឬ មូលធនរបស់ក្រុមហ៊ុនទាំងអស់រួមមានភាគទុនជាប្រាក់ និងជាវត្ថុ ។ |
| Capital outflow | Fuite de capitaux | លំហូរចេញនូវមូលធន គោលដៅយកទៅវិនិយោគនៅក្រៅប្រទេស ។ |
| Capital stocks | Capital actions | ភាគហ៊ុនដែលបង្កើតជាដើមទុននៅក្នុងអាជីវកម្ម ។ |
| Cartel | Cartel; entente | កិច្ចព្រមព្រៀងរវាងក្រុមហ៊ុនពីរ ឬច្រើនក្នុងគោលបំណង បែងចែកទីផ្សារគ្នាសំរាប់លក់ផលិតផល ដូចគ្នាឬកំណត់ថ្លៃលក់ផលិតផលដូចគ្នា ដើម្បីបង្កើនប្រាក់ចំណេញរៀងៗខ្លួន ។ អំពើទាំងនេះ ជាអំពើកំហិតការប្រកួតប្រជែង ។ អំពើកំហិតការប្រកួតប្រជែង ត្រូវបានហាមឃាត់ដោយច្បាប់នៅក្នុងប្រពន្ធ័សេដ្ឋកិច្ចទីផ្សារ ។ ប៉ុន្តែការកំហិតការប្រកួតប្រជែងខ្លះត្រូវបាន អនុញ្ញាតិដូចជាកិច្ចព្រមព្រៀងផ្តល់សិទ្ធផ្តាច់មុខលើការចែកចាយផលិតផលជាដើម ។ |
| Case | Cas; procès | ករណី, រឿងក្តី ។ |
| Case of force majeure | Cas de force majeure | ករណីប្រធានសក្តិៈ ព្រឹត្តិការណ៍កើតឡើងដោយចៃដន្យ ហើយមិនអាចទប់ទល់បាន ដែលធ្វើអោយភា |

| ENGLISH | FRENCH | KHMER |
|---|---|---|
| | | គឺជាប់កិច្ចសន្យាមិនអាចអនុវត្តកាតព្វកិច្ចបានដូចជា គ្រោះធម្មជាតិ វិធានការរបស់អាជ្ញាធរជាដើម ។ |
| Cash sale | Vente au comptant | លក់យកលុយដល់ដៃ។ |
| Casting vote | Voix prépondérante | សម្លេងឧត្តមានុភាពៈ ក្នុងការបោះឆ្នោតមួយនៅពេល ដែលមានសម្លេងគាំទ្រស្មើគ្នា គេអោយសម្លេងខាង ប្រធានឈ្នះ។ ករណីនេះហៅថាសម្លេងខាងប្រធាន មានឧត្តមានុភាព ។ |
| Cease | Cesser | ឈប់, អស់សិទ្ធិ ។ |
| Confidential | Confidentiel | ជាការសម្ងាត់ ។ |
| Certificate of deposit | Certificat de dépôt | លិខិតទទួលស្គាល់ដោយធនាគារ នូវការទទួលប្រាក់ បញ្ញើទុកក្នុងធនាគារ ។ |
| Certificate of registration | Certificat d'enregistrement | ១- វិញ្ញាបនប័ត្រនៃការចុះបញ្ជីពាណិជ្ជកម្មនៅពេល បង្កើតក្រុមហ៊ុនអាចហៅថា certificate of incorporation ក៏បាន ។<br>២- វិញ្ញាបនប័ត្រនៃការចុះបញ្ជីម៉ាក។ វិញ្ញាបនប័ត្រនេះ ទទួលស្គាល់ការប្រើប្រាស់ម៉ាក នឹងទទួលស្គាល់ ការ ការពារម៉ាកដែលបានចុះបញ្ជី ។ |
| Certified check | Chèque certifié | មូលប្បទានប័ត្រដែលមានចារបញ្ជាក់ពីធនាគារថា ម្ចាស់មូលប្បទានប័ត្រនេះ មានប្រាក់គ្រប់គ្រាន់នៅក្នុង ធនាគារ ដើម្បីរ៉ាប់រងការចំណាយបាន ។ |
| Certified copy | Copie certifiée conforme | សេចក្តីចំលងលិខិតដែលមានបញ្ជាក់យថាភាព (ភាព ស្របច្បាប់) ដោយអាជ្ញាធរមានសមត្ថកិច្ច ឬដោយ មន្ត្រីតុលាការ។ |
| Cessation | Cessation | ការបញ្ឈប់, ការលែងអនុវត្ត កាតព្វកិច្ច) ។ |
| Challenge | Récusation | ការប្រឆាំងជំទាស់ ។<br>**ឧទាហរណ៍:** ជំទាស់ទៅនឹង សមាសភាព តុលាការ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Chamber of Commerce | Chambre de commerce | សភាពាណិជ្ជកម្មៈ ជាស្ថាប័នសាធារណៈ ប្រមូលផ្តុំអាជីវករ គ្រប់ប្រភេទអាជីវកម្ម ក្នុងគោលបំណងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ច្បាប់ស្តីពីសភាពាណិជ្ជកម្មអនុញ្ញាតិអោយមានសភាពាណិជ្ជកម្មនៅតាមខេត្តក្រុងនិមួយៗ ។ |
| Characteristic relative | Caractère relatif (Titres) | លក្ខណៈដែលអាចផ្ទេរបាន ឬ ផ្លាស់ប្តូរបាន បើនិយាយពី ភាគហ៊ុន ឬ មូលប័ត្រ (សូមមើលពាក្យ Absolute) ។ |
| Check | Chèque | មូលប្បទានប័ត្រ បណ្ណ័សំរាប់បើកប្រាក់ពីធនាគាររបស់ម្ចាស់គណនី ។ |
| CIF (Cost Insurance and Freight) | Coût, Asurance, Frêt | នៅក្នុងកិច្ចសន្យាទិញ-លក់ លក្ខខណ្ឌ CIF តំរូវអោយ អ្នកលក់ប្រគល់ ទំនិញនៅ កំពង់ផែអ្នកទិញ ដូចនេះ អ្នកលក់ ត្រូវទទួលខុស ត្រូវលើការដឹកជញ្ជូនតាមនាវា ទាំងតំលៃដឹក ទាំងការធានារ៉ាប់រងលើការខូចខាត់ ។ |
| Citation | Citation (en justice) | ដីកាបង្គាប់អោយចូលខ្លួន ។ |
| Civil law | Droit civil | ច្បាប់រដ្ឋប្បវេណីៈ ច្បាប់ដែលមិនទាក់ទងដល់រឿងព្រហ្មទណ្ឌ ។ |
| Civil Law | Droit Romain | ប្រពន្ធ័ច្បាប់ រ៉ូម៉ាំងដែលកំពុងប្រើនៅទ្វីបអឺរ៉ុប ។ |
| Civil rights | Droit civique | សិទ្ធិពលរដ្ឋ ។ |
| Claim | Revendication | ការទាមទារ, បណ្តឹងទាមទារ ។ |
| Class of shares | Catégorie d'actions | ប្រភេទនៃភាគហ៊ុន ។<br>**ឧទាហរណ៏ៈ** ភាគហ៊ុនមានសិទ្ធិបោះឆ្នោត ឬ មិនមានសិទ្ធិបោះឆ្នោត ។ |
| Clause | Clause, Article | មាត្រា ឬ ប្រការ នៅក្នុងច្បាប់ឬកិច្ចសន្យាផ្សេងៗ ។ |
| Clerk | Greffier | ក្រឡាបញ្ជី ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Coercion | Coercition, Contrainte | ការដាក់កំហិត រួមទាំងស្របច្បាប់នឹងមិនស្របច្បាប់ ។ |
| Cohabitation | Concubinage | ការរួមរស់ជាប្តីប្រពន្ធ ក្រៅអាពាហ៍ពិពាហ៍ ។ |
| Collateral | Nantissement | ប្រាតិភោគ ឬទ្រព្យធានា ដែលកូនបំណុលផ្តល់អោយ<br>ទៅម្ចាស់បំណុល ជាថ្នូរនឹងការអនុវត្តន៍កាតព្វកិច្ចសង<br>បំណុលរបស់ខ្លួន ។ ប្រាតិភោគអាចជាចលនវត្ថុ<br>អចលនវត្ថុ ជាវត្ថុរូបិយ ឬអរូបិយ ។ |
| Collection right | Droit de recouvrement | សិទ្ធិទារប្រាក់ដែលជំពាក់ ។ |
| Collective mark | Marque collective | ម៉ាកសមូហភាពៈ ជាម៉ាកមួយដែលប្រើប្រាស់ ដោយ<br>សហគ្រាសច្រើន ប៉ុន្តែស្ថិតនៅក្រោមការគ្រប់គ្រង<br>របស់សហគ្រាសមួយ ជាម្ចាស់ម៉ាកដែលបានចុះបញ្ជី ។ |
| Collusion | Collusion | ការឃុបឃិតគ្នាដើម្បីបោកប្រាសជនណាម្នាក់ ។ |
| Commercial arbitration | Arbitrage commercial | មជ្ឈត្តការផ្នែកពាណិជ្ជកម្ម, ការផ្សះផ្សាវិវាទផ្នែក<br>ពាណិជ្ជកម្ម ។ |
| Commercial court | Tribunal de commerce | តុលាការពាណិជ្ជកម្មៈ ជាប្រភេទតុលាការជំនាញ<br>សំរាប់កាត់ក្តីរឿង វិវាទពាណិជ្ជកម្ម ។ |
| Commercial law | Droit commercial | ច្បាប់ពាណិជ្ជកម្មៈ ជាច្បាប់សំរាប់គ្រប់គ្រងរាល់<br>សកម្មភាពអាជីវកម្ម ។ |
| Commercial register | Registre du commerce | បញ្ជីពាណិជ្ជកម្មៈ ជាបញ្ជីសំរាប់ចុះឈ្មោះអាជីវករ និង<br>ក្រុមហ៊ុន, បញ្ជីនេះតំកល់ទុកនៅក្រសួងពាណិជ្ជកម្ម ។ |
| Commingle | Mélanger | ច្របល់ចូលគ្នា ៈ ដាក់វត្ថុផ្សេងៗច្របល់ចូលគ្នារហូត<br>ដល់ វត្ថុទាំងនោះ លែងមានអត្តសញ្ញាណដាច់ពីគ្នា<br>ទៀត ។ វិធាននេះមាន ចែងក្នុងច្បាប់ប្រតិបត្តិការ<br>មានកិច្ចធានា ។<br>**ឧទាហរណ៍ៈ** ស្ករ និង ម្សៅមីច្របល់ចូលគ្នាយកទៅ<br>ចំអិនក្លាយជានំ ដែលមានសមាសធាតុរួមរបស់ស្ករ និង<br>ម្សៅមី ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Commission | Commission | កំរៃជើងសារ, ជាកំរៃ ដែលភ្នាក់ងារទិញ លក់ ឬ ភ្នាក់ងារដទៃ ទៀតត្រូវបានទទួល ។ |
| Common Law | Droit des pays Anglo-saxon | ប្រព័ន្ធច្បាប់មានប្រភពពីប្រទេសអង់គ្លេស ។ ប្រព័ន្ធច្បាប់នេះ ផ្អែកលើការសំរេចរបស់តុលាការ ។ |
| Company | Société | ក្រុមហ៊ុន : ជាកិច្ចសន្យារវាងបុគ្គល 02 នាក់ ឬ ច្រើន ដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិនិងចំណេះដឹងដើម្បីប្រកប ពាណិជ្ជកិច្ចរួមគ្នាក្នុងគោលបំណងរកប្រាក់ចំណេញចែកគ្នា ។ យោងតាមមាត្រានៃច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្ម នៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនអាចមានទម្រង់ជា ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន ។ |
| Company per chare | Société de capitaux | ក្រុមហ៊ុនមូលធន : ជាក្រុមហ៊ុនដែលបង្កើតឡើងដោយសារដើមទុនរបស់ម្ចាស់ហ៊ុន ។ ក្នុងនោះភាគហ៊ុននិមួយៗ អាចជួញដូរបាន ។ ក្រុមហ៊ុនមូលធនមានទ្រង់ទ្រាយជា ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត Private Limited Company និង ក្រុមហ៊ុនមហាជនទទួលខុស ត្រូវមានកំរិត Public Limited Company ។ |
| Compensate | Compenser, indemniser | សងប៉ះប៉ូវការខូចខាត ។ |
| Compensation | Dédommagement | ការសងចំពោះការខាតបង់ ។ |
| Compensatory damages | Dommages-intérêts | សំណងចំពោះការខាតបង់ជាក់ស្តែង ។ |
| Competence | Compétence | សមត្ថកិច្ចស្របច្បាប់ ។ |
| Competition | Concurrence | ការប្រកួតប្រជែង: ជាយន្តការសេដ្ឋកិច្ច ដែលកំណត់អោយ សហគ្រាសផ្សេងៗ ប្រជែងគ្នា ផ្តល់ផលិតផល ឬសេវា ដែលដូចគ្នាដល់អតិថិជន ក្នុងគោលបំណងដណ្តើម អតិថិជន ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Competitor | Concurrent | អ្នកប្រកួតប្រជែង ។ |
| Complainant | Plaignant; Demandeur | ដើមចោទ ។ |
| Complaint | Plainte | ពាក្យបណ្តឹង |
| Compliance | Conformité | ការប្រព្រឹត្តស្របតាមច្បាប់ ។ |
| Compromise | Compromis | ការព្រមព្រៀងរវាងភាគីជម្លោះ ផ្តល់ការទុកចិត្តអោយអាជ្ញាកណ្តាលណាម្នាក់ដោះស្រាយជម្លោះ ។ |
| Conceale | Dissimuler | លាក់បាំងនូវអ្វីដែលត្រូវបញ្ចេញអោយគេដឹង។ គឺជាអំពើមិនស្មោះត្រង់ចំពោះភាគីនៃកិច្ចសន្យា ។ |
| Concession | Concession | ការធ្វើសម្បទានៈ សកម្មភាពដែលមាន លក្ខណៈគតិយុត្តិ ដែលបុគ្គលម្នាក់យល់ព្រមប្រគល់សិទ្ធិ ឬការកាន់កាប់ ទៅឱ្យបុគ្គលម្នាក់ទៀត។ |
| Conciliation | Conciliation | ការផ្សះផ្សារ, ការដោះស្រាយជម្លោះតាមការព្រមព្រៀងគ្នា ។ |
| Condemnation | Condamnation | ការដាក់ទោស, ការដាក់ទណ្ឌកម្ម ។ |
| Condition | Condition | លក្ខ័ខណ្ឌ ។ |
| Condition of payment | Mode de paiement | បែបបទទូទាត់ ។<br>បែបបទទូទាត់មានច្រើនប្រភេទដូចជា :<br>- ទូទាត់តាមការបង្វិលប្រាក់តាមធនាគារ<br>- ទូទាត់ជាសាច់ប្រាក់<br>- ទូទាត់តាមមូលប្បទានប័ត្រ ឬ តាមរូបិយាណត្តិ។ ល។ |
| Condition precedent | Condition suspensive | លក្ខខណ្ឌមុនបំពេញកាតព្វកិច្ចក្នុងកិច្ចសន្យា ។ ជាលក្ខខណ្ឌដែល យោងដល់ព្រឹត្តិការណ៍ណាមួយដែលកំណត់ថាគូភាគីមិនជាប់កាតព្វកិច្ចទេ ប្រសិនបើព្រឹត្តិការណ៍នោះមិនបានកើតឡើងទេ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| | | ផ្ទុយគ្នាពី Condition subsequent:<br>**ឧទាហរណ៏:** ភាគី "ក" បានសន្យាថានឹងលក់ផ្ទះ អោយភាគី "ខ" តាមតម្លៃដែលបានឯកភាពគ្នា ប្រសិនបើភាគី "ក" បានច្បាប់ទៅរស់នៅឯបរទេស ។ ដូចនេះ ប្រសិនបើ ភាគី "ក" មិនបានច្បាប់ទៅ រស់នៅបរទេសទេ គាត់ពុំចាំបាច់លក់ផ្ទះអោយ ភាគី "ខ" ទេ ។ |
| Condition subsequent | Condition résolutoire | លក្ខខណ្ឌសំរាប់រំលាយកិច្ចសន្យា ។ ជាទូទៅ ជាលក្ខខណ្ឌ ដែលយោងដល់ព្រឹត្តិការណ៏ខាងមុខនីមិនច្បាស់លាស់ ដែលកំណត់ថាគូរភាគីនៃកិច្ចសន្យាមិនជាប់កាតព្វកិច្ចទេ ប្រសិនបើព្រឹត្តិការណ៏នោះកើតមានឡើង ។ |
| Conditional | Conditionnel | ដោយមានលក្ខខណ្ឌ ។ |
| Conditional payment | Paiement sous réserve | សំណងមានលក្ខខណ្ឌ ។ |
| Conditional promise | Promesse sous réserve | ការសន្យាមានលក្ខខណ្ឌ  តាមច្បាប់កិច្ចសន្យាគឺការអនុវត្តកិច្ចសន្យាដោយឈរលើលក្ខខណ្ឌ ។ |
| Confession | Confession | ចម្លើយសារភាព ។ |
| Confidence | Confiance | ទំនុកទុកចិត្ត, ការទុកចិត្ត ។ |
| Confidentiality | Secret professionnel | ការសមាត់ក្នុងវិជ្ជាជីវៈ, ជាការសម្ងាត់របស់ក្រុមហ៊ុន ឬរបស់ស្ថាប័នដែល មិនត្រូវផ្សព្វផ្សាយ ។ |
| Confirmation by the court | Homologation judiciaire | ការទទួលស្គាល់ នឹងយល់ព្រមពីតុលាការដើម្បីឱ្យមានការ អនុវត្តសេចក្ដីសម្រេចណាមួយក្លាយជាកាតព្វកិច្ច។<br>**ឧទាហរណ៏:** ម្ចាស់បំណុលគ្មានការធានាសម្រេចឱ្យកូនបំណុលពន្យាការសងបំណុលមួយរយៈ។ សេចក្ដីសម្រេចនេះត្រូវសុំ ការយល់ព្រមពីតុលាការទើបការពន្យាពេលនេះត្រូវអនុវត្តជា កាតព្វកិច្ចលើគ្រប់ម្ចាស់ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| | | បំណុល ទាំងម្ចាស់បំណុលគ្មានការ ធានាទាំងម្ចាស់បំណុលមានទ្រព្យធានា ។ |
| Confidential | Confidentiel | ជាការសម្ងាត់ ។ |
| Confiscate | Confisquer | ដកហូត ឬ រឹបអូសទ្រព្យសម្បត្តិពីម្ចាស់ ដោយគ្មានការផ្តល់ សំណង់ទូទាត់ ។ |
| Confiscation | Confiscation | ការរឹបអូស ឬ ដកហូតទ្រព្យសម្បត្តិពីម្ចាស់ ដោយគ្មានការផ្តល់សំណងទូទាត់ ។ |
| Conflict of interest: | Conflit d'intérêts: | ទំនាស់ផលប្រយោជន៍ រវាងផលប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ផ្ទាល់ ខ្លួនរបស់មន្ត្រីសាធារណៈ កើតឡើងនៅពេលបំពេញភារកិច្ចជាផ្លូវការ ។ |
| Conflict of law | Conflit de la loi | ទំនាស់កើតឡើងចេញពីភាពផ្ទុយគ្នានៃច្បាប់ ។ ក្នុងស្ថានភាព ដែលមានភាពផ្ទុយគ្នា នៃច្បាប់មានចំណងទាក់ទងដល់ប្រទេសផ្សេង ឬប្រពន្ធ័ច្បាប់ផ្សេងគេត្រូវដោះស្រាយដោយកំណត់យកច្បាប់ណាមួយសំរាប់អនុវត្ត ។ |
| Conflicting evidence | Témoignage contradictoire | ភស្តុតាងផ្ទុយគ្នា ។ ភស្តុតាងដែលផ្តល់ដោយដើមចោទ និងចុងចោទ មានភាពផ្ទុយគ្នា ។ |
| Confrontation | Confrontation | ការជួបផ្ទាល់មុខគ្នាដើម្បីជជីកសួរវវាងចុងចោទ និង ដើមចោទ ។ |
| Confusion | Confusion | ច្រឡូកច្រឡំគ្នា ។ |
| Consensus | Consensus, Accord de l'unanimité | ការព្រមព្រៀងជាឯកច្ឆ័ន្ទ ដោយពុំចាំបាច់មានការបោះឆ្នោត ។ |
| Consent | Consentement | ការព្រមព្រៀង ។ |
| Consideration | Contrepartie | តម្លៃតបស្នង ឬ ថ្នូរ ដែលផ្តល់អោយសំរាប់ការអនុវត្តការសន្យាមួយ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Consignee | Consignataire | អ្នកទទួលទំនិញទុកលក់ |
| Consignment | Consignation | ការផ្ញើទំនិញអោយទុកលក់ ក្នុងករណីនេះ អ្នកម្ចាស់ទំនិញប្រគល់ទៅអោយជនណាម្នាក់ទុកលក់ ហើយម្ចាស់ទំនិញអាចទទួលបានប្រាក់ពីការលក់នោះ នៅពេលអ្នកលក់ទំនិញនោះ លក់ទំនិញរួច ។ |
| Consignor | Consignateur | អ្នកផ្ញើទំនិញអោយលក់ ។ |
| Consolidation | Fusion-création | ការរំលាយក្រុមហ៊ុនបញ្ចូលគ្នារួចបង្កើតជាក្រុមហ៊ុនថ្មីមួយសូមអានពាក្យ Merger ។ |
| Conspiracy | Conspiration | ការសមគំនិតគ្នា ដើម្បីប្រព្រឹត្តអំពើខុសច្បាប់ ។ |
| Constitution | Constitution | ច្បាប់រដ្ឋធម្មនុញ្ញ, ច្បាប់គ្រឹះរបស់ប្រទេសជាតិ ។ |
| Consumer goods | Biens de consommation | គ្រឿងឧបភោគ បរិភោគ ។ |
| Contest | Contester | ជំទាស់ ។ |
| Contingent contract | Contrat conditionnel | កិច្ចសន្យាមានលក្ខខណ្ឌ: ជាកិច្ចសន្យាដែលការអនុវត្តចំណុះ ទៅនឹងព្រឹត្តិការណ៍ណាមួយដែលអាចកើតឡើង ឬមិនកើតឡើង កិច្ចសន្យាប្រភេទនេះត្រូវបានអនុវត្តប្រសិនបើលក្ខខណ្ឌ ដែលបានកំណត់ពិតជាកើតឡើងទៅតាមរយៈពេលកំណត់ ។ |
| Contraband | Contrebande | អំពើរត់ពន្ធ ។ |
| Contract | Contrat | កិច្ចសន្យា: គឺជាការព្រមព្រៀងគ្នារវាងគូរភាគីដើម្បីបង្កើតឡើងនូវកាតព្វកិច្ចឬការផ្ទេរសិទ្ធផ្សេងៗ ។ |
| Contract of guarantee | Contrat de cautionnement | កិច្ចសន្យាធ្វើការធានា ។ ក្នុងកិច្ចសន្យានេះ បុគ្គលម្នាក់ដែល ជាអ្នកធានាសន្យាទទួលសងបំណុលជំនួសកូនបំណុលនៅពេល ដែលកូនបំណុលនោះពុំមានលទ្ធភាពសងបំណុលទៅអោយ ម្ចាស់បំណុលតាមការកំណត់ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Contract of partnership | Contrat de société | កិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ ។ |
| Contracting parties | Parties contractantes | ភាគីជាប់កិច្ចសន្យា, បុគ្គលដែលបានចុះហត្ថលេខាលើកិច្ចសន្យា ។ |
| Contractual | Contratuel | តាមកិច្ចសន្យា ។ |
| Contradiction | Contredit | ការប្រឆាំងជំទាស់ របស់បុគ្គលម្នាក់ទៅនឹងសេចក្តីសំរេចណាមួយ ។ |
| Contravention | Contravention, Infraction | ការរំលោភលើបទបញ្ញត្តិ ឬ ច្បាប់ផ្សេងៗ ។ |
| Contribution | Apport | ភាគទុនៈចំណែកទុនដែលសមាជិកម្នាក់ៗត្រូវបង់ចូលក្នុងក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិតជាសាច់ប្រាក់ជាវត្ថុ ឬ ជាចំណេះដឹង។ |
| Contribution in cash | Apport en numeraire | ភាគទុនជាសាច់ប្រាក់ ។ |
| Contribution in kind | Apport en nature | ភាគទុនជាវត្ថុ ។ |
| Contribution of knowledge | Apport en industrie | ភាគទុនជាចំណេះដឹង ។ |
| Controversy | Différend | វិវាទកម្ម, ជម្លោះ ។ |
| Convene | Convoquer une reunion | កោះប្រជុំ ។ |
| Convention | Convenance | ការព្រមព្រៀងគ្នា។ |
| Convertible | Convertible | ដែលអាចផ្ទេរប្តូរបាន (រូបិយប័ណ្ណ)។ |
| Convertible bond | Obligation convertible en action | សញ្ញាប័ណ្ណដែលអនុញ្ញាតអោយផ្លាស់ប្តូរទៅជាភាគហ៊ុនបាន ។ |
| Corporation law | Droit des sociétés | ច្បាប់សហគ្រាសពាណិជ្ជកម្ម: ច្បាប់នេះកំណត់ពីការបង្កើតសហគ្រាស-ការគ្រប់គ្រង-ការប្រព្រឹត្តទៅ និងការរំលាយ សហគ្រាស ។ |
| Correction | Rectification | ការកែសំរួលឡើងវិញ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Cost | Frais | សោហ៊ុយចំណាយ ។ |
| Costomer | Clientèle | អតិថិតា, អតិថិជនទាំងអស់ ។ |
| Counterfeit | Contrefaçon | ក្លែងបន្លំ ធ្វើត្រាប់តាមក្នុងគោលបំណងបន្លំ ។ យោងតាម ច្បាប់ស្តីពីម៉ាក គឺការលួចធ្វើត្រាប់តាម មុខទំនិញ ឬ ម៉ាកទំនិញ ដែលម្ចាស់ម៉ាកនោះបានចុះ បញ្ជីការពាររួចហើយ ។ |
| Course of business | Marche des affaires | ដំណើរការរបស់ក្រុមហ៊ុន ។ |
| Course of exchange | Cours de change | អត្រាប្តូរប្រាក់ ។ |
| Court martial | Tribunal militaire | តុលាការសឹក ។ |
| Court of appeal | Cour d'appel | សាលាឧទ្ធរណ៍ ។ |
| Credit | Crédit | ឥណទាន, ប្រាក់ដែលអោយខ្ចី ។ |
| Credit sale | Vente à crédit | លក់ជឿ, លក់កាត់ខែ ឬ សងប្រាក់បណ្តើរៗ ។ |
| Creditor | Créancier | ឥណទាយក, ម្ចាស់បំណុល ។ |
| Crime: | Crime | បទល្មើសព្រហ្មទណ្ឌ ។ |
| Criminal code | Code pénal | ក្រមព្រហ្មទណ្ឌ ។ |
| Criminal | Criminel | ឧក្រិដ្ឋជន ។ |
| Culprit | Accusé | ជនជាប់ចោទ ។ |
| Cumulative | Cumulatif | លក្ខណៈត្រួតគ្នា, ប្រការដែលជនម្នាក់ប្រមូលធ្វើ ឬ រ៉ាប់រងសកម្មភាពយ៉ាងច្រើនមកលើខ្លួន ។ |
| Custody | Garde | ការថែរក្សា។ បើនិយាយពីទ្រព្យ គឺលក្ខខណ្ឌនៃការកាន់កាប់ ការថែទាំនឹងការគ្រប់គ្រងទ្រព្យនោះរបស់ជនណាម្នាក់ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Custom clearance | Dedouanement | ការធ្វើបែបបទគយដើម្បីយកទំនិញ ។ |
| Customary | Habituel | ជាទម្លាប់ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|

# D

| | | |
|---|---|---|
| De facto | De facto, de fait | តាមហេតុការណ៍ពិត ។ |
| Debenture | Titre d'obligation | សញ្ញាប័ណ្ណ និង លិខិតបញ្ជាក់បំណុលផ្សេងៗរបស់ក្រុមហ៊ុន ។ |
| Debt | Dette | បំណុល ។ |
| Debtor | Débiteur | កូនបំណុល |
| Deceit | Dol | កាយវិការបោកបន្លំមិនស្មោះត្រង់ ។ កលឧបាយក្នុងគោលបំណងធ្វើឱ្យភាគីមួយយល់ច្រឡំ ហើយទទួលយល់ព្រម ។ នៅក្នុងកិច្ចសន្យាមួយប្រសិនបើរកឃើញកំហុសបែបនេះកិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈ ។ |
| Declaration | Déclaration | ប្រតិវេទន៍: តាមច្បាប់ពាណិជ្ជកម្មគឺជាសំណុំពត៌មានដែលត្រូវផ្តល់នៅពេលចុះបញ្ជីពាណិជ្ជកម្ម ដើម្បីតំកល់ទុក ។ ពត៌មានទាំង នោះមានៈអត្តសញ្ញាណរបស់ពាណិជ្ជករ-កម្មវត្ថុអាជីវកម្ម សេចក្តីបញ្ជាក់ប្រកាសថាគ្មានទោសពៃ-ទីតាំងអាជីវកម្ម ។ល ។ |
| Defamation | Diffamation | ការបរិហារកេរ្តិ៍, ការផ្សព្វផ្សាយដែលធ្វើអោយខូចខាតដល់កេរ្តិ៍ឈ្មោះអ្នកដទៃ ។ |
| Default | Défaillance | ការខកខានមិនបានបំពេញករណីយកិច្ចស្របច្បាប់ ។ |
| Defect | Vice | គុណវិបត្តិ, ភាពមិនពេញលក្ខណៈ ។ |
| Defective goods | Marchandise defectueuse | ទំនិញអន់គុណភាព មិនប្រាកដថាអាចយកទៅប្រើប្រាស់បាន ។ |
| Defendant | Défenseur; accusé | ចុងចោទ ។ |
| Deficiency | Insuffisance | ការខ្វះចន្លោះ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Defraud | Escroquer | ឆបោក, ធ្វើអោយជនម្នាក់អស់ទ្រព្យសម្បត្តិ តាមរយៈការឆបោក ។ |
| Delegate | Déléguer | ផ្ទេរអំណាចឱ្យ, ផ្ទេរសិទ្ធិឱ្យធ្វើជាតំណាង ។ |
| Deliberate | Délibérer | ពិភាក្សាបង្កើតសេចក្តីសំរេច, ធ្វើសេចក្តីសំរេច ។ |
| Deliberation | Délibération | ការពិភាក្សាដើម្បីធ្វើសេចក្តីសំរេច ។ |
| Delict | Délit | បទល្មើសដែលបង្កការខូចខាត ។ |
| Delivery | Livraison | ការប្រគល់ទំនិញ ។ |
| Demonstration | Manifestation | បាតុកម្ម ។ |
| Demonstrator | Manifestant | បាតុករ ។ |
| Denaturalization | Dénaturalisation | ការដកសញ្ជាតិពីជនណាម្នាក់ ដែលបានចូលសញ្ជាតិរួចមកហើយ ។ |
| Denial | Dénégation | ការប្រកែក, ការបដិសេធនូវសំអាងនានារបស់ភាគីម្ខាងទៀត ។ |
| Denial of justice | Déni de justice | ការបដិសេធមិនព្រមជំនុំជំរះរឿងក្តីណាមួយ ពីសំណាក់តុលាការ ដោយសំអាងថាមិនត្រឹមត្រូវតាមសមត្ថកិច្ច ឬដោយលក្ខខ័ណ្ឌ មិនគ្រប់គ្រាន់ ។ |
| Deny | Démentir | ប្រកែក, បដិសេធ ។ |
| Deponent | Témoin | សាក្សី, អ្នកផ្តល់សក្ខីកម្ម ។ |
| Derogation | Dérogation | បដិប្បញ្ញត្តិៈអំពើបញ្ចៀសការអនុវត្ត បទបញ្ញត្តិនៅក្នុងករណី ពិសេស ។<br>**ឧទាហរណ៍ ៖** ក្នុងការនាំសំលៀកបំពាក់ទៅកាន់ទីផ្សារសហគមន៍អ៊ឺរ៉ុប សហគមន៍អ៊ឺរ៉ុបបានធ្វើបទបញ្ញត្តិពិសេសអោយដល់ប្រទេសកម្ពុជានិង ប្រទេសឡាវ ដើម្បីបញ្ចៀសប្រទេសទាំង២ មិនអោយ អនុវត្តទាំង |

| ENGLISH | FRENCH | KHMER |
|---|---|---|
| | | ស្រុងនូវបទបញ្ញត្តិទូទៅ ស្តីពីការនាំសំលៀកបំពាក់ទៅកាន់សហ គមន៍អ៊ឺរ៉ុបដោយប្រទេស ទាំង ២ មិនទាន់មានលក្ខណៈគ្រប់គ្រាន់សំរាប់អនុវត្ត បទបញ្ញាតិទូទៅនៅឡើយ ។ |
| Descent | Descendance | ញាតិបច្ឆាជន កូន-ចៅ ។ |
| Detention | Détention | ការឃុំខ្លួនជនណាម្នាក់តាមការចោទប្រកាន់ថាបានប្រព្រឹត្តិបទល្មើស ។ |
| Detriment | Détriment | ការខាត់បង់ប្រយោជន៏ ។ |
| Devise | Legs | អំណោយជាទ្រព្យសម្បត្តិផ្តល់អោយតាមរយៈមតិកសាសន៏ ។ |
| Devisee | Héritier testamentaire | ជនដែលទទួលទ្រព្យសម្បត្តិតាមរយៈមតិកសាសន៏ ។ |
| Devisor | Testateur | អ្នកផ្តល់ទ្រព្យសម្បត្តិដល់អ្នកដទៃតាមរយៈមតិកសាសន៏ (ជាទូទៅមុនពេលស្លាប់) ។ |
| Direct suffrage | Suffrage direct | ការបោះឆ្នោតដោយផ្ទាល់ : ជារបៀបបោះឆ្នោតដែលអ្នកមានសិទ្ធិបោះឆ្នោតត្រូវទៅបោះដោយផ្ទាល់ខ្លួនតែម្តង មិនតាម រយៈតំណាង ។ |
| Director | Administrateur, Gérant | អភិបាល, បណ្ណាធិការ ។ នៅក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត យើងហៅថា បណ្ណាធិការក៏បាន ប៉ុន្តែនៅក្នុង ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិតត្រូវហៅថាអភិបាល ឬ សមាជិកក្រុមប្រឹក្សាភិបាល ។ |
| Director of Companies | Fonctionnaire du Département du Ministère du Commerce | មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម : ជាមន្ត្រីនៃនាយកដ្ឋាននីតិកម្មរបស់ក្រសួងពាណិជ្ជកម្ម ដែលត្រូវទទួលអនុវត្តការងារនៃច្បាប់នេះ ។ |
| Disaffirm | Refuser | បដិសេធលែងទទួលស្គាល់, បដិសេធ ។ |
| Disbursement | Frais | សោហ៊ុយចំណាយ ។ |

| ENGLISH | FRENCH | KHMER |
| --- | --- | --- |
| Discharge | Décharger | ដោះបំណុល, រំលោះបំណុល, ដោះកាតព្វកិច្ច ។ |
| Disclaim | Rejeter, renoncer | បដិសេធ ។ |
| Disclaimer | Renonciation | ការបោះបង់ការទាមទារ ។ |
| Disclosure | Révélation | ការប្រាប់អោយដឹងពីបញ្ហាអ្វីមួយ ឬ ពីអាថិកំបាំងអ្វីមួយ ។ |
| Discretion | Discrétion | កាតព្វកិច្ចរបស់មន្ត្រីសាធារណៈដើម្បីរក្សាការសម្ងាត់ ។ |
| Discretionary power | Pouvoir discretionnaire | អំណាចឆន្ទានុសិទ្ធិៈ ជាអំណាចរបស់តុលាការ ឬរបស់ជនណាម្នាក់ ក្នុងការសំរេចបញ្ហាប្រកបដោយសេរីភាពពេញលេញ ។ |
| Discrimination | Discrimination | ការរើសអើង (ពូជសាសន៍-ភេទ-សាសនា ។ល។) |
| Dismiss | Renvoyer, Rejeter | បញ្ជូនត្រឡប់ទៅវិញ, បដិសេធ ។ |
| Dissent | Désaccord | ការជំទាស់មិនយល់ព្រម ។ |
| Dissenting creditor | Creancier dissident | ម្ចាស់បំណុលភាគតិច ដែលមិនស្របតាមភាគច្រើន ។ |
| Dissolution | Dissolution | ការរំលាយចោល ឧទាហរណ៍ៈ ការរំលាយក្រុមហ៊ុន ។ |
| Distrain | Saisir | រឹបអូស ។ |
| Distress | Saisie | ការរឹបអូសក្នុងករណីគ្មានលទ្ធភាពទូទាត់ ។ |
| Distribute | Distribuer; Vendre | លក់ទំនិញ, ចែកចាយទំនិញ ។ |
| Distributor | Distributeur | អ្នកបែងចែកទំនិញសំរាប់លក់ ។ |
| Divest | Dessaisir | លះបង់ចោល ។ |
| Divide | Diviser; répartir | បែងចែកឧទាហរណ៍ : ក្រុមហ៊ុនបែងចែកប្រាក់ចំណេញ ដល់សមាជិកភាគហ៊ុន ។ |
| Dividend | Dividende | ភាគលាភ : ជាផលកំរៃបានមកពីការធ្វើអាជីវកម្មហើយ ដែលត្រូវយកទៅចែកចាយអោយម្ចាស់ហ៊ុន ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Divorce | Divorce | ការលែងលះគ្នា ។ |
| Domain | Domaine | អចលនទ្រព្យដែលមានម្ចាស់កម្មសិទ្ធិ ។ |
| Domicile | Domicile | លំនៅដ្ឋានអចិន្ត្រៃយ៍ ។ |
| Donee | Donataire | អ្នកទទួលអំណោយ ។ |
| Donor | Donateur | ម្ចាស់អំណោយ ។ |
| Dowry | Dot | អំណោយជូនទៅខាងស្រីនៅពេលរៀបការ ។ |
| Draft law | Projet de loi | សេចក្តីព្រាងច្បាប់ ។ |
| Draft | Lettre de change, Traite | រូបិយាណត្តិ ( សូមអានពាក្យ Bill of exchange ) ។ |
| Drawee | Tiré | ជនដែលរូបិយាណត្តិអោយចំណាយទឹកប្រាក់សង ។ |
| Drawer | Tireur | ជនដែលចេញរូបិយាណត្តិ ។ |
| Due | Dû | ប្រាក់ជំពាក់ដែលត្រូវសង ។ |
| Dumping | Dumping | ការលក់ខាត, ការលក់ទំនិញនៅទីផ្សារបរទេសថោកជាងតម្លៃទីផ្សារក្នុងស្រុក ។ |
| Duress | Contrainte | ការបង្ខិតបង្ខំទៅលើជនណាម្នាក់អោយធ្វើអ្វីមួយ ។ ក្នុងករណី បែបនេះអាចធ្វើអោយជនរងគ្រោះរួចផុតពីការទទួលខុសត្រូវ ។ |
| Duty | Obligation; Devoir | កាតព្វកិច្ច,ករណីយកិច្ច ។ |

# E

| ENGLISH | FRENCH | KHMER |
|---|---|---|
| Economic | Economie | សេដ្ឋកិច្ច ។ |
| Economic Integration | Integration Economique | សមាហរណកម្មសេដ្ឋកិច្ចៈ ការផ្ទេរអំណាចសេដ្ឋកិច្ចរបស់រដ្ឋមួយ ទៅអោយស្ថាប័នមួយដែលមានរដ្ឋនោះជាសមាជិក ធ្វើជាអ្នកចាត់ចែង ។ ឧទាហរណ៍ កម្ពុជាទទួលយកតាមការចាត់ចែង សេដ្ឋកិច្ចរបស់អាស៊ាននឹងអង្គការពាណិជ្ជកម្មពិភពលោក ក្នុងនាមជាសមាជិករបស់ស្ថាប័នទាំង ២នេះ ។ |
| Economist: | Economiste | សេដ្ឋវិទូ ។ |
| Effeciency | Efficacité | ប្រសិទ្ធិភាព ។ |
| Elaboration of a plan | Elaboration d'un plan | ការរៀបចំតាក់តែងផែនការ ។ |
| Emancipated minor | Mineur émancipé | អនិតិជនដែលរួចផុតពីអាណាព្យាបាលឪពុកម្តាយ ហើយ អាចធ្វើសកម្មភាពបានតាមច្បាប់ស៊ីវិលដូចនីតិជនដែរ ។ |
| Emancipation | Emancipation | ការរួចផុតពីអាណាព្យាបាល ។ |
| Embargo | Embargo | ការហាមឃាត់មិនអោយនាវាបរទេសចេញ ឬចូលកំពង់ផែ ។ |
| Emolument | Rémunération | កំរៃដែលបានទទួលពីពលកម្ម ។ |
| Employee | Employé; Salarié | និយោជិត, អ្នកធ្វើការយកប្រាក់ខែ ។ |
| Employer | Employeur | និយោជក, ថៅកែ, ម្ចាស់សហគ្រាស ។ |
| Employment | Emploie | មុខរបរ ។ |
| Empower | Donner pouvoir à quelqu'un | ប្រគល់សិទ្ធិអោយជនណាម្នាក់ធ្វើការងារអ្វីមួយជំនួស ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Endorsement | Endossement | ការធ្វើបង្គិលេខ : ហត្ថលេខានៅលើខ្នងលិខិត ដោយមានពាក្យ ឬគ្មានពាក្យបញ្ជាក់។ អត្ថប្រយោជន៏ នៃបង្គិលេខគឺ : ដើម្បីសំរួលដល់ការផ្ទេរលិខិតស្នាមផ្សេងៗ ។ បង្គិលេខអាចមានទម្រង់ជាបង្គិលេខពិសេស ដែលមានបញ្ជាក់ពីបុគ្គលដែល មូលប័ត្រត្រូវផ្ទេរទៅអោយ និង បង្គិលេខចំហរដែលគ្មានបញ្ជាក់ឈ្មោះបុគ្គលដែលមូលប័ត្រត្រូវផ្ទេរទៅអោយនោះទេ។ |
| Enforcement | Exécution | ការអនុវត្តន៏ច្បាប់ ។ |
| Engagement | Engagement | ការសន្យា ។ |
| Enjoyment | Jouissance | ការអាស្រ័យផល, ការទទួលសិទ្ធិ ។ |
| Enterprise | Entreprise | សហគ្រាស :  អង្គការសេដ្ឋកិច្ចដែលមានការដាក់ដើមទុនជាមធ្យោបាយបំរើការងារ ។ សហគ្រាសអាចជាសហគ្រាសឯកត្តបុគ្គល កាលណាម្ចាស់ទុនមានតែម្នាក់ឯង សហគ្រាសអាចជាក្រុមហ៊ុន កាលណាម្ចាស់ទុនមានចំនួនពីរនាក់ ឬច្រើននាក់ ។ |
| Entitle | Autoriser | អនុញ្ញាតអោយធ្វើអ្វីមួយ ។ |
| Entrepreneur | Entrepreneur | សហគ្រិន, ម្ចាស់សហគ្រាស ។ |
| Entrust | Confier | មានទំនុកចិត្តលើជនណាម្នាក់ អោយធ្វើអ្វីមួយ ។ |
| Entry into force | Entrée en vigueur | ការចូលជាធរមាន ( ច្បាប់-កិច្ចព្រមព្រៀង-កិច្ចសន្យា) ។ |
| Equal protection of law | Egalité devant la loi | ស្មើភាពចំពោះមុខច្បាប់ ។ |
| Equal | Egal | ស្មើគ្នា, ដូចគ្នា ។ |
| Equitable | Equitable | ដោយសមធម៌, ដោយសមទំនង ។ |
| Equity | Equité | សមធម៌, ភាពសមទំនង ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Estate | Patrimoine | ទ្រព្យសម្បត្តិ ។ |
| Eventual | Eventuel | មិនទាន់ច្បាស់លាស់, ជាយថាហេតុ ។ |
| Evidence | Preuve, Témoignage | ភស្តុតាង ។ |
| Exaction | Exaction | ការជំរិតទារប្រាក់ដោយមន្ត្រីសាធារណៈ ។ |
| Except | Excepter | មិនរាប់បញ្ចូល, វៀរលែងតែ, ដកចេញ ។ |
| Exclusive right | Droit exclusif | សិទ្ធផ្តាច់មុខៈ សិទ្ធកំណត់នៅក្នុងកិច្ចសន្យាដែលតាមរយៈនោះ ភាគីមួយសន្យាថាមិនចុះកិច្ចសន្យាដូចគ្នានេះជាមួយអ្នកទី៣ ឡើយ ។ |
| Executory | Exécutoire | ត្រូវអនុវត្ត, អនុវត្តមិនទាន់បានពេញលេញ ។ |
| Exequatur | Exequatur | សេចក្តីសំរេចរបស់តុលាការទទួលស្គាល់ សេចក្តីសំរេចរបស់មជ្ឈត្តករបរទេស ។ |
| Existence | Existence | អត្ថិភាព, ការមានជីវិត ។ |
| Exoneration | Exonération | ការលើកលែង ។ |
| Expiry | Expiration | ការហួសរយៈពេលកំណត់ ។ |
| Expiry date | Date d'expiration | ហួសរយៈពេលប្រើប្រាស់ ។ |
| Export | Exporter | នាំទំនិញចេញក្រៅប្រទេស ។ |
| Exportation | Exportation | ការនាំចេញ ។ |
| Exporter | Exporteur | អ្នកនាំចេញ ។ |
| Express | Formel | ត្រឹមត្រូវតាមក្បួនខ្នាត ។ |
| Express contract | Contrat formel | កិច្ចសន្យាធ្វើឡើងជាលាយលក្ខអក្សរត្រឹមត្រូវតាមក្បួនខ្នាត មានការព្រមព្រៀងជាមុនរបស់គូរភាគី លើការបំពេញភារកិច្ច ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Expropriation | Expropriation | ការដកហូតទ្រព្យសម្បត្តិ ឬសិទ្ធិតាមផ្លូវច្បាប់ ។ |
| Expulsion | Expulsion | ការបណ្តេញចេញ ។ |
| Extenuating circumstances | Circonstances atténuantes | ស្ថានភាពសម្រាលទោសៈ អង្គហេតុនៅជុំវិញបទល្មើស ដែលអាចនាំអោយមានការបន្ថយទោសបាន ។ |
| Extortion | Extortion | ការជំរិត ។ |
| Extradition | Extradition | បត្យាប័នៈ ការប្រគល់ជនជាប់ទោសពីប្រទេសមួយទៅប្រទេសមួយទៀត ។ |
| Extrajudicial | Extrajudiciaire | ក្រៅអំណាចតុលាការ ។ |
| Extraordinary session | Session extraordinaire | សម័យប្រជុំវិសាមញ្ញៈ ជាសម័យប្រជុំបន្ថែមលើសម័យប្រជុំសាមញ្ញ ។ |
| Extrinsic | Extrinsèque | ដែលមកពីក្រៅ ។ |
| Extrinsic evidence | Preuve autre que document lui-même | ភស្តុតាងក្រៅពីឯកសារផ្ទាល់ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|

# F

| | | |
|---|---|---|
| Face value | Valeur nominale | តំម្លៃចារលើប័ណ្ណភាគហ៊ុន ឬ ប័ណ្ណបំណុល ។ |
| Fact | Fait | ហេតុការណ៏, ព្រឹត្តការណ៏ ។ |
| Factor | Agent, Commissionnaire | ភ្នាក់ងារទិញលក់ ឬ បំរើសេវាយកកំរៃជើងសារ ។ |
| Fail | Manquer, Faire défaut | ខកខានមិនបានធ្វើអ្វីមួយ ។ |
| Failure | Défaut, Insuffisance | ការខ្វះចន្លោះ, ភាពមិនគ្រប់គ្រាន់ ។ |
| Fair price | Prix résonnable | ថ្លៃសមស្រប ។ |
| Fair Trade | Commerce équitable | ការធ្វើពាណិជ្ជកម្មដោយយុត្តិធម៌ និងដោយសមធម៌ ។ បច្ចុប្បន្ននេះការធ្វើពាណិជ្ជកម្មដោយយុត្តិធម៌ និងសមធម៌ត្រូវអនុវត្តតាមល័ក្ខខណ្ឌជាច្រើនជាពិសេសនៅក្នុងដំណាក់កាលផលិតទំនិញដូចជា: ការផលិតទំនិញមិនត្រូវប្រើប្រាស់ពលកម្មកុមារ មិនត្រូវប្រើប្រាស់ជី ឬថ្នាំកំចាត់សត្វល្អិតដែលមានអត្រាជាតិពុលខ្ពស់ពេកនៅក្នុងទំនិញជាចំណីអាហារ ។ល ។ |
| Fair trial | Procés équitable | ការជំនុំជំរះប្រកបដោយសមធម៌ ។ |
| Faith | Confiance | ការជឿទុកចិត្ត ។ |
| False arrest | Arrestation illégale | ការចាប់មនុស្សដោយខុសច្បាប់ ។ |
| False imprisonment | Détention non justifiée | ការដាក់ឃុំឃាំងដោយគ្មានមូលហេតុបញ្ជាក់ច្បាស់លាស់ ។ |
| False pretense | Escroquerie | ការឆបោក ។ |
| False statement | Fausse déclaration | សេចក្តីប្រកាសមិនពិត ។ |
| Falsification | Falsification | ការក្លែង (ក្លែងឯកសារ ឬហត្ថលេខា) ។ |
| Falsify | Falsifier | បន្លំ, បំភាន់, កែខ្លឹមសារលិខិត, ក្លែងហត្ថលេខា ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| File | classer, déposer | តម្កល់ឯកសារ ។ |
| Filiation | Filiation | ចំណងទាក់ទងរវាងសាច់ញាតិ ដែលភ្ជាប់ឪពុកម្តាយទៅនឹងកូន ។ |
| Filing office | Office de dépôt des avis | នៅក្នុងច្បាប់ប្រតិបត្តិការមានកិច្ចធានាសំដៅដល់ការិយាល័យតម្កល់លិខិតជូនដំណឹង ស្ថិតនៅក្នុងក្រសួងពាណិជ្ជកម្ម ។ |
| Financial institutions | Institution financière | ស្ថាប័នហិរញ្ញវត្ថុ : ជាស្ថាប័នដែលមានមុខងារប្រតិបត្តិការហិរញ្ញវត្ថុដូចជាប្រតិបត្តិការផ្តល់ហិរញ្ញប្បទាន ឬប្រតិបត្តិការជួញដូរមូលប័ត្រ ។ |
| Financial statement | Rapport financier | របាយការណ៍ហិរញ្ញវត្ថុ ។ |
| Financial year | Année budgétaire | ឆ្នាំសារពើពន្ធ ។ |
| Fine | Amende | ប្រាក់ពិន័យ ។ |
| Fixture | Immeuble par destination | ចលនវត្ថុតាំងភ្ជាប់ ។ ឧទាហរណ៍: ជណ្តើរយន្តដែលយកទៅប្រើប្រាស់នៅក្នុងអាគារមួយបានក្លាយជាផ្នែកមួយរបស់អាគារនោះ ។ |
| Flagrante delicto | Flagant délit | បទល្មើសជាក់ស្តែង, បទល្មើសដែលគេទាន់ជាក់ស្តែងនាពេល ប្រព្រឹត្ត ។ |
| FOB (Free On Board) | Franco Board | នៅក្នុងកិច្ចសន្យាទិញ-លក់ លក្ខខណ្ឌ FOB គឺជាតំលៃដែល អ្នកលក់ទទួលខុសត្រូវប្រគល់ទំនិញឡើងដល់នាវា ប៉ុន្តែមិនទទួលខុសត្រូវការខូចខាតទំនិញនៅពេលដឹកជញ្ជូនតាមនាវាទេ ហើយតំលៃដឹកជញ្ជូនតាមនាវា ជាបន្ទុករបស់អ្នកទិញ ។ |
| Forced sale: | Vente forcée: | លក់ឡាយឡុងតាមការសំរេចរបស់តុលាការ ដើម្បីយកប្រាក់សងបំណុល ។ |
| Foreclose | Saisir une hypotheque | ប្តឹងរឹបអូសយកទ្រព្យបញ្ចាំ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Foreign Business | Société étrangère | ក្រុមហ៊ុនពាណិជ្ជកម្មបរទេស : ជាក្រុមហ៊ុនដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ ហើយបានមកបោះទីតាំងធ្វើ ពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ |
| Form | Forme | ទម្រង់, ប្រភេទក្រុមហ៊ុន ដូចជាក្រុមហ៊ុនសហកម្មសិទ្ធិ ក្រុមហ៊ុនមូលធន ។ |
| Formal contract | Contrat formel | កិច្ចសន្យាធ្វើត្រឹមត្រូវតាមទម្រង់បែបបទ ។ |
| Fortuitous event | Cas fortuit | ព្រឹត្តិការណ៍ផ្ទៃក្នុងកើតមកដោយចៃដន្យ ធ្វើអោយមិនអាចអនុវត្តកាតព្វកិច្ចបាន(ខ្វះសំភារៈឬមធ្យោបាយ) ។ |
| Franchise | Franchisage | សិទ្ធិប្រើប្រាស់ម៉ាកពាណិជ្ជកម្មៈ នៅក្នុងពាណិជ្ជកម្ម សិទ្ធិនេះធ្វើ ឡើងដោយម្ចាស់ទំនិញផ្តល់ទៅអោយអ្នកផ្សេងទៀតផលិតនិង ប្រើប្រាស់ម៉ាកទំនិញរបស់ខ្លួន ។ |
| Fraud | Fraude | ការបោកបន្លំ, សកម្មភាពមិនស្មោះត្រង់ដែលធ្វើអោយខូចខាត ដល់សិទ្ធិដែលត្រូវគោរព (សិទ្ធិរបស់ម្ចាស់បំណុល) ។ |
| Fraudulent cheque | Chèque sans provision | មូលប្បទានប័ត្រដែលគ្មានប្រាក់នៅក្នុងធនាគារ ។ |
| Free competition | Libre concurrence | ការប្រកួតប្រជែងដោយសេរី នឹងយុត្តិធម៌ ឆ្លើយតបទៅនឹងក្រឹត្យក្រមស្មើ នឹង ផ្តល់ ។ |
| Free Trade | Libre échange | ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារដែលអនុញ្ញាតិអោយមានចរាចរទំនិញដោយសេរី ដោយគ្មានការកំហិតផ្សេងៗពីរដ្ឋ។ |
| Free Trade zone | Zone de libre échange | តំបន់ពាណិជ្ជកម្មសេរី បង្កើតឡើងដោយប្រទេសពីរឬច្រើនក្នុងគោលបំណងធ្វើអោយចរាចរទំនិញទៅវិញទៅមកដោយសេរី ។ ការបង្កើតតំបន់ពាណិជ្ជកម្មសេរីគឺផ្អែកទៅតាមលក្ខខណ្ឌដែលបានព្រមព្រៀងគ្នាដូចជាការទម្លាក់ពន្ធគយ ការបំបាត់ឧបសគ្គ មិនមែនពន្ធគយ ។ល។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Free Zone | Zone Franche | តំបន់រួចពន្ធគយ: ជាតំបន់សេដ្ឋកិច្ចពិសេសរបស់ប្រទេសមួយ ដែលផ្តល់អទិភាពអោយរួចពន្ធគយដល់រាល់សកម្មភាព ពាណិជ្ជកម្មចេញ និងចូលក្នុងតំបន់នោះ ។ តំបន់រួចពន្ធគយ អាចជាកំពង់ផែមួយ ទីកដីមួយជុំ ឬទីក្រុងមួយទាំងមូល ។ |
| Freight | Frais de transport | តំលៃដឹកជញ្ជូន ។ |
| Frivolous | Frivole | ដោយមានឧបាយកល, ឥតបានការ ។ |
| Fulfil | Accomplir, remplir | បំពេញកាតព្វកិច្ច, បំពេញលក្ខខណ្ឌតំរូវ ។ |
| Funds | Fonds | មូលនិធិ, ប្រាក់ ។ |

| ENGLISH | FRENCH | KHMER |
| --- | --- | --- |

# G

| | | |
| --- | --- | --- |
| Gadian | Tuteur | អ្នកអាណាព្យាបាលស្របច្បាប់ ។ |
| Gardianship | Tutelle | សិទ្ធជាអ្នកអាណាព្យាបាល ។ |
| Garnishment | Saisie-arrêt | បែបបទរឹបអូសទ្រព្យសម្បត្តិតាមផ្លូវច្បាប់ធ្វើឡើង ដោយម្ចាស់បំណុល បន្ទាប់ពីទទួលសេចក្តីសំរេចពីតុលាការថា អោយកូនបំណុលសងបំណុល ។ |
| General Assembly | Assemblée Générale | មហាសន្និបាត : ការប្រជុំរបស់ម្ចាស់ហ៊ុនជាទៀងទាត់ តាមពេលវេលាមួយ ជាទូទៅកំណត់មួយឆ្នាំហៅថា មហាសន្និបាតសាមញ្ញ ។ ក្រៅពីមហាសន្និបាតសាមញ្ញ ម្ចាស់ហ៊ុនអាចធ្វើការរួមប្រជុំបន្ថែមទៀតតាមការ ចាំបាច់ហៅថា មហាសន្និបាតវិសាមញ្ញ ។ |
| General creditor | Créancier chirographaire | ម្ចាស់បំណុលដែលកូនបំណុលគ្មានដាក់ទ្រព្យធានា ។ |
| General partner | Associé, Commandité | សហកម្មសិទ្ធិករទូទៅ ។ |
| General partnership | Société en nom collectif | ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ឬ ហៅខ្លីថាក្រុមហ៊ុន សហកម្មសិទ្ធិក៏បាន ។ ម្ចាស់ហ៊ុនដែលមានឈ្មោះ ហៅថា សហកម្ម សិទ្ធិករ ឬ សហកម្មសិទ្ធិករទូទៅ ទទួលខុសត្រូវដោយគ្មានកំរិត នូវការសងបំណុលរបស់ក្រុមហ៊ុន ។ រាល់ការសំរេចរបស់ក្រុមហ៊ុន គឺការសំរេចជាឯកច្ឆ័ន្ទរបស់ម្ចាស់ហ៊ុន ។ |
| Generalyzed system of Preferences | Système généralisé de Preferences | ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មៈ ជាប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិ ដែលប្រទេសជឿនលឿនផ្នែកសេដ្ឋកិច្ចផ្តល់ការអនុគ្រោះពន្ធ នាំចូលទំនិញដែលនាំចូលពីប្រទេសក្រីក្រ ។ ក្នុងប្រព័ន្ធនេះ ប្រទេសផ្តល់ការអនុគ្រោះពន្ធត្រូវកំណត់ពីបញ្ជីទំនិញ ដែលត្រូវទទួលការអនុគ្រោះពន្ធ និងបញ្ជីឈ្មោះប្រទេសដែលជាអ្នកទទួលការអនុគ្រោះពន្ធ ។ |

| ENGLISH | FRENCH | KHMER |
| --- | --- | --- |
| Genuine | Authentique, D'origine | យកជាការបាន, ទទួលស្គាល់ជាផ្លូវការ ។ |
| Geographical Indication | Indication géographique | ការសំគាល់ភូមិសាស្ត្រ: គឺការសំគាល់ទំនិញណាមួយពិសេសទំនិញកសិកម្ម និងម្ហូបអាហារពីផលិតផលកសិកម្ម ដែលមានប្រភព ដើមនៅប្រទេសណាមួយ ឬ តំបន់ណាមួយនៅពេល ដែលគុណភាព នឹងកិត្តិនាម-របស់ទំនិញនោះទទួលបានដោយ សារភូមិសាស្ត្រនៃប្រទេស ឬ តំបន់នោះ ( ធម្មជាតិ និង មនុស្ស )។ ការសំគាល់ភូមិសាស្ត្រ ត្រូវមានកត្តា ២ រួមគ្នា គឺ<br>១- ទំនិញ: ត្រូវមានប្រភពពីប្រទេស ឬតំបន់ណាមួយច្បាស់លាស់<br>២- គុណភាពពិសេសនឹងកិត្តិនាមផ្សារភ្ជាប់ជាមួយឈ្មោះ ប្រទេស ឬ តំបន់នោះ ។ ខុសពី Appellation of origin ការសំគាល់ ភូមិសាស្ត្រមានលក្ខណៈ អនុគ្រោះជាង លើវត្ថុធាតុដើម គឺអាចយកវត្ថុធាតុដើម ពីតំបន់ផ្សេងមកបញ្ចូលបាន ។ សូមមើលពាក្យ Appellation of origin នឹងពាក្យ Indication of source ។ |
| Gift | Don | អំណោយ ។ |
| Good faith | Bonne foi | ដោយសុទ្ធចិត្ត គ្មានបំណងបោកប្រាស់ ។ |
| Goods | Marchandise | ទំនិញ ។ |
| Grace period | Délai de grâce | រយៈពេលអនុគ្រោះបន្ថែម ដែលតុលាការអនុញ្ញាតអោយកូនបំណុល ពន្យារកាសងបំណុលដោយស្ថានភាពសេដ្ឋកិច្ចរបស់ កូនបំណុល ។ |
| Grant | Accorder, Consentir | យល់ព្រម, ផ្តល់អោយ, ធ្វើអនុប្បទានសិទ្ធិ ។ |
| Grantee | Cessionnaire | ជនដែលគេធ្វើអនុប្បទានសិទ្ធិអោយ ។ |
| Grantor | Cédant | អ្នកធ្វើអនុប្បទានសិទ្ធិ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Ground | Cause | មូលហេតុ ។ |
| Guarantor | Caution | អ្នកធានាសងបំណុលជំនួសកូនបំណុលម្នាក់ ប្រសិនបើកូនបំណុលនោះខកខានពុំបានសងដល់ម្ចាស់បំណុល ។ |
| Guaranty contract | Cautionnement | កិច្ចសន្យាធានាសងបំណុលជំនួស ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|

# H

| ENGLISH | FRENCH | KHMER |
|---|---|---|
| Harm | Prejudice | ការធ្វើអោយអន្តរាយខូចខាត ។ |
| Hearing | Audience d'un tribunal | សវនការនៅក្នុងសាលាកាត់ក្តី ។ |
| Hire | Louer | ជួលដោយមានរយៈពេលមួយកំណត់ ។ |
| Hold | Occuper de plein droit | កាន់កាប់ដោយពេញច្បាប់ ។ |
| Holder | Détenteur, Porteur | អ្នកកាន់កាប់រក្សាទុក ។ |
| Holding company | Société holding | ក្រុមហ៊ុនដែលមានគោលដៅគ្រប់គ្រងក្រុមហ៊ុននានាតាមរយៈការចូលរួមក្នុងដើមទុន ដើម្បីផលប្រយោជន៍ក្រុមហ៊ុនហូលឌីងនេះ ។ |

# I

| ENGLISH | FRENCH | KHMER |
|---|---|---|
| Identical | Identique | ដែលដូចគ្នា ( សំដៅលើទ្រង់ទ្រាយទំនិញ ឬម៉ាក ) ។ |
| Identity | Identité | អត្តសញ្ញាណ ។ |
| Identity certificate | Titre d'identité | អត្តសញ្ញាណប័ណ្ណ, ប័ណ្ណសំគាល់ខ្លួន ។ |
| Ignorance of law is no excuse | Nul n'est censé ignorer la loi | គ្មានជនណាម្នាក់ចាត់ទុកជាមិនចេះច្បាប់ឡើយ ។ ពាក្យនេះតាមផ្លូវច្បាប់បើកសិទ្ធិអោយតុលាការកាត់ទោសបានគ្រប់ករណី និងលើមនុស្សគ្រប់រូប ។ អ្នកជាប់ទោសមិនអាចសុំរួចទោសដោយទាមទារ ថាខ្លួនមិនចេះច្បាប់បានទេ ។ |
| Illegal | Illégal; Illicite | ខុសច្បាប់ ។ |
| Illegitimate | Illégitime | មិនស្របតាមច្បាប់ ។ |
| Illegitimate child | Enfant illégitime | កូនឥតខាន់ស្លា,កូនដែលកើតពីឪពុកម្តាយមិនបានរៀបការ ។ |
| Illicit | Illicite | ខុសច្បាប់ ។ |
| Illicit profit | Bénéfice illicite | ប្រាក់ចំណេញមិនស្របច្បាប់ ។ |
| Illicit trade | Commerce illicite | ការធ្វើពាណិជ្ជកម្មលើទំនិញ ឬ សេវាដែលច្បាប់ហាមឃាត់ ។ |
| Imcompetency | Incompétence | អសមត្ថភាព, ការគ្មានសមត្ថកិច្ចតាមផ្លូវច្បាប់ដើម្បីធ្វើអ្វីមួយ ។ |
| Imitation | Imitation | ការធ្វើត្រាប់តាម ។ |
| Immunity | Immunité | អភ័យឯកសិទ្ធិ, សិទ្ធិចាកផុតពីការដាក់ទោស ឬ ចាកផុតពីករណីកិច្ចដែលច្បាប់តម្រូវ ។<br>**ឧ.** អភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Impartial | Impartial | ដោយគ្មានលំអៀង ។ |
| Implied consent | Consentement implicite | ការព្រមព្រៀងដោយស្ងាត់ស្ងៀម ទោះជាមិនបានថ្លែងដោយជាក់លាក់ក្តី ។ |
| Implied contract | Quasi contrat | កិច្ចសន្យាមិនពេញលេញ មិនបានព្រមព្រៀងគ្នាជាមុន នឹងមិនបានធ្វើឡើងជាលាយលក្ខ័អក្សរ ប៉ុន្តែគូរភាគីបានអនុវត្តជាក់ស្តែង ។ |
| Import License | Licence d'importation | អាជ្ញាប័ណ្ណនាំចូល ។ |
| Importation | Importation | ការនាំចូល ។ |
| Importer | Importateur | អ្នកនាំចូល ។ |
| Impound | Confisquer, Saisir | រឹបអូស ។ |
| Impound documents | Déposer des documents | តំកល់ឯកសារ ។ |
| In cash | En numéraire | ជាសាច់ប្រាក់ ។ |
| In writing | Par écrit | ជាលាយលក្ខណ៍អក្សរ ។<br>**ឧទាហរណ៏:** កិច្ចសន្យាសរសេរជាលិខិត ។ |
| Incapacity | Incapacité | អសមត្ថភាព (ទាំងផ្លូវកាយ និង សតិបញ្ញា) ឬការបាត់បង់សិទ្ធិតាមផ្លូវច្បាប់ ។ អសមត្ថភាពតាមផ្លូវច្បាប់គឺ ស្ថានភាព ដែលគ្មានសិទ្ធិតាមផ្លូវច្បាប់ក្នុងការធ្វើអ្វីមួយ ទោះជាបុគ្គលនោះមានសមត្ថភាព និងមានលទ្ធភាពអាចធ្វើបានក៏ដោយ ។<br>**ឧទាហរណ៏:**<br>១- ច្បាប់មិនអនុញ្ញាតអោយបុគ្គលអាយុក្រោម ១៨ ឆ្នាំបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ។<br>២- ច្បាប់មិនអនុញ្ញាតអោយបុគ្គលអាយុក្រោម ១៨ ឆ្នាំ បង្កើតក្រុមហ៊ុន ។ល។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Incitement | Incitation | ការញុះញង់, ការជម្រុញជនដទៃអោយប្រព្រឹត្តបទល្មើស ។ |
| Incompatibility | Incompatibilité | វិសមិតភាព: ភាពដែលមិនអាចប្រកបកិច្ចការច្រើនក្នុងពេល តែមួយបាន ។ **ឧទាហរណ៍ :** តាមច្បាប់ កម្ពុជាសមាជិកសភា មិនអាចធ្វើជារដ្ឋមន្ត្រីក្នុងអាណត្តិ ជាមួយគ្នាបានឡើយ ។ មន្ត្រីរាជការក៏មិនអាចធ្វើជា ប្រធានក្រុមហ៊ុន ឬ ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន បានដែរ ។ |
| Incorporate a company | Constituer une société | រៀបចំបង្កើតក្រុមហ៊ុនតាមនីតិវិធីនៃបញ្ញត្តិច្បាប់ ។ |
| Incorporator | Membre fondateur d'une société | សមាជិកស្ថាបនិករបស់ក្រុមហ៊ុនៈ ជាសមាជិកដែលចេញមុខរៀបចំក្រុមហ៊ុន រហូតដល់ក្រុមហ៊ុនទទួលបាននូវនីតិបុគ្គលិកលក្ខណៈ ដូចជាសរសេរលក្ខន្តិកៈ ស្វែងរក ដើមទុននិងចុះបញ្ជីក្រុមហ៊ុន ។ល។ |
| Incorporeal | Incorporel | អរូបីយ៍, គ្មានរូប ។ |
| Incoterms | Incoterms | ពាក្យប្រើជាសញ្ញានៅក្នុងពាណិជ្ជកម្មអន្តរជាតិ បង្កើតឡើងដោយ សភាពាណិជ្ជកម្មអន្តរជាតិ ហើយដែលទទួលយល់ព្រម អនុវត្តដោយប្រទេសនានាលើសកលលោក ។ ឧទាហរណ៍ ពាក្យ Free on board (សូមអានពាក្យ FOB) ពាក្យ Cost Insurance and Freight (សូមអានពាក្យ CIF) ។ |
| Incumbent | Titulaire d'un poste | អ្នកកាន់តំណែង ។ |
| Indemnification | Indemnisation | សំណងនៃការបង់ខាត ។ |
| Indemnity | Indemnité | សំណងដល់ជនណាម្នាក់ ដើម្បីជួសជុលការខូចខាត ។ |
| Indication of source | Indication de provenance | ការសំគាល់ប្រភពទំនិញ ។ លក្ខណៈសំគាល់ប្រភពទំនិញដូចជា ការសំគាល់ភូមិសាស្ត្រនៃទំនិញដែរ ប៉ុន្តែមិនកំណត់លើ គុណភាព ពិសេសរបស់ទំនិញនោះទេ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| | | គ្រាន់តែចង់បញ្ជាក់ថា ទំនិញនោះ ផលិតក្នុងភូមិសាស្ត្រណាមួយច្បាស់លាស់ ។ ឧទាហរណ៍ Made in Cambodia ការសរសេរពាក្យ Made in Cambodia គឺគ្រាន់តែចង់បញ្ជាក់ថា ទំនិញផលិតនៅកម្ពុជា ឬកែច្នៃនៅកម្ពុជា មិនបញ្ជាក់លើគុណភាព និងលក្ខណៈពិសេស ដូចការសំគាល់ភូមិសាស្ត្រនៃទំនិញទេ។ សូមអានពាក្យ Geographical Indication ។ |
| Indispensable evidence | Preuve indispensable | ភស្តុតាងចាំបាច់ដើម្បីបញ្ជាក់ហេតុការណ៍ ។ |
| Induce | Persuader | បញ្ចុះបញ្ចូល ។ |
| Inflation | Inflation | អតិផរណា, ដំណើរទំនិញឡើងថ្លៃជាទូទៅ ។ |
| Infraction | Infraction | អំពើល្មើសច្បាប់ ។ |
| Infringement | Violation | ការរំលោភ ។ |
| Inherit | Hériter de | ទទួលស្នងមតិកពីជនដែលស្លាប់តាមអំណាចច្បាប់ ឬតាមមតិកសាសន៍ ។ |
| Inheritance | Héritage | ទ្រព្យសម្បត្តិដែលជាមតិក ។ |
| Initial Directors | Premiers administrateurs | ក្រុមប្រឹក្សាភិបាលដំបូង ៖ក្រុមប្រឹក្សាដំបូងតែងតាំងដោយលក្ខន្តិកៈឬតែងតាំងដោយមហាសន្និបាតបង្កើតក្រុមហ៊ុនហើយកាន់ដំណែង រហូតដល់មានមហាសន្និបាត ម្ចាស់ភាគហ៊ុនលើកទី ១ ។ |
| Initial notice | Avis initial | លិខិតជូនដំណឹងដំបូង ។ |
| Injunction | Injonction | បញ្ជារចេញពីតុលាការ ឬពីអាជ្ញាធរ ។ |
| Injury | Préjudice | ការខូចខាត (ទាំងកាយទាំងសំភារៈ) ។ |
| Innocent | Innocent | ដែលគ្មានពិរុទ្ធ, ដែលមិនបានប្រព្រឹត្តអាក្រក់ដោយចេតនា ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Innocent purchase | Acquisition de bonne foi | ការទទួលកម្មសិទ្ធិលើទ្រព្យសម្បត្តិដោយសុទ្ធចិត្ត ។ |
| Inoperative | Inopérant | ដែលគ្មានប្រសិទ្ធិភាព, អត់បានការ ។ |
| Insanity | Aliénation mentale | ភាពវិកលចរិត, ជម្ងឺសរសៃប្រសាទដែលជាទូទៅ អាចរួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ។ |
| Insolvency | Insolvabilite | សោធនភាព: ស្ថានភាពរបស់កូនបំណុលដែលមិនអាចធ្វើការទូទាត់បាន។ |
| Instrument | Instrument | លិខិតុបករណ៍, តាមច្បាប់ពាណិជ្ជកម្ម គឺជាឯកសារផ្លូវការជាលាយលក្ខណ៍អក្សរ ។ |
| Insurance | Assurance | ការធានារ៉ាប់រង ។ |
| Insurance company | Société d'assurance | ក្រុមហ៊ុនធានារ៉ាប់រង ។ |
| Insured | Assuré | រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទិញកិច្ចសន្យាធានារ៉ាប់រង ។ |
| Insurer | Assureur | រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលលក់កិច្ចសន្យាធានារ៉ាប់រង ។ |
| Intangible property | Bien et droit incorporels | ទ្រព្យអរូបីយ៍ ( មូលបត្រទានបត្រ រូបិយាណត្តិ ភាគហ៊ុន សញ្ញាប័ណ្ណ កម្មសិទ្ធិបញ្ញា សិទ្ធិលើអតិថិជន) ។ |
| Integration | Integration | សមាហរណកម្ម: ការរួមបញ្ចូលគ្នាអោយនៅក្រោមការចាត់ចែងតែមួយ។ |
| Intellectual property right | Droit de propriété intellectuelle | ច្បាប់កម្មសិទ្ធិបញ្ញា: ច្បាប់នេះមានបរិវិស័យសំខាន់ គឺច្បាប់ស្តីពីម៉ាក តក្កកម្ម និង សិទ្ធនិពន្ធ ។ |
| Intent | Intention | បំណង, ចេតនា ។ |
| Intent to contract | Intention de contracter | ចេតនាធ្វើកិច្ចសន្យា ។ |
| Interdiction | Interdiction | ការហាមឃាត់ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Interest | Intérêt, Avantage | ការប្រាក់, អត្ថប្រយោជន៏ សិទ្ធិ (ពាក្យសំរាប់យោងដល់សិទ្ធិណាមួយចំពោះការចាត់ចែងលើទ្រព្យសម្បត្តិ) |
| Interim measure | Mesure provisoire | វិធានការបណ្តោះអាសន្ន: ជាវិធានការរបស់តុលាការនៅក្នុងពេលបណ្តឹងវិវាទ ដើម្បីដោះស្រាយបញ្ហា ជាបន្ទាន់ចំពោះមុខ ក្នុងការរង់ចាំសេចក្តីសំរេចជាស្ថាពរ ។ ឧទាហរណ៏:<br>តុលាការបានដាក់បញ្ជាមិនអោយលក់ដូរអចលនទ្រព្យដែលជាប់វិវាទដោយដាក់ អោយនៅក្រោមការគ្រប់គ្រងរបស់អាណាព្យាបាលរហូតដល់មានសេចក្តីសំរេចជាស្ថាពរពីតុលាការ ។ |
| Intermediate product | Produit semi-fini | ផលិតផលពាក់កណ្តាលសំរេច ។ |
| International classification | Classification Internationale | ចំណាត់ថ្នាក់អន្តរជាតិទំនិញនឹងសេវា ។ ចំណាត់ថ្នាក់នេះ មានគោលដៅសំរាប់ចុះបញ្ជីម៉ាក: គឺជាបញ្ជីប្រភេទទំនិញ និងសេវាដែលក្នុងនោះមាន ៤២ ចំណាត់ថ្នាក់ (៣៤ជាចំណាត់ថ្នាក់ ទំនិញ នឹង ៨ ជាចំណាត់ថ្នាក់សេវា) នឹងមាន ១២,000យថាប្រភេទ។ បញ្ជីនេះត្រូវបានបោះពុម្ពផ្សាយដោយអង្គការកម្មសិទ្ធបញ្ញាពិភពលោក ។<br>**ឧទាហរណ៏ :**<br>- ចំណាត់ថ្នាក់ទី ១ : មានផលិតផលគីមី សំរាប់ប្រើប្រាស់ក្នុង ឧស្សាហកមក្នុងកសិកម្ម វិទ្យាសាស្ត្រ ។ល។<br>- ចំណាត់ថ្នាក់ទី ១២ : គ្រឿងភ្លេង ។<br>- ចំណាត់ថ្នាក់ទី ៣៤ :មានថ្នាំជក់ បារី ឈើគូស ។ល។ |
| International Treaty | Traité internationale | អនុសញ្ញាអន្តរជាតិ ។ ឧទាហរណ៏ : អនុសញ្ញាទីក្រុងបារីស ចុះថ្ងៃទី ២0មិនា ឆ្នាំ ១៨៨៣ ស្តីពីការការពារសិទ្ធិឧស្សាហកម្ម (ម៉ាក និង តក្កកម្ម) ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Interpretation | Interprétation | ការបកស្រាយ<br>**ឧទាហរណ៍:** ការបកស្រាយមាត្រា ទាំងឡាយនៃច្បាប់ ឬកិច្ចព្រមព្រៀង ។ |
| Intervention | Intervention | អន្តរាគមន៍ ។ |
| Intestate | Intestat | ស្លាប់ដោយគ្មានទុកបណ្តាំ ឬ មតិកសាសន៍ ។ |
| Intestate succession | Succession ab intestat | ការបែងចែកទ្រព្យសម្បត្តិទៅអោយទាយាទស្របតាមច្បាប់កំណត់ ក្នុងករណីគ្មានមតិកសាសន៍ ។ |
| Invalid | Invalide | ដែលមានមោឃភាព ។ |
| Inventory | Inventaire | បញ្ជីសារពើភ័ណ្ឌ ។ |
| Investigation | Enquête | ការធ្វើអង្កេត ។ |
| Investment | Investissement | ការធ្វើវិនិយោគ, ការយកលុយទៅប្រើប្រាស់ ដើម្បីទាញយកផលប្រយោជន៍មកវិញ ។ |
| Inviolable | Inviolable | មិនអាចរំលោភបាន ។ |
| Invoice | Facture | វិក័យប័ត្រ: ជាឯកសារចេញដោយអ្នកលក់ទៅឱ្យអ្នកទិញ ដែលមានបញ្ជាក់ឈ្មោះអ្នកលក់តម្លៃ បរិមាណ និងប្រភេទទំនិញ ។ |
| Ipso jure | De plein-droit | ពេញលក្ខណៈច្បាប់, មិនអាចសំរេចផ្សេងបាន ។ |
| Irregularity | Irrégularité | ភាពមិនប្រក្រតី ។ |
| Irrevocable | Irrévocable | ពុំអាចដកហូតវិញបាន ។ |
| Issuance | Emission | ការបោះផ្សាយ ។ |
| Issuance of patent | Délivrance d'un brevet d'invention | ការចេញប្រកាសនីយប័ត្រតកក្កកម្ម ។ |
| Issue | Délivrer | ចេញអោយ, ផ្តល់អោយ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|

# J

| ENGLISH | FRENCH | KHMER |
|---|---|---|
| Joint venture | Coentreprise | សហគ្រាស ២ ឬច្រើនបានធ្វើកិច្ចព្រមព្រៀងជាមួយគ្នា ដើម្បីរួមគ្នាធ្វើអាជីវកម្មលើគំរោងការសេដ្ឋកិច្ចណាមួយ ។ |
| Judge | Juge, Juger, Statuer | ១- ចៅក្រម ។<br>២- កាត់ក្តី ។ |
| Judgment | Jugement | សេចក្តីវិនិច្ឆ័យរបស់តុលាការ ។ |
| Judicial liquidation | Liquidation judiciaire | ការជំរះតាមផ្លូវតុលាការ នៅពេលមានធនក្ស័យ ។ ក្នុងករណីនេះ តុលាការបញ្ជាអោយដោះស្រាយ លក់ទ្រព្យសម្បត្តិដើម្បីយកប្រាក់សងម្ចាស់បំណុល ។ |
| Judicial proceedings | Procédure judiciare | នីតិវិធីតុលាការដែលចៅក្រមត្រូវអនុវត្តតាមក្នុងដំណើរការកាត់ក្តី ។ |
| Juridical person | Personne juridique | គតិយុត្តិបុគ្គលៈ គតិយុត្តិបុគ្គលរួមមាន រូបវ័ន្តបុគ្គល និង នីតិបុគ្គលដែលជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ។ |
| Juridicial | Juridique | គតិយុត្តិ, ទាក់ទងដល់ប្រព័ន្ធ និង របៀបប្រតិបត្តិរបស់តុលាការ ។ |
| Jurisdiction | Juridiction | យុត្តាធិការតុលាការ ,ចង្កោមសាលាកាត់ក្តីដែលមានសមត្ថកិច្ច ។ |
| Jurisprudence | Science du droit; Jurisprudence | នីតិសាស្ត្រ, វិជ្ជាផ្នែកច្បាប់, ក្នុងន័យមួយទៀត ទាំងភាសាបារាំងទាំងភាសាអង់គ្លេស គឺ ជាកម្រងសេចក្តីសំរេចរបស់តុលាការដែលអាចយកទៅកាត់ក្តីបានក្នុងរឿងក្តីណាមួយដែលដូចគ្នា ។ |
| Jurist | Juriste | អ្នកច្បាប់ ។ |
| Juror | Juré | សមាជិកគណៈវិនិច្ឆ័យ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Jury | Jury | គណៈវិនិច្ឆ័យ ។ |
| Justice | Justice | យុត្តិធម៌ ។ |
| Justifiable doubt | Doute légitime | ការសង្ស័យដែលមានមូលដ្ឋានត្រឹមត្រូវ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|

# L

| | | |
|---|---|---|
| Laissez faire | Laissez faire | ទ្រឹស្តីសេដ្ឋកិច្ច ដែលតាមទ្រឹស្តីនេះរដ្ឋាភិបាល មិនជ្រៀតជ្រែក ក្នុងការសំរេចរបស់ផ្នែកឯកជន ។ |
| Label | Etiquette | ស្លាកបិទលើទំនិញ សំរាប់សំគាល់ម៉ាកទំនិញ។ |
| Lapse | Caducité | ផុតសុពលភាព, មិនអាចប្រើប្រាស់បាន ។ |
| Law | Droit; loi | ច្បាប់ ។ |
| Lawful | Légitime | ពេញច្បាប់, ស្របច្បាប់ ។ |
| Lawsuit | Procès | រឿងក្តី, ការប្តឹងផ្តល់ ។ |
| Lawyer | Juriste | អ្នកច្បាប់, មេធាវី ។ |
| Lease | Location | កិច្ចសន្យាជួលអចលនទ្រព្យ, ការជួលអចនលទ្រព្យ ។ |
| Leasehold | Propriété louée | អចលនទ្រព្យដែលត្រូវបានកាន់កាប់ដោយកិច្ច សន្យាជួល ។ |
| Leaseholder | Locataire à bail | អ្នកជួលអចលនទ្រព្យពីអ្នកដទៃ ។ |
| Legacy | Legs | អំណោយអចលនទ្រព្យតាមរយៈមតិកសាសន ។ |
| Legal age | Majorité | អាយុពេញវ័យតាមច្បាប់ ជាអាយុដែលច្បាប់អនុញ្ញាត អោយបំពេញកាតព្វកិច្ចអ្វីមួយបាន ដូចជាធ្វើកិច្ចសន្យា-បោះឆ្នោត ។ល។ |
| Legal document | Acte authentique | លិខិតបញ្ជាក់របស់មន្ត្រីសាធារណៈសំរាប់យកទៅ ប្រើប្រាស់ជាផ្លូវការ ។ |
| Legal entity | Personne morale | នីតិបុគ្គលៈ អង្គភាពដែលមាននីតិបុគ្គលិកលក្ខណៈ។ នីតិបុគ្គលរបស់ក្រុមហ៊ុននិមួយៗ កើតឡើងនៅពេលចុះ បញ្ជីពាណិជ្ជកម្ម ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Legal Personality | Personne juridique | និតិបុគ្គលិកលក្ខណៈ : លក្ខណៈដែលមានអត្ថិភាពនៅក្រោមច្បាប់ និង មានកាតព្វកិច្ចស្របច្បាប់ដូចជាសមត្ថភាពក្នុងការប្តឹង និង ត្រូវគេប្តឹង ។ |
| Legal | Légal | ស្របតាមច្បាប់ ។ |
| Legalize | Légaliser | ធ្វើអោយស្របច្បាប់ ។ |
| Legally | Légalement | ដោយស្របច្បាប់ ។ |
| Legatee | Légataire | ជនទទួលមតិកតាមរយៈមតិកសាសន៍ ។ |
| Legator | Testateur | ជនដែលធ្វើមតិកសាសន៍មុនពេលស្លាប់ ។ |
| Legislation | Législation | នីតិកម្ម, ប្រព័ន្ធច្បាប់ ។ |
| Legitimate | Légitime | ស្របតាមច្បាប់ ។ |
| Lessee | Locataire | អ្នកជួល អ្នកកាន់កាប់អចលនទ្រព្យតាមរយៈកិច្ចសន្យាជួល ។ |
| Lessor | Bailleur | ម្ចាស់អចលនទ្រព្យដែលបានជួលអចលនទ្រព្យនោះអោយអ្នកដទៃ ។ |
| Letter head | En-Tête | សេចក្តីដែលបោះពុម្ពនៅលើក្បាលទំព័រក្រដាសសំរាប់សំគាល់ក្រុមហ៊ុន ឬ ស្ថាប័នណាមួយ ។ |
| Letter of credit | Lettre de crédit | លិខិតឥណទាន ជាលិខិតធ្វើឡើងដោយធនាគារតាមសំណូមពរ របស់អតិថិជន ដើម្បីធានាសងថ្លៃទំនិញនៅក្នុងការលក់ដូរទំនិញ ។ |
| Liabilities | Passif | ទ្រព្យអកម្ម : បំណុលរួមដែលក្រុមហ៊ុនត្រូវសង ។ |
| Liability | Responsabilité | ទទួលខុសត្រូវ ។ |
| Liable | Responsable | ភាពទទួលខុសត្រូវ ។ |
| License | Licence | អាជ្ញាប័ណ្ណ, លិខិតផ្តល់ការអនុញ្ញាតស្របច្បាប់ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| License Contract | Contrat de licence | កិច្ចសន្យាផ្តល់អាជ្ញាបណ្ណ: ជាកិច្ចសន្យាដែលម្ចាស់ម៉ាកមួយ ដែលបានចុះបញ្ជីរួចហើយផ្តល់ឱ្យជនណាម្នាក់នូវសិទ្ធិប្រើប្រាស់ ម៉ាកនោះ ។ |
| Lien | Droit de rétention | សិទ្ធិឃាត់ទុក: សិទ្ធិរបស់ម្ចាស់បំណុលលើទ្រព្យធានារហូតដល់ កូនបំណុលសងបំណុលអស់ជាស្ថាពរ ។ |
| Lien holder | Porteur de droit de rétention | អ្នកមានសិទ្ធិឃាត់ទុកទ្រព្យធានានៅពេលកូនបំណុលគ្មានលទ្ធភាពសងបំណុល ។ |
| Limited liability company | Société à responsabilité limitée: | ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត ( សូមអានពាក្យ Private limited company ) |
| Limited liability | Responsabilité limitée | ការទទួលខុសត្រូវមានកំរិត ។ នៅក្នុងក្រុមហ៊ុន គឺការកំណត់ ទឹកប្រាក់ដែលអ្នក ម្ចាស់ហ៊ុនអាចទទួលនៅពេលខាតបង់ ។ |
| Limited partner | commanditaire | សហកម្មសិទ្ធិករមានកំរិត:នៅក្នុងក្រុមហ៊ុន សហកម្មសិទ្ធិ មានកំរិត អនេរោល ផារតនរេ មានឈ្មោះជាភាសាបារាំង ហៅថា : Commandité ។ ហើយ Limited partner ហៅថា commanditaire ។ |
| Limited partnership | Société en commandite simple | ក្រុមហ៊ុនសហកម្មសិទ្ធិមានកំរិត ។ ក្នុងក្រុមហ៊ុនប្រភេទនេះម្ចាស់ភាគហ៊ុនមាន ២ ប្រភេទគឺ :<br>សហកម្មសិទ្ធិករទូទៅ និង សហកម្មសិទ្ធិករមានកំរិត ។<br>- សហកម្មសិទ្ធិករទូទៅ : មានសិទ្ធិដឹកនាំ ក្រុមហ៊ុន និង រ៉ាប់រងទទួលខុសត្រូវលើបំណុលក្រុមហ៊ុនដោយគ្មានកំរិត<br>- សហកម្មសិទ្ធិករមានកំរិត : ទទួលខុសត្រូវត្រឹមតែភាគ ទុនដែលខ្លួនបាន ដាក់ចូលក្នុងក្រុមហ៊ុនប៉ុណ្ណោះ ។ |
| Liquidation | Liquidation | ការជំរះបញ្ជី : នីតិក្រម សំដៅធ្វើការបែងចែកទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននៅពេលរំលាយក្រុមហ៊ុន ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Liquidator | Liquidateur | អ្នកជំរះបញ្ជី : បុគ្គលទទួលបន្ទុកធ្វើការងារ ជំរះបញ្ជី ។ |
| List (on stock exchange) | Coter (en bourse) | ដាក់តំលៃភាគហ៊ុន ឬ តំលៃទំនិញនៅក្នុងផ្សារហ៊ុន ។ |
| Litigant | Plaideur | គូរក្តី ។ |
| Litigation | Litige | បណ្តឹងវិវាទនៅមុខតុលាការ ។ |
| Lucrative | Lucratif | ដែលផ្តល់ប្រាក់ចំណេញ ។ |
| Loan | Prêt | ប្រាក់កំម្ចី ។ |
| Laissez faire | Laissez faire | ទ្រឹស្តីសេដ្ឋកិច្ច ដែលតាមទ្រឹស្តីនេះរដ្ឋាភិបាល មិនជ្រៀតជ្រែកក្នុងការសំរេចរបស់ផ្នែកឯកជន ។ |
| Label | Etiquette | ស្លាកបិទលើទំនិញ សំរាប់សំគាល់ម៉ាកទំនិញ ។ |
| Lapse | Caducité | ផុតសុពលភាព, មិនអាចប្រើប្រាស់បាន ។ |
| Law | Droit; loi | ច្បាប់ ។ |
| Lawful | Légitime | ពេញច្បាប់, ស្របច្បាប់ ។ |
| Lawsuit | Procès | រឿងក្តី, ការប្តឹងផ្តល់ ។ |
| Lawyer | Juriste | អ្នកច្បាប់, មេធាវី ។ |
| Lease | Location | កិច្ចសន្យាជួលអចលនទ្រព្យ, ការជួលអចនលទ្រព្យ ។ |
| Leasehold | Propriété louée | អចលនទ្រព្យដែលត្រូវបានកាន់កាប់ដោយកិច្ចសន្យាជួល ។ |
| Leaseholder | Locataire à bail | អ្នកជួលអចលនទ្រព្យពីអ្នកដទៃ ។ |
| Legacy | Legs | អំណោយអចលនទ្រព្យតាមរយៈមតិកសាសន៍ ។ |
| Legal age | Majorité | អាយុពេញវ័យតាមច្បាប់ ជាអាយុដែលច្បាប់អនុញ្ញាតអោយបំពេញកាតព្វកិច្ចអ្វីមួយបាន ដូចជាធ្វើកិច្ចសន្យា-បោះឆ្នោត ។ល។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Legal document | Acte authentique | លិខិតបញ្ជាក់របស់មន្ត្រីសាធារណៈសំរាប់យកទៅប្រើប្រាស់ជាផ្លូវការ ។ |
| Legal entity | Personne morale | នីតិបុគ្គលៈ អង្គភាពដែលមាននីតិបុគ្គលិកលក្ខណៈ ។ នីតិបុគ្គលរបស់ក្រុមហ៊ុននិមួយៗ កើតឡើងនៅពេលចុះបញ្ជីពាណិជ្ជកម្ម ។ |
| Legal Personality | Personne juridique | នីតិបុគ្គលិកលក្ខណៈ : លក្ខណៈដែលមានអត្ថិភាពនៅក្រោមច្បាប់ និង មានកាតព្វកិច្ចស្របច្បាប់ដូចជាសមត្ថភាពក្នុងការប្តឹង និង ត្រូវគេប្តឹង ។ |
| Legal | Légal | ស្របតាមច្បាប់ ។ |
| Legalize | Légaliser | ធ្វើអោយស្របច្បាប់ ។ |
| Legally | Légalemen | ដោយស្របច្បាប់ ។ |
| Legatee | Légataire | ជនទទួលមតិកតាមរយៈមតិកសាសន៍ ។ |
| Legator | Testateur | ជនដែលធ្វើមតិកសាសន៍មុនពេលស្លាប់ ។ |
| Legislation | Législation | នីតិកម្ម, ប្រព័ន្ធច្បាប់ ។ |
| Legitimate | Légitime | ស្របតាមច្បាប់ ។ |
| Lessee | Locataire | អ្នកជួល អ្នកកាន់កាប់អចលនទ្រព្យតាមរយៈកិច្ចសន្យាជួល ។ |
| Lessor | Bailleur | ម្ចាស់អចលនទ្រព្យដែលបានជួលអចលនទ្រព្យនោះអោយអ្នកដទៃ។ |
| Letter head | En-Tête | សេចក្តីដែលបោះពុម្ពនៅលើក្បាលទំព័រក្រដាសសំរាប់សំគាល់ក្រុមហ៊ុន ឬ ស្ថាប័នណាមួយ ។ |
| Letter of credit | Lettre de crédit | លិខិតឥណទាន ជាលិខិតធ្វើឡើងដោយធនាគារតាមសំណូមពរ របស់អតិថិជន ដើម្បីធានាសងថ្លៃទំនិញនៅក្នុងការលក់ដូរទំនិញ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Liabilities | Passif | ទ្រព្យអកម្ម : បំណុលរួមដែលក្រុមហ៊ុនត្រូវសង ។ |
| Liability | Responsabilité | ទទួលខុសត្រូវ ។ |
| Liable | Responsable | ភាពទទួលខុសត្រូវ ។ |
| License | Licence | អាជ្ញាប័ណ្ណ, លិខិតផ្តល់ការអនុញ្ញាតស្របច្បាប់ ។ |
| License Contract | Contrat de licence | កិច្ចសន្យាផ្តល់អាជ្ញាបណ្ណ័: ជាកិច្ចសន្យាដែលម្ចាស់ម៉ាកមួយ ដែលបានចុះបញ្ជីរួចហើយផ្តល់ឱ្យជនណាម្នាក់នូវសិទ្ធិប្រើប្រាស់ ម៉ាកនោះ ។ |
| Lien | Droit de rétention | សិទ្ធិឃាត់ទុក: សិទ្ធិរបស់ម្ចាស់បំណុលលើទ្រព្យធានារហូតដល់កូនបំណុលសងបំណុលអស់ជាស្ថាពរ ។ |
| Lien holder: | Porteur de droit de rétention | អ្នកមានសិទ្ធិឃាត់ទុកទ្រព្យធានានៅពេលកូនបំណុលគ្មានលទ្ធភាពសងបំណុល ។ |
| Limited liability company | Société à responsabilité limitée | ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត ( សូមអានពាក្យ Private limited company) |
| Limited liability | Responsabilité limitée | ការទទួលខុសត្រូវមានកំរិត ។ នៅក្នុងក្រុមហ៊ុន គឺការកំណត់ ទឹកប្រាក់ដែលអ្នកម្ចាស់ហ៊ុនអាចទទួលនៅពេលខាតបង់ ។ |
| Limited partner | commanditaire | សហកម្មសិទ្ធិករមានកំរិត:នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិ មានកំរិត អនេរោល ផារតនរេ មានឈ្មោះជាភាសាបារាំង ហៅថា : Commandité ។ ហើយ Limited partner ហៅថា commanditaire ។ |
| Limited partnership | Société en commandite limitée | ក្រុមហ៊ុនសហកម្មសិទ្ធិមានកំរិត ។ ក្នុងក្រុមហ៊ុនប្រភេទ នេះម្ចាស់ភាគហ៊ុនមាន ២ ប្រភេទគឺ : សហកម្មសិទ្ធិករទូទៅ និង សហកម្មសិទ្ធិករមានកំរិត ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| | | - សហកម្មសិទ្ធិករទូទៅ : មានសិទ្ធិដឹកនាំ ក្រុមហ៊ុន និង រ៉ាប់រងទទួលខុសត្រូវលើបំណុលក្រុមហ៊ុនដោយគ្មានកំរិត ។<br>- សហកម្មសិទ្ធិករមានកំរិត : ទទួលខុសត្រូវត្រឹមតែភាគ ទុនដែលខ្លួនបាន ដាក់ចូលក្នុងក្រុមហ៊ុនប៉ុណ្ណោះ ។ |
| Liquidation | Liquidation | ការជំរះបញ្ជី : នីតិក្រម សំដៅធ្វើការបែងចែក ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននៅពេលរំលាយក្រុមហ៊ុន ។ |
| Liquidator | Liquidateur | អ្នកជំរះបញ្ជី : បុគ្គលទទួលបន្ទុកធ្វើការងារ ជំរះបញ្ជី ។ |
| List (on stock exchange) | Coter (en bourse) | ដាក់តំលៃភាគហ៊ុន ឬ តំលៃទំនិញ នៅក្នុងផ្សារហ៊ុន ។ |
| Litigant: | Plaideur: | គូរក្តី ។ |
| Litigation: | Litige: | បណ្តឹងវិវាទនៅមុខតុលាការ ។ |
| Lucrative | Lucratif | ដែលផ្តល់ប្រាក់ចំណេញ ។ |
| Loan | Prêt | ប្រាក់កំចី ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|

# M

| | | |
|---|---|---|
| Magistracy | Magistrature | អង្គចៅក្រមទទួលភារកិច្ចកាត់ក្តី ។ |
| Magistrate | Magistrat | ចៅក្រម, មន្ត្រីបំពេញការងារផ្នែកតុលាការ ។ |
| Mailing address | Adresse postale | អាស័យដ្ឋាន ។ |
| Majority | Majorité | អាយុពេញវ័យកំណត់ដោយច្បាប់, ភាគច្រើន, សម្លេងភាគច្រើន ។ |
| Mala fide | De mauvaise foi | មិនសុទ្ធចិត្ត ។ |
| Malfeasance | Malfaisance | អំពើទុច្ចរិត ។ |
| Management | Gestion | ការគ្រប់គ្រងអាជីវកម្ម ។ |
| Manager | Gestionnaire | អ្នកគ្រប់គ្រងអាជីវកម្ម, អភិបាល ឬបណ្ណាធិការក្រុមហ៊ុន ។ |
| Mandate | Mandat | អាណត្តិ ។ |
| Mandatory of a company | Mandataire d'une société | អ្នកទទួលសិទ្ធិពីក្រុមហ៊ុន ។ |
| Manufacture | Manufacture | កម្មន្តសាលៈ អង្គភាពសេដ្ឋកិច្ចផលិតទំនិញឧស្សាហកម្ម ។ |
| Mark | Marque | ម៉ាក ជាសញ្ញាដែលមើលឃើញ សំរាប់សំគាល់ទំនិញ (ពាណិជ្ជសញ្ញា : Trade Mark) ឬសេវា (សេវាសញ្ញា : Service Mark) របស់សហគ្រាសណាមួយ ។ **ឧទាហរណ៏ៈ** CAMEL KODAK GAP |
| Market Economy | Economie de marché | សេដ្ឋកិច្ចទីផ្សារៈ នៅក្នុងសេដ្ឋកិច្ចទីផ្សារ ការលក់ដូរ ឬផលិតមិននៅក្រោមការគ្រប់គ្រងរបស់រដ្ឋទេ ហើយថ្លៃទំនិញ ស្ថិតនៅលើការស្រុះស្រួលរវាងអ្នកលក់ និងអ្នកទិញ ។ |
| Market value | Valeur vénale | តំលៃគិតជាប្រាក់របស់ទំនិញ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Marketing | Etude des marchés | ការសិក្សាពីទីផ្សារ នឹងតម្រូវការរបស់អ្នកប្រើប្រាស់ ក្នុងគោលដៅបង្កើនការលក់ដូររបស់ក្រុមហ៊ុន។ |
| Martial law | Loi martiale | ច្បាប់អាជ្ញាសឹក។ នៅពេលមានសង្គ្រាម ឬ ការបះបោរ គេបង្កើតច្បាប់អាជ្ញាសឹកដើម្បីអោយយោធាប្រើអំណាចត្រួតត្រាលើកិច្ចការទូទៅរបស់រដ្ឋ ។ |
| Material fact | Fait essentiel | ព្រឹត្តិការណ៏សំខាន់, អង្គហេតុសំខាន់។ |
| Maturity | Echéance | រយះពេលកំណត់សំរាប់ការសងបំណុល ឬ សំរាប់បំពេញកាតព្វកិច្ច។ |
| Mediation | Médiation | ការសម្រុះសម្រួលជម្លោះនៅក្រៅតុលាការ។ |
| Meeting | Réunion | ការប្រជុំ។ |
| Meeting of creditors | Réunion des créanciers | នៅក្នុងច្បាប់ធនក្ស័យ សំដៅដល់អង្គប្រជុំរបស់ម្ចាស់បំណុល ដើម្បីត្រួតពិនិត្យការចែកទ្រព្យសម្បត្តិ និង សេចក្តីសំរេចពីបញ្ហាផ្សេងៗ។ |
| Merchant | Commerçant | ពាណិជ្ជករ។ |
| Merger | Fusion | ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។ ក្នុងប្រតិបត្តិការនេះមានក្រុមហ៊ុនពីរ ឬ ច្រើនរំលាយបញ្ចូលគ្នាជាក្រុមហ៊ុនតែមួយតាមវិធី២យ៉ាង គឺ :<br>- ក្រុមហ៊ុនមួយរំលាយចូលជាមួយក្រុមហ៊ុនមួយទៀត (Absorption) សូមអានពាក្យ absorption<br>- ក្រុមហ៊ុនរំលាយចូលគ្នា រួចបង្កើតជា ក្រុមហ៊ុនថ្មីមួយ (consolidation) សូមអានពាក្យ consolidation |
| Minimum Capital | Capital Minimum | ដើមទុនអប្បបរមារ: ជាដើមទុនតិចបំផុតរបស់ក្រុមហ៊ុន ដែលកំណត់ដោយច្បាប់។ ច្បាប់ពាណិជ្ជកម្មកម្ពុជាកំណត់ទុនអប្បបរមាចំនួន ០៤ លានរៀល។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Minor | Mineur | អនីតិជន, ជនដែលមានអាយុក្រោមការកំណត់នៃច្បាប់ ដើម្បីធ្វើកាតព្វកិច្ចអ្វីមួយ ។ ប្រទេសភាគច្រើនកំណត់អាយុក្រោម ១៨ ឆ្នាំ ។ |
| Minority | Minorité | អនីតិភាព ។ |
| Minutes of meeting | Procès-verbal | កំណត់ហេតុអង្គប្រជុំ ។ |
| Misrepresentation | Declaration tendant a induire en erreur | ការថ្លែងមិនពិតក្នុងគោលបំណងធ្វើអោយមានការភាន់ច្រឡំ ។ |
| Miss | manquer | ខ្វះ ។ |
| Missing personne | Personne disparue | បុគ្គលបាត់ខ្លួន ។ |
| Misstatement | Fausse déclaration | សេចក្តីថ្លែងការណ៍ខុស ឬបន្លំ ។ |
| Mistake | Erreur | កំហុសដោយភាន់ច្រលំ ។ |
| Mitigate | Attenuer | សំរាល ។ |
| Mitigating circumstances | Circonstances atténuantes | ស្ថានសំរាលទោស,ស្ថានភាពដែលអាចបន្ថយទោសបាន ។ |
| Monogamy | Monogamie | ប្រព័ន្ធច្បាប់ដែលអនុញ្ញាតអោយមានប្តី ឬ ប្រពន្ធតែមួយក្នុងពេលតែមួយ ។ |
| Monopoly | Monopole | ភាពផ្តាច់មុខក្នុងការធ្វើអាជីវកម្ម: ជាស្ថានភាពពាណិជ្ជកម្ម ដែលនៅក្នុងនោះ ការប្រកួតប្រជែងត្រូវបានបំបាត់ដោយយន្តការនៃ ការធ្វើអាជីវកម្មដែលមានក្រុមហ៊ុនណាមួយ មានកំលាំងខ្លាំងមិនអាចអោយក្រុមហ៊ុនឯទៀតប្រជែងជាមួយបានឬដោយអន្តរាគមន៍របស់អាជ្ញាធរ ដែលអនុញ្ញាតិអោយតែក្រុមហ៊ុនណាមួយធ្វើអាជីវកម្ម ។ |
| Morality | Moralité | សីលធម៌ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Mortgage | Hypothèque | ១- អ៊ីប៉ូតែក : សិទ្ធិបង្កើតឡើងជាផលប្រយោជន៍ដល់ម្ចាស់បំណុលកាន់កាប់អចលនទ្រព្យរបស់កូនបំណុល សំរាប់ធានាដល់ការសងបំណុល ។ ក្នុងករណីអ៊ីប៉ូតែក ម្ចាស់ទ្រព្យមានសិទ្ធិគ្រប់គ្រងលើអចលនទ្រព្យរបស់ខ្លួន ។<br>២- ទ្រព្យធានាបំណុល ជាអចលនទ្រព្យ ។ |
| Mortgagee | Créancier hypothècaire | ម្ចាស់បំណុលអ៊ីប៉ូតែក ។ |
| Mortgagor | Débiteur hypothècaire | កូនបំណុលអ៊ីប៉ូតែក ។ |
| Motion | Demande | ពាក្យស្នើសុំ ។ |
| Motive | Motif | មូលហេតុ ជាសំអាង ។ |
| Movables property | Biens mobiliers | ចលនទ្រព្យ: ទ្រព្យដែលអាចដឹកជញ្ជូនបាន ។ |
| Movant | Requérant | អ្នកស្នើសុំ ។ |
| Multilateral agreement | Accord multilatéral | កិច្ចព្រមព្រៀងពហុភាគី ជាកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាទទួលស្គាល់ដោយភាគីច្រើន ។ |
| Mutual consent | Consentement mutuel | ការព្រមព្រៀងទៅវិញទៅមក ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|

# N

| ENGLISH | FRENCH | KHMER |
|---|---|---|
| Name of company | Raison sociale | នាមករណ៏ក្រុមហ៊ុន : ឈ្មោះផ្លូវការរបស់ក្រុមហ៊ុន ដែលបានចុះក្នុងបញ្ជីពាណិជ្ជកម្ម ។ |
| Natural person | Personne physique | រូបវន្តបុគ្គល, មនុស្សម្នាក់ៗ ។ |
| Naturalization | Naturalisation | សញ្ជាតូបនីយកម្ម: វិធានដែលធ្វើអោយបុគ្គលម្នាក់ ទទួលបាន សញ្ជាតិមួយផ្សេងពីសញ្ជាតិដើម ។ |
| Naturalize | Naturaliser | ចូលសញ្ជាតិ ។ |
| Negative | Négatif | អវិជ្ជមាន ។ |
| Negligence | Négligence | សេចក្តីធ្វេសប្រហែស ។ |
| Negotiable instruments | Effets de commerce | ផលប័ត្រពាណិជ្ជកម្ម: ជាលិខិតសន្យាសងប្រាក់តាម ពេលវេលាជាក់លាក់ ទៅអោយអ្នកកាន់ផលប័ត្រ ឬ ទៅអោយជនណាម្នាក់តាមបញ្ជា ។ ផលប័ត្រ ពាណិជ្ជកម្ម អាចត្រូវផ្ទេរដោយចំណារលើខ្នងប័ណ្ណ ។ ផលប័ត្រពាណិជ្ជកម្មរួមមាន :<br>- Bill of exchange លិខិតបញ្ជាសងប្រាក់ ។<br>- Promissory note លិខិតសន្យាសងប្រាក់ ។ |
| Negotiation | Négociation | ការចរចា ។ |
| Nepotism | Népotisme | គំនិតគ្រួសារនិយម និង បក្សពួកនិយមរបស់អ្នកកាន់ អំណាច ។ |
| Nicety | Précision; subtilité | ភាពម៉ត់ចត់ ច្បាស់លាស់ ។ |
| Nominate | Nommer; désigner | ចាត់តាំង ។ |
| Nonsuit order | Ordonnance de non-lieu | ដីកាលើកលែងការចោទប្រកាន់របស់ចៅក្រម បន្ទាប់ពី រកឃើញថា គ្មានមូលដ្ឋានគ្រប់គ្រាន់សំរាប់ចោទប្រកាន់ ជនជាប់ចោទ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Normal activity | Profession habituelle | មុខរបរប្រចាំថ្ងៃ។ |
| Notary public | Notaire | សារការី៖ ជាមន្ត្រីសាធារណៈដែលមានសិទ្ធិបញ្ជាក់សុពលភាព នៃឯកសារខាងផ្លូវច្បាប់ ។ |
| Notice | Avis | លិខិតជូនដំណឹង។ |
| Notice of meeting | Convocation en assemblée | លិខិតអញ្ជើញប្រជុំសន្និបាត ។ |
| Null | Nul caduc | មោឃៈ ដែលគ្មានអានុភាពតាមផ្លូវច្បាប់តទៅទៀត ។ |
| Nullity | Nullité | មោឃភាព។ |

# O

| ENGLISH | FRENCH | KHMER |
|---|---|---|
| Oath | Serment | ការស្បថ។ |
| Object | Objet | គោលបំណង, កម្មវត្ថុ។ |
| Objection | Objection | ការជំទាស់, ការមិនយល់ព្រម។ |
| Objective of the company | Objet de la société | កម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនៈ ជាមុខរបរដែលក្រុមហ៊ុនចង់ធ្វើអាជីវកម្ម ហើយដែលក្រុមហ៊ុនត្រូវបញ្ជាក់នៅក្នុងលក្ខន្តិករបស់ខ្លួន។ |
| Obligation | Obligation | កាតព្វកិច្ច ។ |
| Obligee | Obligataire | ម្ចាស់បំណុល, ឥណទាយក។ |
| Obliger | Débiteur, Obligé | អ្នកជំពាក់បំណុល អ្នកមានកាតព្វកិច្ចចំពោះជនម្នាក់ទៀត។ |
| Occur | Avoir lieu | កើតឡើង។ |
| Offender | Auteur du délit | អ្នកប្រព្រឹត្តបទល្មើស។ |
| Offense | Offense | បទល្មើស, ការប្រមាថ ដែលនាំអោយមានទោស ។ |
| Offer | Offrir, offre | ១- ជូន, ផ្តល់អោយ។<br>២-ការធ្វើសំណើលក់ ឬធ្វើកិច្ចសន្យាទិញ-លក់។ កិច្ចសន្យាទិញ-លក់ត្រូវបញ្ជាក់ពីថ្លៃទំនិញ និងលក្ខខណ្ឌ ប្រគល់-ទទួល។ |
| Offeree | Destnataire | អ្នកទទួលសំណើលក់, អ្នកទទួលទំនិញ។ |
| Offeror | Offrant | អ្នកធ្វើសំណើលក់, អ្នកប្រគល់ទំនិញ។ |
| Officer (company) | Cadre (société) | អ្នកចាត់ចែងការងារនៅក្នុងក្រុមហ៊ុន ។ |
| Official gazette | Journal officiel | រាជកិច្ច, ជាព្រឹត្តប័ត្ររបស់រាជរដ្ឋាភិបាលសំរាប់ផ្សព្វផ្សាយនូវរាល់អត្ថបទច្បាប់និងលិខិតបទដ្ឋានផ្សេងៗ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Omission | Omission | ការខកខានមិនបានធ្វើអ្វីមួយដែលជាកាតព្វកិច្ច។ |
| Opinion | Opinion | មតិ, យោបល់។ |
| Optional | Facultatif | តាមជំរើស។ |
| Oral contract | Contrat verbal | កិច្ចសន្យាផ្ទាល់មាត់ ដោយគ្មានធ្វើជាលិខិត |
| Oral statement | Déclaration verbale | សេចក្ដីថ្លែងការណ៍ផ្ទាល់មាត់ |
| Order | Ordonnance,<br>Ordre d' achat | ១- ដីការបង្គាប់របស់តុលាការ ឬរបស់អាជ្ញាធរ។<br>២- បញ្ជាទិញ។ |
| Ordinary resolution | Décision ordinaire | សេចក្ដីសំរេចសាមញ្ញ : ជាសេចក្ដីសំរេចដែលបានធ្វើឡើងដោយសម្លេងឆ្នោតភាគច្រើនលើសពី៥០% (សូមអានពាក្យ special resolution)។ |
| Ordinary session | Session ordinaire | សម័យប្រជុំសាមញ្ញ របស់ក្រុមហ៊ុន ឬរបស់ស្ថាប័នណាមួយ។ ជាសម័យប្រជុំដែលបានកំណត់ទុកជាមុននូវពេលវេលា និង ទីកន្លែង។ |
| Ordonnance | Règlement | បទបញ្ញត្តិ, បទបញ្ជា។ |
| Organization | Organisation | ការរៀបចំបង្កើត។ |
| Organize a company | Fonder une société | បង្កើតក្រុមហ៊ុន។ |
| Original | Original | គំរូដើម, សំណៅដើម។ |
| Overissue | Emission excessive | ការបោះផ្សាយហួសចំនួនដែលអនុញ្ញាត (ភាគហ៊ុន ឬ សញ្ញាប័ណ្ណ) ។ |
| Ownership | Droit de propriété | ភាពជាម្ចាស់។ |

| ENGLISH | FRENCH | KHMER |
|---|---|---|

# P

| | | |
|---|---|---|
| Paid-up stock | Action libérée | ភាគហ៊ុនដែលបានបង់គ្រប់ចំនួនជូនទៅក្រុមហ៊ុន។ |
| Par value | Valeur nominale | តម្លៃចារលើមូលប័ត្រ ឬផលប័ត្រពាណិជ្ជកម្ម។ |
| Pardon | Grâce | ការលើកលែងទោស។ |
| Parent company | Société mére | ក្រុមហ៊ុនមេ : ជាក្រុមហ៊ុនដែលមានភាគហ៊ុនលើសពី ៥០%នៅក្នុងដើមទុនក្រុមហ៊ុនមួយទៀតដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធ។ (សូមអានពាក្យ Subsidiary company) ។ |
| Parental liability | Responsabilité parentale | ការទទួលខុសត្រូវរបស់ឪពុកម្តាយ។ ក្នុងពេលដែលកូននៅជាអនីតិជន ច្បាប់កំណត់អោយឪពុកម្តាយទទួលខុសត្រូវរាល់ ទង្វើរបស់កូនខ្លួនដែលបង្កការខូចខាតដល់អ្នកដទៃ ។ |
| Paris Convention | Convention de Paris | អនុសញ្ញាទីក្រុងបារីស ជាអនុសញ្ញាស្តីពីការការពារសិទ្ធិ ឧស្សាហកម្ម ក្នុងនោះមានម៉ាកនិងប្រកាសនីយប័ត្រ តក្កកម្ម ចុះថ្ងៃទី ២០ មិនា ឆ្នាំ ១៨៨៣ ។ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន ធ្វើជាសមាជិកអនុសញ្ញាទីក្រុងបារីស នៅថ្ងៃទី ២២ កក្កដា ១៩៩៨។ |
| Participation | Participation | ការដាក់ហ៊ុនចូលរួមក្នុងដើមទុនក្រុមហ៊ុនណាមួយ ។ |
| Partner | Associé | សហកម្មសិទ្ធិករ, ម្ចាស់ភាគទុននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិ ។ |
| Partnership | Société de personnes | ក្រុមហ៊ុនសហកម្មសិទ្ធិ, ជាក្រុមហ៊ុនដែលម្ចាស់ហ៊ុនរួមគ្នាទទួលខុសត្រូវដោយគ្មានកំរិតលើបំណុលរបស់ក្រុមហ៊ុន ។ ក្រុមហ៊ុនសហកម្មសិទ្ធិ,ចែកចេញជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| | | មានកំរិត ។ សូមអានពាក្យ General partnership និង Limited partnership ។ |
| Party | Partie | ភាគី (នៅក្នុងកិច្ចព្រមព្រៀង ឬ កិច្ចសន្យា) ។ |
| Pawn | Mettre en gage | ដាក់ទ្រព្យបញ្ចាំសំរាប់ធានាការសងបំណុល ។ |
| Payee | Bénéficiaire | អ្នកទទួលសំណង ។ |
| Pecuniary | Pécuniaire | ដែលទាក់ទងដល់ប្រាក់កាស ។ |
| Penal law | Droit pénal | ច្បាប់ព្រហ្មទណ្ឌ: ច្បាប់ដែលមានគោលដៅដាក់ទណ្ឌកម្មដល់ អ្នកប្រព្រឹត្តិបទល្មើស ។ |
| Penalty | Peine | ទោស, ទណ្ឌកម្ម ។ |
| Peremptory | Péremptoire | មិនអាចប្រកែកបាន, ដាច់អហង្ការ ។ |
| Performance | Exécution | ការអនុវត្តន៍កាតព្វកិច្ច ឬ កិច្ចសន្យា ។ |
| Period of grace | Periode de grâce | រយះពេលអនុគ្រោះ: យោងតាមច្បាប់ស្តីពីម៉ាក រយះពេលអនុគ្រោះត្រូវបានកំណត់ត្រឹម៦ខែ សំរាប់អោយចុះបញ្ជីម៉ាកសារជាថ្មី នៅពេលចប់សុពលភាពវិញ្ញាបនបត្រ័ចុះបញ្ជីម៉ាក (ដែលមានរយៈពេល ១០ឆ្នាំ ) ។ |
| Perishable | Périssable | ងាយរលួយខូច ។ |
| Permit | Autorisation | ការអនុញ្ញាត ។ |
| Person | Personne | បុគ្គល : រួមបញ្ចូលទាំងរូបវ័នបុគ្គល និង នីតិបុគ្គល ។ |
| Personal warranty | Cautionnement personnel | ជាកិច្ចសន្យាដែលបុគ្គលម្នាក់ ធានាសងបំណុលទៅអោយម្ចាស់បំណុល ប្រសិនបើកូនបំណុលមិនអាចសងតាមការកំណត់ ។ |
| Pertinence | Pertinence | ភាពយកជាការបាន ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Pertinent | Pertinent | ដែលមានការជំពាក់ទាក់ទងជាមួយគ្នារវាងព្រឹត្តិការណ៍ដែលកើតឡើងនិងភស្តុតាងដែលអាចយកជាការបាន ។ |
| Petition | Requête | ពាក្យបណ្តឹង ។ |
| Pettionner | Requerant | អ្នកប្តឹង ។ |
| Physical incapacity | Incapacité physique | អសមត្ថភាពខាងផ្លូវកាយ ។ |
| Piracy | Piraterie, contrefaçon | ការលួចចម្លងស្នាដៃរបស់អ្នកផ្សេងយកទៅធ្វើអាជីវកម្ម ។ ឧទាហរណ៍: ការលួចចម្លងបទចំរៀង ឬខ្សែភាពយន្តយកទៅលក់ ។ |
| Place of delivery | Lieu de livraison | ទីកន្លែងប្រគល់ទំនិញដែលមានចែងក្នុងកិច្ចសន្យាទិញ-លក់ ។ |
| Plagiarism | Plagiat | ការលួចចម្លងស្នាដៃនិពន្ធរបស់អ្នកដទៃ ។ |
| Plaint | Plainte | ពាក្យបណ្តឹងចោទប្រកាន់ ។ |
| Plaintiff | Demandeur | ដើមចោទ, ដើមបណ្តឹង ។ |
| Planned economy | Economie planifiée | សេដ្ឋកិច្ចផែនការ: ជាទូទៅគឺសេដ្ឋកិច្ចដែលដឹកនាំដោយផែនការ ។ |
| Plea | Plaidoirie | ចម្លើយរបស់ចុងចោទ ទៅនឹងបណ្តឹងចោទប្រកាន់ ។ |
| Plead | Plaider | ជជែកតវ៉ារឿងក្តីរបស់គូរក្តី ។ |
| Pleading | Plaidoirie | សេចក្តីថ្លែងសំអាងរបស់គូរក្តី ។ |
| Pledge | gage | ១- ការបញ្ចាំ ។<br>២- ចលនវត្ថុដែលកូនបំណុលដាក់ជាទ្រព្យធានាប្រាក់ជំពាក់ ។ ម្ចាស់បំណុលមានសិទ្ធិរក្សាទុកចលនវត្ថុនេះ រហូតដល់កូនបំណុលបានសងប្រាក់ជំពាក់ ។ ក្នុងករណី ដែលកូនបំណុលពុំអាចសងបំណុលបានទេ ម្ចាស់បំណុលអាចលក់ចលនវត្ថុនោះ យកប្រាក់ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| | | ជាចំណែករបស់ខ្លួនមកវិញ ឯប្រាក់ដែលនៅសល់<br>ត្រូវប្រគល់ទៅអោយកូនបំណុល ។ |
| Polygamy | Polygamie | ប្រព័ន្ធច្បាប់ដែលអនុញ្ញាតអោយមានប្តី ឬ ប្រពន្ធច្រើន<br>ក្នុងពេលតែមួយ ។ |
| Pool | Mettre en commun | ដាក់រួម, ដាក់បញ្ចូលគ្នា ( ទ្រព្យឬដើមទុន) ។ |
| Pooling agreement | Convention régissant<br>une exploitation en commun | កិច្ចព្រមព្រៀងធ្វើអាជីវកម្មរួមគ្នា ។ |
| Possession | Possession | ការកាន់កាប់គ្រប់គ្រង ។ |
| Power of attorney | Procuration | លិខិតប្រគល់សិទ្ធិអោយធ្វើការងារអ្វីមួយជំនួស ។ |
| Pratice | Pratique | ការអនុវត្តជាទម្លាប់ ។ |
| Pre emptive right | Droit de preemption | សិទ្ធិដែលកំណត់ទុកជាមុនតាមរយៈច្បាប់ ឬ កិច្ចសន្យា<br>អោយជនណាម្នាក់មានអាទិភាពធ្វើអ្វីមួយបានមុនគេ ។<br>**ឧ.** ក្រុមហ៊ុនមូលធនមួយអនុញ្ញាតអោយ<br>បុគ្គលិករបស់ខ្លួន ឬ ម្ចាស់ភាគហ៊ុនចាស់អាចទិញ<br>ភាគហ៊ុនរបស់ក្រុមហ៊ុនមុនគេ ក្នុងករណីដែលក្រុមហ៊ុន<br>មានបោះចេញភាគហ៊ុនបន្ថែម ។ |
| Preamble | Préambule | បុព្វកថាៈ ជាសេចក្តីផ្តើមសរសេរបញ្ជាក់ពីមូលហេតុ<br>ដែលនាំអោយមានឯកសារ-សៀវភៅ ឬ ច្បាប់មួយ ។ |
| Preference | Droit de priorité | សិទ្ធិជាអាទិភាព ។ ឧទាហរណ៍ៈ នៅក្នុងការសង<br>បំណុលសិទ្ធិ អាទិភាពគឺសិទ្ធិរបស់ម្ចាស់បំណុលដែល<br>កូនបំណុលត្រូវសងមុនម្ចាស់បំណុលដទៃទៀត ។ |
| Preferential creditor | Créancier privilégié | ម្ចាស់បំណុលដែលមានសិទ្ធិជាអាទិភាព ៈ ម្ចាស់បំណុល<br>ដែលត្រូវបានទទួលសំណងមុនគេ នៅក្នុងករណីដែល<br>កូនបំណុលក្ស័យធន ។ ដើម្បីទទួលសិទ្ធិជាអាទិភាព<br>ម្ចាស់បំណុលត្រូវ តម្កល់លិខិតជូនដំណឹងពីទ្រព្យធានា<br>របស់កូនបំណុលនៅការិយាល័យតម្កល់លិខិតជូនដំណឹង |

| ENGLISH | FRENCH | KHMER |
|---|---|---|
| | | នៃក្រសួងពាណិជ្ជកម្ម ។ ចំពោះទ្រព្យធានាជាអចលនវត្ថុត្រូវចុះបញ្ជីនៅក្រសួង នគររូបនីយកម្ម ។ |
| Prejudice | Préjudice | ការបាត់បង់ផលប្រយោជន៏ - ការខូចខាត ។ |
| Prescribe | Prescrire | ដាក់បញ្ញាត្តិ ។ |
| Preliminary | Préalable | ធ្វើឡើងជាដំបូង ។ |
| Presumption of innocence | Présomption d' innocence | ការចោទប្រកាន់លើជនណាម្នាក់ដោយគ្មានភស្តុតាងបញ្ជាក់ ។ ជនជាប់ចោទត្រូវបានសន្និដ្ឋានថាគ្មានទោសរហូតដល់ការ សំរេចចុងក្រោយរបស់តុលាការ ។ |
| Presumption of law | Présomption légale | វិធីសន្និដ្ឋាន ដែលកំណត់ដោយច្បាប់ ។ |
| Prevail | Prévaloir, Prédominer | មានឧត្តមានុភាព, មានប្រៀប ។ |
| Prima facie evidence | Commencement de preuve | ភស្តុតាំងដំបូង ។ |
| Principal | Principal | ចាំបាច់, ចំបង ។ |
| Principal establishment | Etablissement principal | គ្រឹស្ថានដើម, កន្លែងធ្វើអាជីវកម្មចំបងរបស់ក្រុមហ៊ុន ។ |
| Principle | Principle | គោលការណ៏ ។ |
| Priority | Priorité | អាទិភាព ។ |
| Private | Privé | ឯកជន ។ |
| Private deed | Acte sous-sein privé | លិខិតឯកជនៈ ជាលិខិតដែលភាគីជាប់កិច្ចសន្យាសរសេរ ដោយខ្លួនឯងនិងចុះហត្ថលេខាដោយភាគីជាប់កិច្ចសន្យា |
| Private law: | Droit privé | ប្រព័ន្ធច្បាប់ដែលគ្រប់គ្រងទំនាក់ទំនងរវាងបុគ្គលឯកជន និង បុគ្គលឯកជនៈ ច្បាប់រដ្ឋប្បវេណី -ច្បាប់ពាណិជ្ជកម្ម ។ល ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Private Limited Company | Société à responsabilité limitée | ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត : ជាទ្រង់ទ្រាយ មួយនៃក្រុមហ៊ុនមូលធនមានសមាជិកចាប់ពី ២ នាក់ ដល់៣០ នាក់ ( ប៉ុន្តែបុគ្គលម្នាក់ក៏អាចបង្កើតក្រុមហ៊ុន បានដែរដែលមានឈ្មោះថាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត Single member private limited company) ។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត មិនអនុញ្ញាតអោយលក់ភាគទុនជាសាធារណៈទេ ប៉ុន្តែអាចលក់ ឬ ផ្ទេរភាគទុនបាន ប្រសិនបើមានការយល់ព្រមពីសមាជិកភាគទុនដ៏ទៃទៀត ។ |
| Privilege | Privilège | ឯកសិទ្ធិ, សិទ្ធិទទួលផលប្រយោជន៍ពិសេស ។ |
| Procédure | Procédure | នីតិវិធីៈ របៀបរបបធ្វើការងារ ឬកាត់ក្តីដែលត្រូវអនុវត្ត ។ |
| Proceeding | Procès | រឿងក្តី ។ |
| Process | Ordonnance | ដីកាបង្គាប់របស់តុលាការដើម្បីអនុវត្តអំណាចរបស់ខ្លួន ។ |
| Procuration | Procuration | លិខិតប្រគល់សិទ្ធិអោយធ្វើការងារអ្វីមួយជំនួស ។ |
| Prohibit | Prohibition | ការហាមឃាត់មិនឱ្យធ្វើអ្វីមួយ ។ |
| Promise | Promesse | ការសន្យាបំពេញកាតព្វកិច្ចរបស់បុគ្គលម្នាក់ ឬរបស់ភាគីជាប់កិច្ចសន្យា ។ |
| Promissory note | Billet a ordre | លិខិតសន្យាសងប្រាក់ ជាលិខិតដែលតាមរយៈនោះបុគ្គលម្នាក់សន្យាសងប្រាក់ តាមកាលកំណត់ទៅអោយជនម្នាក់ទៀត ដែលជាអ្នកទទួលផលឬទៅអោយជនទី៣ តាមបញ្ជាអ្នកទទួលផលនោះ ។ |
| Promoter | Fondateur | ស្ថាបនិក ឧទាហរណ៍ៈ ស្ថាបនិកក្រុមហ៊ុនជាសមាជិក ដែលបានចូលរួមបង្កើត ធ្វើលក្ខន្តិករហូតដល់ចុះបញ្ជី និងដំណើរការក្រុមហ៊ុន ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Promulgate | Promulguer | ប្រកាសអោយប្រើជាផ្លូវការ ( ច្បាប់ ឬ បទបញ្ញាត្តិ របស់រដ្ឋាភិបាល ) ។ |
| Proof | Preuve | ភស្តុតាង ។ |
| Property | Propriété | កម្មសិទ្ធិ ។ |
| Prosecutor | Procureur de la republique | ព្រះរាជអាជ្ញា ។ |
| Protest | Protestation | ការតវ៉ាប្រឆាំង ។ |
| Prove | Prouver | ធ្វើអោយឃើញការពិត, បង្ហាញតឹកតាង ។ |
| Provision | Provisions, disposition | ខ ចែងនៅក្នុងច្បាប់, បទបញ្ញត្តិ ។ |
| Provisional | Provisoire | បណ្ដោះអាសន្ន ។ |
| Provisional administrator | Administrateur Provisoire, | អភិបាលបណ្ដោះអាសន្នៈ នៅក្នុងករណីធនក្ស័យ តុលាការចាត់តាំងអភិបាលបណ្ដោះអាសន្ន ទទួលបន្ទុក តំណាងអោយម្ចាស់បំណុលទាំងអស់ ក្នុងគោលបំណង អោយគ្រប់គ្រង និង ចាត់ចែងជំរះបញ្ជីទ្រព្យសម្បត្តិ ក្រុមហ៊ុន របស់កូនបំណុល ដែលក្ស័យធន ។ |
| Provisional measure | Measure conservatoire | វិធានការបន្ទាន់ដាក់ចេញដោយតុលាការ ដើម្បីការពារ និង គ្រប់គ្រងទ្រព្យសម្បត្តិ ក្នុងការរង់ចាំសេចក្ដីសំរេច ជាស្ថាពរ ។ ឧទាហរណ៍ : តុលាការបានដាក់បញ្ជាមិន អោយលក់ទ្រព្យសម្បត្តិ ដែលមានជម្លោះរហូតដល់ មានសេចក្ដីសំរេចជា ស្ថាពរ ។ |
| Provocation | Provocation | បង្កហេតុ, ការនាំអាទិ៍ |
| Proxy | Mandataire | អាណត្តិគាហក : អ្នកទទួលអំណាចដែលគេផ្ដល់អោយ ដើម្បីជំនួសមនុស្សណាម្នាក់ទៀត ។ |
| Public law | Droit publique | ច្បាប់សាធារណៈ ជាច្បាប់ចែងពីតួនាទី និង អំណាច របស់រដ្ឋ រួមមានៈ ច្បាប់ធម្មនុញ្ញ-ច្បាប់រដ្ឋបាល ។ល។ |

| ENGLISH | FRENCH | KHMER |
| --- | --- | --- |
| Public Limited Company | Société anonyme | ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិតៈ ជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធន ដែលត្រូវបានអនុញ្ញាតអោយបោះចេញនូវមូលប័ត្រដែលអាចលក់ជាសាធារណៈបាន ។ (ឬអាចហៅថាជា ក្រុមហ៊ុនអនាមិក) ។ |
| Public notice | Affiche | ប័ណ្ណប្រកាសដែលបិទអោយសាធារណជន បានដឹងពីរឿងអ្វីមួយ ។ |
| Public order | Ordre public | សណ្តាប់ធ្នាប់សាធារណៈ ។ |
| Purchase | Achat | ការទិញ ។ |
| Purport | La teneur | សេចក្តីនៃអត្ថបទ ។ |
| Purport of a statement | La teneur d'une déclaration | ខ្លឹមសារនៃប្រតិវេទន៍ ។ |
| Purpose | But, Object | គោលបំណង, ទិសដៅ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|

# Q

| | | |
|---|---|---|
| Qualification | Qualification | ការមានគុណភាព, ការមានលក្ខណៈសម្បត្តិ ។ |
| Quality | Qualité | គុណភាពទំនិញ ឬ សេវា ។ |
| Quality goods | Marchandise de qualité | ទំនិញមានគុណភាពខ្ពស់ ។ |
| Quantitative restriction | Contingentement | ការដាក់កំហិតលើបរិមាណ ។ |
| Quantity | Quantité | បរិមាណ ។ |
| Quarantine | Quarantaine | វិធានការដាក់អោយឆ្ងាយពីមនុស្សនូវនាវាដែលមានដឹកទំនិញ ដែលយល់ថាអាចបង្កគ្រោះថ្នាក់ ឬជម្ងឺឆ្លងផ្សេងៗនៅពេលនាវានោះចូលមកកំពង់ផែក្នុងរយៈពេលកំណត់មួយ ។ |
| Quietus | Quittance | លិខិតបញ្ជាក់ថាកូនបំណុលបានសងបំណុលរួចរាល់អស់ហើយនិងបានបញ្ចប់កាតព្វកិច្ចរបស់ខ្លួន ។ |
| Quorum | Quorum | កូរ៉ុម : ចំនួនវត្តមានចាំបាច់ ដើម្បីអោយការបោះឆ្នោត, ការប្រជុំ ឬការសំរេចផ្សេងៗអាចយកជាការបាន ។ |
| Quota | Quota | កំរិតកំណត់លើបរិមាណ, កូតា ។<br>**ឧទាហរណ៍:** សហរដ្ឋអាមេរិក បានដាក់កំរិតកំណត់លើការនាំចូលសំលៀកបំពាក់ពីប្រទេស ផ្សេងៗ ។ ប្រទេសនីមួយៗ មានកូតារៀងៗខ្លួន ។ |
| Quotation | Cotation; cours | តម្លៃហាងឆេងទំនិញ ដែលកំណត់នៅក្នុងទីផ្សារហ៊ុន (Bourse) ឬ ទីផ្សារលក់ដុំ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|

# R

| | | |
|---|---|---|
| Ratification | Ratification | សច្ចាប័នៈ ការបញ្ជាក់យល់ព្រមជាផ្លូវការរបស់សភាជាតិ លើកិច្ចព្រមព្រៀងនានា ដែលចុះហត្ថលេខាដោយរដ្ឋាភិបាល ។ |
| Real estate | Bien immobilier | អចលនទ្រព្យដូចជា អាគារ-ដីធ្លី ។ |
| Real estate agent | Agent immobilier | ភ្នាក់ងារទិញលក់អចលនទ្រព្យ ឬ មូលនិធិពាណិជ្ជកម្ម |
| Real right | Droit réel | ច្បាប់ទាក់ទងផ្ទាល់ដល់ការកាន់កាប់ទ្រព្យសម្បត្តិមានជាអាទិ៍ ច្បាប់កម្មសិទ្ធិ ។ តាមរយៈច្បាប់កម្មសិទ្ធិម្ចាស់ទ្រព្យមានសិទ្ធិប្រើប្រាស់ទ្រព្យរបស់ខ្លួនមានសិទ្ធិទទួលផលពីទ្រព្យនោះ និង មានសិទ្ធិចាត់ចែងលើទ្រព្យទាំងនោះ ។ |
| Recall | Révocation | ការដកតំណែង។ |
| Receipt | Récépissé | បង្កាន់ដៃសំគាល់។ |
| Receiver | Séquestre | ជនដែលតុលាការ ឬ គូរភាគីផ្តល់ទំនុកចិត្តអោយគ្រប់គ្រងទ្រព្យសម្បត្តិរឹបអូស ឬ កំពុងមានជំលោះរហូតដល់ដោះស្រាយជំលោះជាស្ថាពរ ។ |
| Receiver manager | Sequestre gérant | អ្នកគ្រប់គ្រងទ្រព្យសម្បត្តិរឹបអូស ឬ កំពុងមានជំលោះដែលតុលាការអនុញ្ញាតអោយធ្វើអាជីវកម្មក្រុមហ៊ុនជាធម្មតា ជំនួសក្រុមប្រឹក្សាភិបាលក្រុមហ៊ុននោះ ។ |
| Reclaim | Récupérer | ទាមទារមកវិញ ។ |
| Recognition | Reconnaissance | ការទទួលស្គាល់ ឧទាហរណ៍ៈ តុលាការកម្ពុជាមានកាតព្វកិច្ចទទួលស្គាល់សេចក្តីសំរេចរបស់មជ្ឈត្តករបរទេស ។ |
| Reconciliation | Réconciliation | ការផ្សះផ្សាវិវាទ។ |
| Reconduction | Reconduction | ការបន្តកិច្ចសន្យាជាថ្មី។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Record | Dossier, Proces-verbal | សំណុំរឿងដែលបានដឹកល់ទុក, កំណត់ហេតុ។ |
| Record date | Date à laquelle il faut avoir été en possession d'une action pour toucher le dividende | កាលបរិច្ឆេទកំណត់ទុក នៅពេលកាន់កាប់ភាគហ៊ុន ដើម្បីមានសិទ្ធិទទួលភាគលាភ ។ |
| Recourse | Recours | ការសុំឧទ្ធរណ៏។ |
| Recover | Recouvrement, Récupération | ការទារសំណង, ការយកមកវិញតាមច្បាប់។ |
| Redeem | Rembourser | រំលោះមកវិញ, ដកហ៊ុនចេញពីក្រុមហ៊ុន, បង្វិលសងវិញ។ |
| Redeem a loan | Amortir un emprunt | សងរំលោះបំណុល។ |
| Redemption | Rachat | ការទិញត្រឡប់មកវិញ ។ |
| Redemption of mortgage | Dégagement | ការរំលោះយកវត្ថុបញ្ចាំមកវិញ ។ |
| Refusal | Refus , Renonciation | ប្រកែក, បដិសេធ។ |
| Refusal to register | Refus d'enregistrement | ការប្រកែកមិនព្រមចុះបញ្ជី អោយ។ |
| Regard | Considérer | ចាត់ទុក, គិតដល់ ។ |
| Register | Enregistrer, Registre | ១- ចុះបញ្ជី (ចុះឈ្មោះក្នុងបញ្ជី)។<br>២- បញ្ជី។ |
| Register of marks | Registre des marques | បញ្ជីម៉ាក: ជាបញ្ជីកាន់កាប់ដោយមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលក្នុងនោះមានចុះម៉ាកទំនិញ នឹងសេវា ។ |
| Registra | Fonctionraire enregistreur | មន្ត្រីចុះបញ្ជី<br>១- មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដែលមានភារៈកិច្ចចុះបញ្ជី និង |

| ENGLISH | FRENCH | KHMER |
|---|---|---|
| | | លុបឈ្មោះ ពាណិជ្ជករ និងក្រុមហ៊ុនពីបញ្ជីពាណិជ្ជកម្ម។<br>២- មន្ត្រីក្រសួងពាណិជ្ជកម្មមានភារៈកិច្ចពិនិត្យសំណើសុំចុះបញ្ជីម៉ាក ចុះបញ្ជីម៉ាក ឬបដិសេធការសុំចុះបញ្ជី ម៉ាក ។ |
| Registration | Enregistrement, immatriculation | ការចុះបញ្ជី, ឧទាហរណ៍ : ការចុះបញ្ជីពាណិជ្ជករ និងក្រុមហ៊ុនត្រូវធ្វើនៅក្រសួងពាណិជ្ជកម្ម ក្នុងបញ្ជីមួយឈ្មោះហៅថា : បញ្ជីពាណិជ្ជកម្ម ។ |
| Registration of mark | Enregistrement de la marque | ការចុះបញ្ជីម៉ាក ។ ការចុះបញ្ជីម៉ាក បានផ្តល់សិទ្ធិដល់ផលិតករជាម្ចាស់ម៉ាកនូវការប្រើប្រាស់ផ្តាច់មុខនូវម៉ាកដែលចុះបញ្ជីនោះ។ ការចុះបញ្ជីម៉ាកត្រូវធ្វើនៅក្រសួងពាណិជ្ជកម្ម។ |
| Registred office | Siège sociale | ទីស្នាក់ការចុះបញ្ជី ឬ ជាកន្លែងប្រមូលផ្តុំការងាររដ្ឋបាល និង រាល់កិច្ចការច្បាប់របស់ក្រុមហ៊ុន ។ ទីស្នាក់ការចុះបញ្ជីអាចនៅខុសកន្លែងគ្នាពីទីកន្លែងធ្វើអាជីវ កម្ម របស់ក្រុមហ៊ុន ។ |
| Registred shareholder | Actionnaire inscrit au registre des actionnaires | ម្ចាស់ភាគហ៊ុនដែល បានចុះក្នុងបញ្ជីភាគហ៊ុន ។ |
| Regulation | Règlement | បទបញ្ជា។ |
| Rehabilitation | Redressement | ការធ្វើនីតិសម្បទា, ការស្តារឡើងវិញ (សិទ្ធិ-សមត្ថភាព-អាជីវកម្ម) របស់ក្រុមហ៊ុននៅពេលដែលក្រុមហ៊ុនស្ថិតនៅក្នុងភាពក្ស័យធន ក្នុងគោលបំណងជួយក្រុមហ៊ុនឱ្យរក្សាសកម្មភាព និង អាជីពរបស់ពលករ ។ ការធ្វើនិតីសម្បទាត្រូវសំរេចដោយតុលាការដោយតម្រូវឱ្យមានការគ្រប់គ្រងជាថ្មី និងមានរយៈពេលកំណត់មួយ ។ |
| Reimburse | Rembourser | សងមកវិញ ឬសងអោយវិញ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Relationship | Rapport | ទំនាក់ទំនង ។ |
| Relative | Relatif | ដែលអនុញ្ញាតអោយមានការលើកលែង ឬ អោយមានការតវ៉ា, លក្ខណៈមិនដាច់ខាតឬលក្ខណៈធៀប ។ |
| Relative majority | Majorité relative | សំលេងភាគច្រើនធម្មតា ។ នៅក្នុងការសំដែងមតិ ឬ បោះឆ្នោត គឺសំលេងភាគច្រើនធម្មតា លើគូប្រជែង ទោះជាមិនបាន ៥០ភាគរយក៏ដោយ ។ |
| Relative nullity | Nullité relative | មោឃភាពមិនដាច់ខាតៈ គឺមោឃភាពក្នុងករណីមានការភាន់ច្រឡំ ការបង្ខិតបង្ខំ ការបោកបន្លំ អសមត្ថភាព ឬ ខ្វះការព្រមព្រៀង ។ |
| Release | Libérer, decharger | ដោះលែង ឬ អោយរួចផុតពីកាតព្វកិច្ច ។ |
| Relevant authority | L'autorité compétente | អាជ្ញាធរមានសមត្ថកិច្ច ។ |
| Reliable | Digne de confiance | គួរអោយជឿបាន ។ |
| Remand | Renvoi | បញ្ជូនត្រឡប់ទៅវិញ ។ |
| Remedy | Dédommagement | ដំណោះស្រាយសងការខូចខាត ។ |
| Remit | Renvoyer | បង្វិលទៅវិញ ។ |
| Remittance | Règlement | ប្រាក់សងបំណុលដែលបានជំពាក់ ។ |
| Removal | Révocation:, Radiation | ការដកពីមុខតំណែង, ការលុបចោល ។ |
| Remove | Révoquer | ដកហូតពីដំណែង ។ |
| Renewal of a trade mark | Renouvellement de l' enregistrement | ការចុះបញ្ជីម៉ាកសារជាថ្មី : ជាការចុះបញ្ជីឡើងវិញ បន្ទាប់ពីវិញ្ញាបនប័ត្រនៃការចុះបញ្ជីពីមុនត្រូវអស់សុពលភាព ។ នៅព្រះរាជាណាចក្រកម្ពុជាសុពលភាពនេះមាន រយៈពេល១០ឆ្នាំ ។ |
| Repayement | Remboursement | សងបំណុល ។ |
| Represent | Représenter | តំណាងអោយ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Representative office | Bureau de représentations | ការិយាល័យតំណាងពាណិជ្ជកម្ម : ជាភ្នាក់ងាររបស់ជនបរទេស ហើយពុំមាននីតិបុគ្គលភាពដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ ។ការិយាល័យតំណាងពាណិជ្ជកម្មមិនអាចធ្វើសកម្មភាពទិញលក់សេវាជាប្រចាំឬធ្វើប្រតិបត្តិការកែច្នៃ និង សាងសង់នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទេ ។ |
| Repudiation | Résiliation | ការលុបចោល ( កិច្ចសន្យា) ។ |
| Request the court | Saisir un tribunal | ដាក់ពាក្យបណ្តឹងទៅតុលាការណាមួយ ។ |
| Res judicata | Chose jugée | សេចក្តីវិនិច្ឆ័យរបស់តុលាការ ចាត់ថាជាស្ថាពរ ដោយរយៈពេលទុកអោយឧទ្ធរណ៍បានហួសពេលកំណត់ ។ |
| Rescind | Annuler, resilier | បដិសេធ, លុបចោល ។ |
| Resignation | Démission | ការលាលែងពីមុខតំណែង ។ |
| Resort | Ressort | ដំណាក់កាលកាត់ក្តី, រង្វង់សមត្ថកិច្ចកាត់ក្តីរបស់តុលាការ ។ |
| Respite | Sursis | ការព្យួរទោស, ការមិនអនុវត្តការដាក់ទោសដល់ជនជាប់ចោទ (ឃុំឃាំង-ពិន័យជាប្រាក់) ប្រសិនបើជននោះមិនប្រព្រឹត្តកំហុស ក្នុងរយៈពេលមួយដែលកំណត់ដោយតុលាការ ។ |
| Restate | Réaffirmer | អះអាងថែមទៀត ។ |
| Restitution | Restitution | ការសងប្រាក់ ឬ វត្ថុអ្វីមួយវិញ ដែលបានជំពាក់ ។ |
| Restraint | Restriction; contrainte | ការរិតត្បិត, ការកំហិត ។ |
| Restrict | Limiter | ដាក់ក៏រិត, ដាក់កំហិត ។ |
| Restrictive | Restrictif | ដែលដាក់ក៏រិត ។ |
| Restrictive endorsement | Endossement restrictif | ចំណារលើខ្នងផលប័ត្រ ដោយដាក់ឈ្មោះអ្នកទទួល ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| | | **ឧទាហរណ៍:** ម្ចាស់ផលប័ត្រចារលើផលប័ត្រថា "សងប្រាក់ជូនតែលោក X" ។ |
| Review | Revision | ពិនិត្យឡើងវិញ |
| Revival | Remise en vigueur | ការដាក់អោយមានសុពលភាពឡើងវិញ ឬ អោយដំណើរការឡើងវិញ ។ |
| Revocable | Révocable | អាចដកហូតវិញបាន ។ |
| Revocation | Révocation | ការដកហូតអំណាច ឬ ដកហូតតួនាទីវិញ ។ |
| Revoke | Révoquer | ដកហូតវិញ, ដកហូតតួនាទីវិញ ។ |
| Right | Droit | សិទ្ធិ ។ |
| Right of action | Droit d'instituer un procès | សិទ្ធិប្តឹង តាមផ្លូវច្បាប់ ។ |
| Right of self-determination | Droit d'autodétermination | សិទ្ធិស្វ័យសំរេច ។ |
| Risk | Risque | ហានិភ័យនៃការបាត់បង់: ព្រឹត្តិការណ៍ដែលអាចបណ្តាលអោយមានការខូចខាតជាយថា ហេតុពេលអនុវត្តការងារអ្វីមួយ ។ ឧទាហរណ៍: ការអោយប្រាក់ទៅជនណាម្នាក់ខ្ចីដោយគ្មានទ្រព្យធានាម្ចាស់បំណុលមានហានិភ័យនៃការបាត់បង់ខ្ពស់ ។ |
| Risk of loss | Risque de perte | ការប្រថុយខាតបង់ពេលធ្វើអាជីវកម្ម ឬ ពេលទិញ-លក់ ។ |
| Royal Decree | Décret Royal | ព្រះរាជក្រឹត្យ: សេចក្តីសំរេចដែលធ្វើឡើងដោយព្រះមហាក្សត្រ ។ |
| Rule | Règle; Règlement | វិធាន, បទបញ្ញត្តិ |
| Rule of law | Etat de droit | នីតិរដ្ឋ: រដ្ឋមួយដែលយកច្បាប់ជាធំ មិនមែនមនុស្សណាម្នាក់ ឬ ក្រុមណាមួយឡើយ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Rule of origine | Règle d'origine | វិធានប្រភពដើមទំនិញៈ ជាលក្ខខណ្ឌផ្សេងៗ ដែលប្រទេសមួយ កំណត់លើទំនិញនាំចូលក្នុងគោលបំណងផ្តល់ភាពអនុគ្រោះពន្ធ ប្រសិនបើទំនិញនោះនាំចូលពីបណ្តាប្រទេសដែលត្រូវបានទទួលភាពអនុគ្រោះពន្ធ ។ |
| Run | Exploiter; encourir | ដំណើរការអាជីវកម្ម ។ |
| Run a factory | Diriger une usine | គ្រប់គ្រងក្រុមហ៊ុនមួយឬរោងចក្រមួយ ។ |
| Running | Courrant; en cours | ដែលកំពុងដំណើរការ ។ |
| Running account | Compte courant | គណនីចរន្តៈ ជាគណនីដែលអតិថិជនអាចដាក់ប្រាក់ ឬដកប្រាក់ប្រចាំថ្ងៃបានតាមចិត្តដោយគ្មានពេលកំណត់ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|

# S

| | | |
|---|---|---|
| Salary | Traitement | ប្រាក់ឈ្នួលការងារ ។ |
| Sale | La vente | ការលក់ ។ |
| Sale by auction | Vente aux enchères | លក់ដេញថ្លៃ ។ |
| Sale contract | Contrat de vente | កិច្ចសន្យាលក់ ។ |
| Sample | Echantillon | ទំនិញគំរូ ។ |
| Saving | Epargne | ប្រាក់សន្សំដែលម្ចាស់ប្រាក់បានដាក់ក្នុងធនាគារ ដើម្បីយកការប្រាក់ ឬធ្វើវិនិយោគផ្ទាល់ ។ |
| Seal | Cachet; sceau | ត្រា ។ |
| Secure | Nantir | ដាក់របស់បញ្ចាំ, ដាក់ទ្រព្យធានាកាតព្វកិច្ច ។ |
| Secured creditor | Créancier nanti | ម្ចាស់បំណុលដែលរក្សាទុកទ្រព្យធានាសំរាប់ជាការធានា ។ ម្ចាស់បំណួលនេះ មានសិទ្ធិជាអាទិភាពក្នុងការទទួលសំណងមុន ម្ចាស់បំណុលផ្សេងទៀត ។ |
| Secured obligation | Obligation garantie | កាតព្វកិច្ចមានកិច្ចធានាៈ ជាកតព្វកិច្ចដែលធានាដោយប្រាក់ ឬទ្រព្យធានា ។ |
| Securities | Titres, Valeurs mobilières | មូលប័ត្រលោះផ្សាយដោយក្រុមហ៊ុនមូលធន រួមមាន : ភាគហ៊ុន-សញ្ញាបណ្ណ័ នឹងបណ្ណ័បំណុលផ្សេងៗ ។ |
| Securities register | Registre des titres | បញ្ជីមូលប័ត្ររបស់ក្រុមហ៊ុនអនាមិក ។ |
| Security | Surêté | ទ្រព្យធានាបំណុលរួមមានៈកិច្ចសន្យាធានាសងបំណុលជំនួស (Guarantee) ទ្រព្យធានាបំណុលជាចលនទ្រព្យ (Pledge) នឹងទ្រព្យធានាបំណុលជាអចលនទ្រព្យ (Mortgage) ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Security Arrangement | Accord de nantissement | កិច្ចព្រមព្រៀងអំពីប្រាតិភោគ : ជាកិច្ចព្រមព្រៀងដែលកូនបំណុលប្រគល់ទ្រព្យធានាបំណុល ទៅអោយម្ចាស់បំណុល កាន់កាប់ ។ |
| Security interest | Droit de surêté | សិទ្ធិលើទ្រព្យធានាដែលបានដាក់ធានាលើការបំពេញកាតព្វកិច្ច ។ ឧទាហរណ៏: លោក "ក" បានខ្ចីលុយពីធនាគារ ដោយដាក់ផ្ទះមួយជាទ្រព្យធានា ។ បើលោក "ក " មិនបានសងតាមកាលកំណត់ទេធនាគារ អាចលក់ផ្ទះនោះដើម្បីទូទាត់បំណុល ។ |
| Security market | Marché des valeurs, Bourse | ផ្សារហ៊ុនៈ ជាទីផ្សារដែលក្រុមហ៊ុនមូលធនអាចធ្វើការលក់ដូរ ភាគហ៊ុន ឬ សញ្ញាប័ណ្ណ ។ |
| Seizure | Saisie | ការរឹបអូសទ្រព្យសម្បត្តិ ។ |
| Sentence | Sentence; jugement | សាលក្រម, សេចក្តីសំរេចរបស់តុលាការ ។ |
| Separation of powers | Séparation de pouvoirs | ការបែងចែកអំណាចក្នុងការគ្រប់គ្រងប្រទេស ។ ក្នុងនោះមានអំណាចនីតិប្រតិបត្តិរបស់រដ្ឋាភិបាល អំណាចនីតិបញ្ញត្តិរបស់សភាជាតិ និង អំណាចតុលាការ ។ |
| Serie of shares | Série d'actions | ស៊េរីនៃភាគហ៊ុន ។ ប្រភេទភាគហ៊ុននិមួយៗ អាចត្រូវបោះចេញជាស៊េរីតាមការកំណត់របស់លក្ខន្តិកៈរបស់ក្រុមហ៊ុនដោយមានភ្ជាប់លក្ខខណ្ឌនិងអាទិភាពផ្សេងៗ ។ |
| Set aside | Annuler: | ធ្វើអោយទៅជាមោឃៈ ( ច្បាប់ ឬ កិច្ចសន្យា) ។ |
| Settle | Règler, Trancher | ផ្សះផ្សាបញ្ចប់រឿងក្តី តាមការព្រមព្រៀង |
| Settlement | Résolution; Règlement | ការផ្សះផ្សាអោយមានការព្រមព្រៀងគ្នា ។ |
| Sevice mark | Marque de service | សេវាសញ្ញាៈ ម៉ាកដែលប្រើប្រាស់សំរាប់សំគាល់សេវា |
| Share | Action | ភាគហ៊ុនបោះផ្សាយដោយក្រុមហ៊ុនមូលធន តំណាងឱ្យចំណែកមួយនៃដើមទុនរបស់ក្រុមហ៊ុន ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Share certificate | Certificat d'action | ប័ណ្ណភាគហ៊ុន ។ |
| Shareholder | Actionnaire | ម្ចាស់ភាគហ៊ុនៈ អ្នកកាន់កាប់ភាគហ៊ុនក្នុងក្រុមហ៊ុនមូលធន ។ |
| Sharing | Participation | ការចូលរួមចំណែក ។ ចំណែកជាភាគហ៊ុនរបស់បុគ្គលណាម្នាក់នៅក្នុងដើមទុនក្រុមហ៊ុន |
| Similar | Analogue | ស្រដៀងគ្នា ប្រហាក់ប្រហែលគ្នា ( ទំនិញឬម៉ាក) ។ |
| Single member private limited company | Entreprise unipersonnelle | សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត : គឺជាទ្រង់ទ្រាយក្រុមហ៊ុនឯកជន ទទួលខុសត្រូវមានកំរិតដែលមាន ម្ចាស់ហ៊ុនតែម្នាក់ ។ |
| Smuggling | Contrebande | ការរត់ពន្ធ ។ |
| Solicitation | Sollicitation | ការទទូចសុំ ។ |
| Solvency | Solvabilité | ភាពដែលអាចសងបំណុលបានតាមការទាមទារ ។ |
| Sound mind | Sain d’esprit | សតិបញ្ញាធម្មតា ។ តាមច្បាប់ស្តីពីកិច្ចសន្យា គូរភាគីត្រូវមានសតិបញ្ញាធម្មតា នៅពេលចុះកិច្ចសន្យាជាមួយគ្នា ។ ពុំនោះទេ កិច្ចសន្យានឹងត្រូវចាត់ទុកជាមោឃៈ ។ |
| Special meeting | Assemblée extraordinaire | មហាសន្និបាតវិសាមញ្ញ ។ |
| Special Resolution | Decision speciale | សេចក្តីសំរេចពិសេសៈជាសេចក្តីសំរេចដែលបានធ្វើឡើង ដោយសំលេងឆ្នោតភាគច្រើនយ៉ាងតិច ២/៣ ។ |
| Specie | Espèces, numeraire | ក្រដាសប្រាក់ ។ |
| State | Déclarer | ប្រកាស, ថែង ។ |
| Stated capital | Capital déclaré | ដើមទុនចុះបញ្ជី ។ |
| Stated salary | Salaire fixe: | បៀវត្សថេរ មិនប្រែប្រួល ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Stated value | Valeur attribuée (à une action) | តម្លៃកំណត់ទុកជាមុន (លើភាគហ៊ុន)។ |
| Statement | Exposé | សេចក្ដីថ្លែងការណ៍។ |
| Statement of claim | Conclusion en demande | បណ្ដឹងទាមទារ។ |
| Statement of defense | Conclusion en defense | ពាក្យដោះសារ។ |
| Status | Statut légal | បុគ្គលិកលក្ខណៈតាមផ្លូវច្បាប់រួមមាន : សិទ្ធិ, ករណីយកិច្ច, ស្ថានភាពនិង សមត្ថភាពរបស់បុគ្គល ។ |
| Stock | Stock | ១- ទំនិញស្តុកទុកលក់ ។<br>២- ភាគហ៊ុន។ |
| Stock certificate | Titre au porteur | វិញ្ញាបនប័ត្រភាគហ៊ុនៈ ជាលិខិតបញ្ជាក់ភាគហ៊ុន នៅក្នុងក្រុមហ៊ុន ប៉ុន្តែគ្មានដាក់ឈ្មោះអ្នកកាន់កាប់ ។ |
| Stock company | Société par actions | សំរាប់ហៅក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ ក្រុមហ៊ុនអនាមិក (សូមអានពាក្យ Public limited company)។ |
| Stock Exchange | Bourse des valeurs | ផ្សារហ៊ុន : ទីផ្សារសំរាប់លក់ និង ទិញភាគហ៊ុន និង សញ្ញាប័ណ្ណ។ |
| Stockholder | Actionnaire | ម្ចាស់ភាគហ៊ុន។ |
| Store | Magasin | ហាងទំនិញ។ |
| Strict liability | Responsabilité sans faute | ការទទួលខុសត្រូវដាច់ខាត ដោយមិនបាំបាច់បង្ហាញកំហុស។ |
| Sub-contract | Sous-traitant | កិច្ចសន្យាធ្វើមួយចំណែក នៃកិច្ចសន្យាដើម ។<br>**ឧទាហរណ៍ :** ក្រុមហ៊ុន "ក" បានចុះកិច្ចសន្យាធ្វើអាគារមួយ (កិច្ចសន្យា ដើម) ទន្ទឹមនោះក្រុមហ៊ុន "ក" បានចុះកិច្ចសន្យាជាមួយ ក្រុមហ៊ុន "ខ" ឱ្យរៀបចំប្រព័ន្ធភ្លើង ។ កិច្ចសន្យារវាងក្រុមហ៊ុន "ក" និង |

| ENGLISH | FRENCH | KHMER |
|---|---|---|
| | | ក្រុមហ៊ុន "ខ" ហៅថាកិច្ចសន្យាមួយចំណែក (Sub-contract) ។ |
| Subdecree | Sous-décret | អនុក្រឹត្យចេញដោយនាយករដ្ឋមន្ត្រី ។ |
| Subordination | Subordination | ស្ថានភាពស្ថិតនៅក្រោមចំណុះអ្វីមួយ ។ |
| Subrogation | Subrogation; Substitution | ការដាក់ជំនួសដើម្បីកាន់កាប់សិទ្ធិបន្ត ។ |
| Subrogee | Subrogé | ជនដែលត្រូវដាក់ស្នងជំនួសដើម្បីកាន់កាប់សិទ្ធិបន្ត ។ |
| Subrogor | Subrogateur | ជនដែលត្រូវបានស្នងជំនួសដោយជនម្នាក់ទៀត ។ |
| Subscribe | Souscrire | សុំចូលហ៊ុន ។ |
| Subscriber | Souscripteur | អ្នកចូលរួមសកម្មភាពក្នុងក្រុមហ៊ុនមូលធនតាមរយៈការ ទិញភាគហ៊ុន ។ |
| Subscription | Souscription | ការចូលរួមសកម្មភាព ក្នុងក្រុមហ៊ុនមួយតាមរយៈការទិញ ភាគហ៊ុន ។ |
| Subscription right | Droit de souscription | សិទ្ធិជាអាទិភាពរបស់ម្ចាស់ហ៊ុនដែលអាចទិញភាគហ៊ុនបន្ថែមដើម្បីបង្កើនដើមទុនរបស់ខ្លួន ។ |
| Subsidiary | Company Filiale | បុត្រសម្ព័ន្ធក្រុមហ៊ុន : គឺជាក្រុមហ៊ុនដែលគ្រប់គ្រងដោយក្រុមហ៊ុនមួយទៀត ហៅថា" ក្រុមហ៊ុនមេ "។ ក្រុមហ៊ុន មេកាន់កាប់ភាគហ៊ុនយ៉ាងតិច 51% របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ។ |
| Subsidy | Subvention | ការឧបត្ថម្ភធនៈ ជាជំនួយហិរញ្ញវត្ថុរបស់រដ្ឋាភិបាលដល់ស្ថាប័ន ឯកជនឬក្រុមហ៊ុនឯកជនក្នុងគោលគោលបំណងជួយលើកទឹកចិត្តដល់ការផលិត ឬការនាំចេញ ។ |
| Substitute arbitrator | Arbitre remplaçant | អាជ្ញាកណ្តាលជំនួសៈ ក្នុងពេលដែលអាជ្ញាកណ្តាលម្នាក់ត្រូវបានដកហូតអំណាចវិញ អាជ្ញាកណ្តាលជំនួសម្នាក់ត្រូវបានចាត់តាំងឡើងក្រោមនីតិវិធីដដែល ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Succession | Succession | ការទទួលកាន់កាប់បន្តនូវមតិករបស់អ្នកស្លាប់តាមលក្ខណៈច្បាប់ ឬតាមមតិកសាសន៍ ។ |
| Successor | Successeur | អ្នកទទួលកាន់កាប់បន្ត, អ្នកបន្តវេន ។ |
| Sue | Porter plainte | ប្តឹងជនណាម្នាក់ ។ |
| Summon | Citation à compararaîte | ដីកាកោះអញ្ជើញអោយមកបង្ហាញខ្លួននៅក្នុងតុលាការ ។ |
| Supplier | Fournisseur | អ្នកផ្គត់ផ្គង់, អ្នកលក់ ។ |
| Suprem Court | Cour suprême | តុលាការកំពូល ។ |
| Surety | Cautionnement | ការធានាសងបំណុលជំនួសកូនបំណុលម្នាក់ ប្រសិនបើកូនបំណុលនោះ ខកខានមិនបានសងបំណុលដល់ម្ចាស់បំណុលតាមកិច្ចសន្យាទេ ។ |
| Surplus | Exédent | ចំនួនលើស ។ |
| Surrender | Cèder | ផ្ទេរ, ប្រគល់អោយ ។ |
| Surviving company | Société absorbante | ក្រុមហ៊ុនដែលត្រូវនៅបន្តអាជីវកម្ម នៅក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា (Merger) ។ |
| Sustain | Soutenir | គាំទ្រ ។ |
| Synallagmatic (contract) | Contrat bilatéral | កិច្ចសន្យាទ្វេភាគី ។ |

# T

| ENGLISH | FRENCH | KHMER |
|---|---|---|
| Tacit | Tacite | យល់ព្រមដោយស្ងៀមស្ងាត់។ |
| Tacit reconduction | Reconduction tacite | បន្តកិច្ចសន្យាជាថ្មី តាមឆន្ទះរបស់គូរភាគី ដោយមិនចាំបាច់ធ្វើកិច្ចសន្យាឡើងវិញ ។ |
| Tangible property | Bien corporel | ទ្រព្យរូបិយ៍, ចលនទ្រព្យ និងអចលនទ្រព្យដែលអាចកាន់បាន។ |
| Tax | Taxe; Impôt | អាករ, ពន្ធ។ |
| Tenancy | Location | គារកាន់កាប់អចលនទ្រព្យតាមរយៈការជួល។ |
| Tenant | Locataire | អ្នកជួល។ |
| Termination of the mandate | Cessation du mandat | ការបញ្ចប់អាណត្តិ។ |
| Testament | Testament | មតិកសាសន៏ៈ បណ្តាំដែលទាក់ទងដល់ការចាត់ចែងទ្រព្យសម្បត្តិរបស់ជនណាម្នាក់ហើយដែលត្រូវអនុវត្តក្រោយពេលមរណភាព ។ |
| Testamentary succession | Succession par testament | ការទទួលកាន់កាប់ទ្រព្យសម្បត្តិតាមរយៈមតិកសាសន៏របស់អ្នកស្លាប់ ។ |
| Testator | Testateur | ម្ចាស់មតិកសាសន៏។ |
| Testify | Témoigner | ធ្វើជាសាក្សី អោយភាគីណាមួយ។ |
| Testimony | Témoignage | សក្ខីកម្ម, ភស្តុតាងដែលផ្តល់អោយដោយសាក្សី។ |
| Third party | Tierce personne | តតិយជន, ភាគីទី៣ ក្រៅពីភាគីពាក់ព័ន្ធ ឬ បុគ្គលដែលមិនមែនជាសមាជិកក្រុមហ៊ុន។ |
| Threaten | Menacer | គំរាមកំហែង, មានចេតនាធ្វើអោយខូចខាត ឬ ធ្វើអោយឈឺចាប់។ |
| To enter into on negotiation | Entamer une négociation | ចូលធ្វើការចរចារ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Topic | Thème de discussion | ប្រធានបទពិភាក្សា ។ |
| Trade balance | Balance commerciale | ជញ្ជីងពាណិជ្ជកម្មៈ ការប្រៀបធៀបរវាងការនាំចេញ និង ការនាំចូលរបស់ប្រទេសមួយ ។ |
| Trade circle | Milieu commercial | មជ្ឈដ្ឋានពាណិជ្ជកម្ម ។ |
| Trade mark | Marque de commerce | ពាណិជ្ជសញ្ញាៈ ម៉ាកដែលប្រើប្រាស់សំរាប់សំគាល់ទំនិញ ។ |
| Trade name | Nom commercial | ពាណិជ្ជនាមៈ ជាឈ្មោះ ឬ ជាសញ្ញាសំគាល់សំរាប់សហគ្រាសមួយ ។ |
| Trade secret | Secret de fabrication | ការសម្ងាត់ផ្នែកពាណិជ្ជកម្មៈ រូបមន្ត និង ពត៌មានដែលត្រូវប្រើប្រាស់ក្នុងអាជីវកម្ម ហើយត្រូវរក្សាជាការសម្ងាត់ ដើម្បីទាញយកអត្ថប្រយោជន៍លើគូរប្រជែងដែលមិនទាន់បានដឹងពីរូបមន្ត និងពត៌មានទាំងនោះ ។ |
| Trade union | Syndicat des ouvriers | សហជីពកម្មករ ។ |
| Trader | Commerçant | ពាណិជ្ជករ ។ |
| Trading activity | Acte de commerce | ពាណិជ្ជកិច្ចៈ (សូមអានពាក្យ Act of merchant) ។ |
| Transaction | Transaction | កិច្ចការជំនួញ ។ |
| Transfer | Transfert | ផ្ទេរ, ផ្ទេរកម្មសិទ្ធ ។ |
| Transfer of title | Cession du titre de propriété | ការផ្ទេរសិទ្ធិកាន់កាប់ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមរយៈការលក់ដូរ ឬ ការផ្តល់អោយ ។ |
| Transferee: | Cessionnair | អ្នកទទួលសិទ្ធិពីការធ្វើអនុប្បទានសិទ្ធិ ។ |
| Transitional provision | Disposition transitoire | អន្តរប្បញ្ញត្តិ ។ |
| Transmission | Transmission | ការផ្ទេរពីដៃមួយ ទៅដៃម្នាក់ទៀត ។ ការផ្ទេរនេះអាចកើតឡើងដោយឆន្ទៈរបស់អ្នកផ្ទេរ ដោយការកំណត់របស់ច្បាប់ ឬ ដោយមរណភាព ។ល ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|
| Transnational corporation | Firme multinationale | ក្រុមហ៊ុនអន្តរជាតិធ្វើអាជីវកម្មនៅក្នុងប្រទេសលើសពីមួយ ។ |
| Transparency | Transparence | តម្លាភាពៈ ភាពមិនលាក់លាមក្នុងកិច្ចការ ។ |
| Treat | Menace | ការគំរាមកំហែង ។ |
| Trial | Jugement; procès | ការជំនុំជំរះក្តី, រឿងក្តី ។ |
| Trial court | Tribunal de première instance | សាលាដំបូង ។ |
| Tribunal | Tribunal | សាលាជំនុំជំរះក្តី ឬ តុលាការជំនុំជំរះក្តី ។ |
| Trust | Trust | ការរួមបញ្ចូលផលប្រយោជន៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមេ ទៅលើក្រុមហ៊ុនសម្ពន្ធ័ជាច្រើន តាមរយៈការទិញភាគហ៊ុនជាច្រើនរបស់ក្រុមហ៊ុនសម្ពន្ធ័ ដើម្បីគ្រប់គ្រងក្រុមហ៊ុនសម្ពន្ធ័ទាំងនោះ ។ គោលបំណងនៃការបង្កើតប្រពន្ធ័ក្រុមហ៊ុនប្រភេទនេះ គឺសំដៅបង្កើតភាពផ្តាច់មុខនៅលើទីផ្សារ ។ |
| Trustee in bankruptcy | Syndic de faillite | ជនដែលតុលាការចាត់តាំងអោយចាត់ចែងលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ឬ ពាណិជ្ជករធនក្ស័យ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|

# U

| | | |
|---|---|---|
| Unanimous consent | Consentement unanime | ការយល់ព្រមជាឯកច្ឆ័ន្ទ ។ |
| Unanimously | Unanimité | ឯកច្ឆ័ន្ទ ។ |
| Undue | Indu, Illégitime | មិនគួរបាន, ខុសច្បាប់ |
| Unfair competition | Concurrence deloyale | ការប្រកួតប្រជែងមិនស្មោះត្រង់ ឬការរកស៊ីដេញជើងគ្នា ។ ជាអំពើក្រួតប្រជែងដែលមិនគោរពតាមច្បាប់ឬយន្តការកំណត់ ដែលបង្កអោយមានការខូចខាតផលប្រយោជន៏ដល់អាជីវករដែលអនុវត្តច្បាប់ ។<br>**ឧទាហរណ៏ :** ការដាក់ ម៉ាក់ ឬឈ្មោះ ទំនិញមួយ ឬចម្លងផលិតផលឱ្យដូចទៅនឹងម៉ាក ឬ ឈ្មោះទំនិញមួយរបស់ក្រុមហ៊ុនផ្សេង ក្នុងគោលបំណងធ្វើអោយអតិថិជនមានការភន្ត័ច្រឡំ ។ |
| Unilateral | Unilatéral | ឯកតោភាគី: កាសំរេចធ្វើឡើងដោយភាគីតែម្ខាង។ |
| Unlawful | Contraire à la loi | ផ្ទុយនឹងច្បាប់។ |
| Usage | Coutume | ទម្លាប់។ |
| Use | Droit d'usage | សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិអ្នកដទៃ ។ |
| Usufruct | Usufruit | សិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិអ្នកដទៃ និង ទទួលផលពីការប្រើប្រាស់ទ្រព្យសម្បត្តិនោះប៉ុន្តែមិនត្រូវធ្វើអោយមានការប្រែប្រួលសារធាតុនៃទ្រព្យសម្បត្តិនោះឡើយ ។ |
| Usury | Usure | ការអោយខ្ចីប្រាក់ ដោយកំណត់អត្រាការប្រាក់ហួសប្រមាណ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|

# V

| | | |
|---|---|---|
| Validity | Validité | សុពលភាព, រយៈពេលប្រើប្រាស់ ។ |
| Validity of agreement | Validité de la convention | សុពលភាពនៃកិច្ចព្រមព្រៀង៖ រយៈពេលអនុវត្ត កិច្ចព្រមព្រៀង ។<br><br>ឧទាហរណ៍៖ ដើម្បីបញ្ជាក់ពី រយៈពេលប្រើប្រាស់នៃកិច្ចព្រមព្រៀង ជាទូទៅភាគី ធ្វើកិច្ចព្រមព្រៀងតែងបញ្ជាក់នៅក្នុង ខ ចុងក្រោយ ថា កិច្ចព្រមព្រៀងនេះមានសុពលភាពរហូតដល់ ថ្ងៃទី.............. ។ |
| Verification | Vérification | ការពិនិត្យបញ្ជាក់ ។ |
| Vice | Vice | គុណវិបត្តិ ។ |
| Violation | violation; Infringement | ការរំលោភ ។ |
| Void | Nul | មោឃៈ ។ |
| Voidable | Annulable | ដែលអាចទុកជាមោឃៈបាន ។ |
| Vote | Voter | បោះឆ្នោត ។ |
| Voting share | Action à droit de vote | ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត ។ |

| ENGLISH | FRENCH | KHMER |
| --- | --- | --- |

# W

| | | |
| --- | --- | --- |
| Wage | Salaire | ប្រាក់បៀវត្ស។ |
| Waive | Renoncer à | លះបង់សិទ្ធិ, ឈប់ទាមទារសិទ្ធិ។ |
| Waiver | Renonciation | ការលះបង់សិទ្ធិ។ |
| Warrant | Garantie | ការសន្យារ៉ាប់រង, ការធានាតាមរូបភាពផ្សេងៗ។ |
| Warranty of title | Attestation du titre | ការរ៉ាប់រងលើកម្មសិទ្ធិដើម្បីអះអាងថា ខ្លួនពិតជាម្ចាស់ទ្រព្យនោះមែន។ |
| Well-known mark | Marque notoire | ជាម៉ាកដែលល្បីៈ ជាម៉ាកដែលគេស្គាល់គ្រប់គ្នា។ ម៉ាកដែលល្បីទោះជាមិនបានចុះបញ្ជីការពារនៅព្រះរាជា ណាចក្រកម្ពុជា ក៏ដោយក៏ត្រូវបានទទួលការការពារពីរាជរដ្ឋាភិបាលកម្ពុជាដែរ។<br>**ឧទាហរណ៍ ៖** KODAK TOYOTA។ |
| Wholesale | Vente en gros | ការលក់ដុំ។ |
| Wholesaler | Grossiste | អ្នកលក់ដុំ។ |
| Will | Testament | មតិកសាសន៍, សំបុត្របណ្តាំ។ |
| Withdraw | Retirer, se retiner | ដកខ្លួនចេញ, ដកចេញ ។ |
| Witness | Témoin: | សាក្សី។ |
| World Intellectual Property Organization (WIPO) | Organisation Mondiale de la Propriété Intellectuelle (OMPI) | អង្គការកម្មសិទ្ធិបញ្ញាពិភពលោកជាអង្គការទទួលខុសត្រូវចំពោះការការពារកម្មសិទ្ធិបញ្ញា ។ កិច្ចព្រមព្រៀងសំខាន់ ២ ដែលគ្រប់គ្រងដោយ WIPO គឺ ៖<br>- អនុសញ្ញាទីក្រុងប៉ារីស សំរាប់ការពារកម្មសិទ្ធិឧស្សាហកម្ម |

| ENGLISH | FRENCH | KHMER |
|---|---|---|
| | | - អនុសញ្ញាទីក្រុងប៊ែន សំរាប់ការពារសិទ្ធិអ្នកនិពន្ធ ។ WIPO ត្រូវបានបង្កើតឡើង តាមអនុសញ្ញាស្តុកខុល ចុះ ហត្ថលេខាថ្ងៃ ១៤ កក្កដា ១៩៦៧ ។ ប្រវត្តរបស់ WIPO ចាប់ផ្តើម តាំងពីឆ្នាំ ១៨៨៣ នឹងឆ្នាំ ១៨៨៦ នៅពេលនោះ ឆ្នាំ ១៨៨៣ ជាឆ្នាំ បង្កើតអនុសញ្ញាទីក្រុងប៉ារីស នឹងឆ្នាំ ១៨៨៦ ជាឆ្នាំ បង្កើត អនុសញ្ញាទីក្រុងប៊ែន ។ ព្រះរាជាណា ចក្រកម្ពុជា បានផ្តល់សច្ចាប័ន នឹងចូលជាសមាជិក អង្គការ WIPO នៅថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ១៩៩៥ ។ |
| Wrong fully | Injustement | អំពើខុសដោយបំពានលើសិទ្ធិរបស់ជនណាម្នាក់ ។ |
| Wrongful act | Acte injustifié | អំពើរប្រព្រឹត្តរំលោភលើសិទ្ធិអ្នកដទៃ ។ |

| ENGLISH | FRENCH | KHMER |
|---|---|---|

# Y

| | | |
|---|---|---|
| Yield | Rendement | ទិន្នផល ។ |